ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 09-Apr-2012, 09:19
CMS/CFO: Kauv Keoratanak

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្ដីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១២**

**ម៉ោង ០៩:០៥ នាទី**

**សវនាការលើកទី៤៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ (អវត្តមាន)
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្ដារា

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

លោក រ៉ូជ័រ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន
*(Mr. Michiel PESTMAN)*

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ម៉ុច សុវណ្ណារី

លោក ហុង គឹមសួន

លោកស្រី ជេត វណ្ណលី

លោកស្រី ស៊ីន សុវ៉ន

លោក វ៉ែន ពៅ

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

លោកស្រី ម៉ារី ហ្គីរ៉ូដ

*(Ms. Marie GUIRAUD)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| លោក សុន អរុណ | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក ហ្សាស្ដើ ប៉ៅ | អង់គ្លេស |
| លោក អាង ឧត្ដម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក កាំង ហ្គេកអ៊ាវ | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី ÷ កាំង ហ្គេកអ៊ាវ ហៅ ឌុច**


សួរបន្តដោយលោក ម៉ៃខល ផេសមិន ផ្តើមពី៖ ..........ទំព័រ០២

សួរដោយលោក ហ្សាស្តេី ប៉ៅ ផ្តើមពី៖ ..........ទំព័រ៥១

សួរដោយលោក សុន អរុណ ផ្តើមពី៖..........ទំព័រ៧២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៥:០៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តការស្តាប់សក្ខីកម្មរបស់សាក្សីឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលនឹងបន្តការសួរដេញដោលដោយក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា។ មុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី នួន ជា អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីនៃរឿងក្តីក្នុងសំណុំរឿង០០២ ទាំងអស់ថា នៅក្នុងកិច្ចដំណើរការសវនាការក្នុងថ្ងៃនេះ នឹងអាចរហូតដល់ពីរថ្ងៃដើមសប្តាហ៍ក្រោយ លោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ មានបញ្ហាសុខភាព ដែលបាននឹងកំពុងសម្រាកព្យាបាល គាត់មិនអាចចូលរួមក្នុងកិច្ចដំណើរសវនាការបាន។ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយនឹងបណ្តាចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង យើងសម្រេចតែងតាំងលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ ដែលលជាចៅក្រមបម្រុងអន្តរជាតិជំនួសកន្លែងចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដែលអវត្តមានរហូតដល់ពេលលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ មានវត្តមាន និងមានលទ្ធភាពអាចបំពេញការងារក្នុងការចូលរួមសវនាការនៅអង្គជំនុំជម្រះសាលាដំបូងវិញបាន។ នេះជាការអនុវត្តដោយផ្អែកតាមបទប្បញ្ញត្តិនៃវិធាន៧៩ អនុវិធាន៤ នៃបទប្បញ្ញត្តិ-- នៃបទបញ្ជាផ្ទៃក្នុង អ.វ.ត.ក។

[០៩:០៦:៥៥]

តទៅនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន សូមជម្រាបសួរ លោក លោកស្រីចៅក្រម ភាគីទាំងអស់។ ពីម្សិលមិញយើងបានព្យាយាមឲ្យ *អ៊ិនធើហ្វេស* ធ្វើដំណើរការ ប៉ុន្តែមានការលំបាក។ ប៉ុន្តែខ្ញុំបានបញ្ជូនឯកសារទាំងអស់ទៅលោក លោកស្រីចៅក្រម និងភាគីទាំងអស់ហើយ។ ហើយយើងខ្ញុំនឹងប្រើឯកសារទាំងនោះ

នៅថ្ងៃនេះ។ ហើយខ្ញុំបានឃើញលោកចៅក្រមងក់ក្បាល។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតបន្តទៅឯកសារមួយទៀតសម្រាប់សាក្សីរូបនេះ។

[០៩:០៧:៣៩]

ឯកសារទីមួយនៅលើបញ្ជីនោះ ខ្ញុំគិតថាខ្ញុំមិនចាំបាច់អានលេខ ERN ឬលេខឯកសារទៀតទេ។ ខ្ញុំសូមអនុញ្ញាត សូមឱ្យមន្ត្រីតុលាការ ហើយនិងសាក្សីពិនិត្យមើលឯកសារ ហើយសូមមន្ត្រីតុលាការបង្ហាញឯកសារលើអេក្រង់បាទ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីសូមលោកបញ្ជាក់អំពីអត្តសញ្ញាណឯកសារ ហើយនិងលេខ ERN ផង ដើម្បីជាប្រតិចារឹកនៅក្នុងកិច្ចដំណើរការសវនាការរបស់យើង។ បើមិនធ្វើដូច្នោះទេ មិនមានប្រតិចារឹកចូលទៅក្នុងកិច្ចការដំណើរការប្រក្រតីភាពនៃកិច្ចដំណើរការរបស់យើងបានទេ។

**លោក ម៉ៃខល ផេសមិន៖**

ឯកសារ D43/IV ឧបសម្ព័ន្ធលេខ១១ ខ្មែរ 00170883 បន្តទៅទៀត 00583931 ភាសាបារាំង 00280047។

[០៩:០៩:១៦]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីមេធាវីយកជូនសាក្សីពិនិត្យ!

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ឌុច សំណួររបស់ខ្ញុំគឺថា សួរលោកថា តើលោកស្គាល់ឯកសារនេះដែរឬទេ?

[០៩:១០:០៨]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំស្គាល់ឯកសារនេះ។

**ស៖** សូមលោកជម្រាបតុលាការដោយសង្ខេប ថាតើកំណត់ដៃនេះមានន័យដូចម្តេច? ដែលខ្ញុំប្រើពាក្យ "កំណត់ដៃ" នេះគឺថាដែលអក្សរដែលសរសេរនៅលើហ្នឹង មានអត្ថន័យដូចម្តេច? ថាអ្នកណាជាអ្នកសរសេរនូវខ្លឹមសារនេះបាទ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ឯកសារនេះវាជាលិខិតអមផ្ញើរបស់ភូមិភាគ៨០១ ដែលមានលេខាភាគឈ្មោះ សែ ជូនមកអចិន្ត្រៃយ៍មជ្ឈិមបក្ស គឺគណៈ៨៧០។ នេះខ្ញុំសូមបញ្ជាប់ប៉ុណ្ណេះ។

**សៈ** តើត្រូវដែរឬទេ បើខ្ញុំនិយាយថា នេះជា-- នេះគឺជាកំណត់ដៃហៅថា "ដីកាអមភ្ជាប់ជាមួយចម្លើយសារភាព"? តើអ៊ីចឹងដែរឬទេ?

[០៩:១១:៤៥]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ច្បាស់លាស់ណាស់ គឺអ៊ីចឹង។

**សៈ** កំណត់ដៃនេះ គឺថាបញ្ជូនទៅគណៈមន្ទីរ៨៧០ តើលោកអាចជម្រាបតុលាការ និងខ្ញុំបានទេ ថាតើមន្ទីរ៨៧០ នេះជាអ្វី? ហើយមានអ្នកណាជាសមាជិក?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន អក្សរដែលសរសេរនៅនេះ "គណៈ៨៧០" មិនមែន "គណៈមន្ទីរ៨៧០" ទេ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង "គណៈ៨៧០"។

**សៈ** តើលោកដឹងទេ តើកំណត់ដៃនេះជូនទៅអ្នកណា ដែលគេដាក់ថា "គណៈ៨៧០" នេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន "គណៈ៨៧០" នេះ គឺបងប៉ុល! ប៉ុល ពត។

**សៈ** សូមអរគុណ។ ឥឡូវនេះសូមលោកអានអត្ថបទនៅក្នុងប្រអប់ក្រហម ហើយអត្ថបទអក្សរនោះសរសេរក្រហមដែរបាទ។

[០៩:១៣:៣៣]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខាងលើបំផុតដាក់ថា "អ/ហ" មានន័យថា "អានហើយ"។ បន្ទាប់មកទៀតសរសេរ "១៤/៤/៧៨" (ស៊ីក) គឺមានន័យថា "១៤ មេសា ១៩៧៨" (ស៊ីក)។ ជួរខាងក្រោមសរសេរ "តាមដាន"។

**សៈ** សូមលោកប្រាប់តុលាការថា អ្នកណាជាអ្នកសរសេរចំណារក្រហមនេះ តាមដែលលោកដឹង និងស្គាល់នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំជឿថា នេះជាចំណាររបស់បង នួន ជា។

**សៈ** លោកជឿថា តើលោកប្រាកដទេ លោកមិនមានការសង្ស័យទាល់តែសោះឬ?

**ឆ៖** ខ្ញុំមិនសង្ស័យទេ។

[០៩:១៤:៥៨]

**សៈ** ខ្ញុំសួរលោក ពីព្រោះថាម្សិលមិញនោះ នៅចំណុចមួយលោកសន្និដ្ឋានទេ ការ-- ចំណារ

ផ្ទាល់ដៃនោះជារបស់លោក នួន ជា។ ប៉ុន្តែចំណុចមួយនេះលោកប្រាកដ ច្បាស់ទេ ដោយមិនសង្ស័យនោះបាទ?

**ឆ៖** ខ្ញុំមិនសង្ស័យទេ។

**ស៖** តើលោកអាចពន្យល់តុលាការបានទេ ហេតុអ្វីបានជាលោកប្រាកដ ហើយលោកគ្មានការសង្ស័យទាល់ៗតែសោះ ថាចំណារនេះរបស់លោក នួន ជា នោះ? សូមលោកនិយាយដោយពាក្យផ្ទាល់របស់លោក។

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ទីមួយលក្ខណៈតួអក្សរ ដែលខ្ញុំធ្លាប់ចំណាំ អានេះជាតួអក្សររបស់បង នួន ជា។ ទីពីរ “អ/ហ” នេះ បានន័យថា “អានហើយ”។ ខ្ញុំបានជម្រាបអង្គជំនុំជម្រះពីម្សិលមិញហើយ បង នួន ជា ខ្ញុំ គាត់ចូលចិត្តណាស់អាអស់ហើយ ហើរហើយ នៅខាងចុងនេះ។ ទីបីគាត់ជាមនុស្សតែម្នាក់គត់ ក្រោយពីថ្ងៃ២៥ ខែវិច្ឆិកា ១៩៧៨ ដែលមាន-- ៧៧ គាត់ជាមនុស្សតែម្នាក់គត់ក្រោយថ្ងៃ២៥ តុលា ១៩៧៧ ដែលមានសមត្ថកិច្ចគិតគូរអំពីការងារគ្រប់យ៉ាង ក្នុងនោះមានការងារសន្តិបាលមួយផងដែរ។ ដូច្នេះឯកសារនេះវាចុះកាលបរិច្ឆេទថ្ងៃ១៤ មេសា ១៩៧៨។ ទីបួន ពាក្យ “តាមដាន” នេះ ពិតជាសមត្ថកិច្ចរបស់គាត់នៅពេលនុ៎ង។ គាត់មានសិទ្ធិជំនួសប៉ុល ពត នៅក្នុងករណីការងារខ្លះ នៅពេលដែល ប៉ុល ពត រវល់។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ។

[០៩:១៧:២៧]

**ស៖** សូមអរគុណ។ លោកបានផ្តល់សក្ខីកម្មបែបនេះ ជូនសហចៅក្រមស៊ើបអង្កេត។ តើលោកចាំទេថា លោកបានជម្រាបសហចៅក្រមស៊ើបអង្កេតដូចម្តេច អំពីចំណារមួយនេះ?

**ឆ៖** ខ្ញុំមិនចាំទេ។

**ស៖** ខ្ញុំក៏គិតថា លោកមិនចាំដែរ។ ដូច្នេះខ្ញុំសូមដកស្រង់អំពីចម្លើយរបស់លោក ដែលឆ្លើយប្រាប់សហចៅក្រមស៊ើបអង្កេត ដែលនិយាយថា ឯកសារ D117 ខ្មែរ ERN 00239834 អង់គ្លេស ERN 00242876 បារាំង ERN 00239824។ ឥឡូវនេះខ្ញុំនឹងដកស្រង់សម្តីលោកមួយចំនួន ដែលលោកពន្យល់អំពីចំណារផ្ទាល់ដៃនេះ ជូនសហចៅក្រមស៊ើបអង្កេត “បាទ អាពណ៌ក្រហមគឺដើម្បីបន្ត” នេះគឺជាការបកប្រែរបស់លោក គឺថា “ខ្ញុំមិនដឹងថា អ្នកណាជាអ្នកសរសេរនោះទេ។ ប៉ុន្តែមិនមែនប៉ុល ពត ទេ ដែលចំណាររបស់គាត់ស្រដៀងរបស់ខ្ញុំ ដូចជា វន វ៉េត និង សុន សេន ប្រហែលជានួន ជា ជាអ្នកសរសេរចំណារនេះ។ ប៉ុន្តែគ្រាន់តែជាការសន្និដ្ឋានរបស់ខ្ញុំទេ ពីព្រោះខ្ញុំមិនបានឃើញចំណារផ្ទាល់

ដៃរបស់គាត់ញឹកញាប់ទេ"។ តើលោកចាំថា លោកនិយាយអ៊ីចឹងប្រាប់ទៅសហចៅក្រមស៊ើបអង្កេតដែរឬទេ?

[០៩:១៩:៣០]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន នេះជាការកត់ត្រាជាលាយលក្ខណ៍អក្សរនៅក្នុងកំណត់ហេតុសួរចម្លើយក្នុងរយៈកាលស៊ើបអង្កេត។ អត់មានអីខុសទេ។ ខ្ញុំនឹកឃើញទាំងអស់ឡើងវិញ។

**ស៖** តើលោកអាចពន្យល់ជូនតុលាការបានទេ ហេតុអ្វីនៅពេលនោះលោកមិនប្រាកដទេថាជាចំណាររបស់អ្នកណា ប៉ុន្តែឥឡូវនេះ លោកបែរជាថាច្បាស់ប្រាកដណាស់ ថាជាចំណាររបស់លោក នួន ជា។ តើលោកអាចពន្យល់ពីគំនិតនេះបានទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន របៀបដែលខ្ញុំរាយការណ៍ជូនសហចៅក្រមស៊ើបអង្កេតឈរលើគោលការណ៍មួយគឺ ថ្លឹងថ្លែងរវាង "អឺ" ហើយនិង "ទេ" តាមពិនិត្យគឺ ខ្ញុំថ្លឹងថ្លែងអ៊ីចឹងមែន។ ឃើញមួយភ្លែតដំបូង អក្សរនេះមិនមែនអក្សរបងប៉ុល ទេ ហើយក៏មិនមែនអក្សរបងខៀវ ដែរ។ ដូច្នេះ អាចជាអក្សរបងនួន នេះការថ្លឹងថ្លែងជំនាន់នុំង ដើម្បីបង្ហាញភាពរាបសារដែលយើងមិនហ៊ានថាភ្លាមនៅពេលដែលឯកសារ មិនទាន់បានគ្រប់ចំនួនល្មមនឹងយើងហ៊ានសន្និដ្ឋាន។ នេះ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** លោកនិយាយថា លោកបានជម្រាបសហចៅក្រមស៊ើបអង្កេតថា លោកមិនបានឃើញអក្សរផ្ទាល់ដៃរបស់ នួន ជា ញឹកញាប់ទេ តើលោកបាននិយាយអ៊ីចឹងដែរឬទេ?

[០៩:២១:៤៧]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន មុនថ្ងៃ៧ មករា ១៩៧៩ ខ្ញុំឃើញអក្សរបងនួន តែសរសេរមកខ្ញុំប៉ុន្មានសំបុត្រទេខ្លីៗ ដូចជាប្អូនសំបុត្រ ឬប្រាំសំបុត្រ ខ្ញុំរក្សាទុកនៅហ្នឹងផ្ទះខ្ញុំ ប្រហែលជាគេប្រមូលបានរួចមកហើយ។ ក្រៅពីនោះ ខ្ញុំមិនបានឃើញចំណារបងនួនទេ។ ក្រោយមក ខ្ញុំឃើញចំណារតិចតួច នៅពេលដែលខ្ញុំសរសេរអត្ថបទផ្សាយតាមវិទ្យុ នៅមន្ទីរក-១៨ ចន្លោះឆ្នាំ១៩៨៨, ៨៩-១៩៩០។ អត្ថបទណាដែលគាត់អានហើយហ្នឹង ជួនអីគាត់គូសខ្វែងនៅខាងចុងខាងលើបន្តិច ជួនអីគាត់ដាក់ "អ/ហ" នេះទម្លាប់គាត់។ ដូច្នេះ នៅពេលដែលខ្ញុំសន្និដ្ឋានជូនសហចៅក្រមស៊ើបអង្កេត ឈរលើការយល់ដឹងត្រឹមប៉ុណ្ណឹង។ ដល់ក្រោយមក នៅក្នុងរយៈកាលសវនាការ ខ្ញុំឃើញឯកសារច្រើនដែរ ថែមទៀត។ ហ្នឹង ខ្ញុំសូមនិយាយប៉ុណ្ណឹង។

[០៩:២៣:១៣]

**ស៖** នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ លោកបានសរសេរ ហើយនិងឆ្លើយតបទៅនឹងសំណួរមួយចំនួន ដែលសហចៅក្រមស៊ើបអង្កេតសួរលោក អំពីលិខិតមួយដែលលោកទើបតែនិយាយអំមិញនេះ ដែលមានពាក្យខ្លីៗមួយចំនួន នោះគឺជាសេចក្តីដកស្រង់ដែលលោកនិយាយពីកំណាត់ហេតុ ដែលខ្ញុំយកពីឯកសារ D121/4 ខ្មែរ 00406238 អង់គ្លេស ERN 00434349 បារាំង 00208249។ លោកសរសេរថា កាលនោះគឺថា សំបុត្រទាំងនោះដែលលោកបានទទួលពី នួន ជា នោះគឺមានពាក្យពីរបីម៉ាត់តែប៉ុណ្ណោះខ្លីៗ។ តើត្រូវដែរឬទេ?

[០៩:២៤:២០]

**ផ៖** ជម្រាបប្រសាសន៍លោកប្រធាន ត្រឹមត្រូវ!

**ស៖** ឥឡូវនេះ ខ្ញុំនឹងដកស្រង់សេចក្តីពី D70-- 88 ឬ E3/61 ខ្មែរ 001955464 អង់គ្លេស 00195573 បារាំង 00195582 ដែលលោកនិយាយថាលោកប្រាប់សហចៅក្រមស៊ើបអង្កេតថា លោកមិនៗចាំទេពាក្យអក្សរខ្លីៗប៉ុន្មានម៉ាត់នោះ លោកមិនចាំថានិយាយបែបណាទេ តើអ៊ីចឹងដែរឬទេ?

**ផ៖** ជម្រាបប្រសាសន៍លោកប្រធាន ត្រឹមត្រូវហើយ! មានន័យថាខ្លឹមសារសំបុត្រដែលបង នួន គាត់សរសេរមកខ្ញុំ ខ្ញុំមិនចាំទេ។

**ស៖** អ៊ីចឹងគឺថាជាសំបុត្រដែលមានពាក្យខ្លីៗហ្នឹង។ បាទ តើត្រូវទេ? ប្រហែលជា៣០ឆ្នាំមកហើយ បើសិនជាខ្ញុំមិនច្រឡំទេ មុនពេលដែលលោកបានឃើញចំណាររបស់លោក នួន ជា ដែលជាចំណារដែលលោកអះអាងថាជារបស់លោក នួន ជា នៅលើចម្លើយសារភាពនោះ។ តើត្រូវដែរឬទេ?

**ផ៖** ជម្រាបប្រសាសន៍លោកប្រធាន។ ឥឡូវសូមកាត់ឃ្លាហ្នឹងឲ្យខ្លី។ ខ្ញុំវង្វេងហើយ។ សូមនិយាយអាខាងដើមបន្តិច។

[០៩:២៦:៥០]

**ស៖** ខ្ញុំៗចង់ព្យាយាមចង់ដឹងថាតើពេលប៉ុន្មានដែលនៅចន្លោះពេលដែលថាលោកទទួលសំបុត្រពី នួន ជា តើនៅស-២១ ហើយនិងខណៈពេលដែលលោកបានឃើញចំណាររបស់គាត់នៅលើចម្លើយសារភាពនៅក្នុងរឿងក្តីរបស់លោក ដែលលោកអះអាងថាជាចំណារសរសេរដោយ នួន ជា។ ថាតើចន្លោះពេលរវាងសំបុត្រដែលគាត់ផ្ញើមកលោកហ្នឹង រហូតដល់ពេលដែលលោកបានឃើញចំណារដែលលោកអះអាងថារបស់ នួន ជា ចន្លោះពេលប៉ុន្មានបាទ?

**ផ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំស្ថិតនៅក្រោមការគ្រប់គ្រងរបស់បង នួន យើងគិត

ត្រឹមតែឆ្នាំ១៩៧៨ ទៅចុះ រហូតមកដល់យើងគិតថាខែមីនា ឬក៏ខែមេសា តាមពិតប្រហែលជាខែមីនា ១៩៩៩ នេត ថាយ័រ នេះ វាបានឯកសារមួយដែលជាចម្លើយសារភាពរបស់ គង់ គៀន ហៅ វ៉េត, អ៊ឹង វ៉េត យកទៅបង្ហាញខ្ញុំ។ ក្នុងឯកសារនេះ វាមានទាំងចំណារខ្ញុំ វាមានទាំងចំណារ សុន សេន វាមានទាំងចំណារ បងនួន។ ដូច្នេះឃើញអក្សរ សុន សេន ខ្ញុំស្គាល់។ អក្សរខ្ញុំមិនបាច់និយាយទេ គ្រាន់ក្រឡេកស្គាល់ហើយ។ ដូច្នេះអក្សរ បងនួន តិចទេ ដូចនិយាយថា "ជូនទៅខាង៣៣ ហើយនិង៣៥" ប៉ុនទុំងឯងទេ។ ដូច្នេះដែនសមត្ថកិច្ចដែលគ្រប់គ្រងលើឯកសារនេះវាមានអ្នកណា? នៅពេលលើ សុន សេន មានតែ នួន ជា។ ហើយបង សុន សេន សរសេរទៀត "ជូនបង នួន ផ្ទាល់" នេះខ្ញុំតាមខ្ញុំចាំឯកសារនេះ។ ដូច្នេះវាបញ្ជាក់ថាៗហ្នឹងអក្សរ នួន ជា។ ដូច្នេះខ្ញុំឃើញចំណាររបស់ បងនួន ដំបូងគឺពេលទុំងឯងខែមីនា ចុងខែមីនា ឬដើមខែមេសា ១៩៩៩។ ឥឡូវយើងនាំគ្នាដកធ្វើលេខដកទៅ។ វាច្បាស់ហើយកាលបរិច្ឆេទ។ វា៩៩ ដក ៧៨ វា២២-- ២១ឆ្នាំ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ។

[០៩:២៩:៥៦]

**ស៖** ដូច្នេះចម្លើយរបស់លោកបើសិនជាខ្ញុំមិនខុសទេនោះ គឺថាលោកស្គាល់ចម្លើយ លោកស្គាល់អក្សរដែររបស់លោក នួន ជា នៅពេលដែល នេត ថាយ័រ បង្ហាញឲ្យលោកឃើញនូវឯកសារនោះ។ បាទ ដែលលោកថា លោកមិនដែលបានឃើញទេ រយៈពេល២១ឆ្នាំមកហើយ។ ហើយក៏លោកចង់បញ្ជាក់ថា សូម្បីតែខ្លឹមសារនៅក្នុងអាសំបុត្រខ្លីៗនោះ លោកមិនទាំងចាំផង តើអ៊ីចឹងមែនឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន។ ដោយសំណួរនេះមានបញ្ហាច្រើន ច្របូកច្របល់គ្នា ខ្ញុំសូមអនុញ្ញាតឆ្លើយតាមខយ៉ាៗដូចតទៅ៖

សំបុត្រដែល បងនួន សរសេរមកខ្ញុំ រវាងឆ្នាំ១៩៧៨ វាបញ្ហាមួយផ្សេងទៀត។ នេះដែលខ្ញុំឃើញអក្សរ បងនួន ផ្ទាល់នឹងភ្នែក នៅពេលដែលខ្ញុំក្រោមការគ្រប់គ្រងរបស់គាត់។ ផុតមួយរឿងហើយ រឿងទីពីរ គឺចម្លើយរបស់ គង់ គៀន ហៅ អ៊ឹង វ៉េត ដែលស-២១ ជូនទៅ បងខៀវ ដូចរវាងខែឧសភា ១៩-- ដែលបងរបស់ខ្ញុំ ស-២១ ជូនទៅ បងខៀវ សុន សេន។ ដល់ទៅ បងខៀវ គាត់អានហើយ គាត់ចារ "ជូន បងនួន ផ្ទាល់"។ ដូច្នេះ វាច្បាស់ណាស់ ឯកសារហ្នឹងសំដៅទៅលើបង នួន ជា។ ហើយទៅដល់ចំណារបង នួន ជា សរសេរពីបីម៉ាត់ទេ ជូន មិត្តម៉ុត ហើយ-- អឺ! អត់ទេ ជូននែ៎!តំបន់៣៣ សាមប៉ុន្មានទេ ៣៣, ៣៥ នេះអក្សរគាត់នៅខ្លីៗប៉ុណ្ណឹង។ នេះនៅក្នុងឯកសារនេះ។

[០៩:៣២:២៩]

**លោក វីល្លៀម ស្មីត៖**

ខ្ញុំអត់បាន ស្ដាប់បកប្រែអត់ឮទេ។ ជម្រាបសួរលោក លោកស្រីចៅក្រមដើម្បីប្រតិចារឹក គឺថា សាក្សី ឯកសារដែលសាក្សីយោង គឺ IS5.42។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ឌុច ខ្ញុំសូមសួរទៅលោកដែរថា លោកមិនអាចចាំអក្សរសរសេរដៃដោយ នួន ជា បានទេ ឬ? ប៉ុន្តែនៅពេលដែលលោកមើលកាលបរិច្ឆេទនៅលើឯកសារ ឬក៏កាលបរិច្ឆេទនៃចំណារផ្សេងៗហ្នឹង ហើយបើវាមិនមែនជាអក្សររបស់ សុន សេន ទេ ឬក៏អក្សររបស់លោកទេ គឺថាលោកសន្និត នោះលោក សន្និតតែម្ដង តើអ៊ីចឹងមែនទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតបនឹងសំណួរ ហើយចាំស្ដាប់នូវការសម្រេចរបស់តុលាការ ដោយសារ មានការជំទាស់តវ៉ាពីមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ សូមអញ្ជើញ!

[០៩:៣៣:៥២]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វ៖**

លោកប្រធាន។ ខ្ញុំគិតថានេះមិនមែនជាសំណួរទេ ក៏ប៉ុន្តែជាការសន្និដ្ឋានដែលសហភាតាររបស់ ខ្ញុំចង់ទាញយក។ ខ្ញុំគិតថា នេះវាមិនជាការសមស្របនោះទេ ដែលធ្វើការកត់សម្គាល់បែបនេះនៅក្នុង ដំណាក់កាលនេះ។ ដូច្នេះខ្ញុំសូមជំទាស់ទៅនឹងការអត្ថាធិប្បាយរបស់គាត់ ហើយខ្ញុំគិតថាអង្គជំនុំជម្រះ គួរតែរំឭកទៅគាត់ឲ្យគាត់ចោទសំណួរ ប៉ុន្តែមិនឲ្យគាត់ធ្វើការអត្ថាធិប្បាយនោះទេ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមអភ័យទោស។ ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម អស់ លោក លោកស្រីទាំងអស់ ទាំងក្នុងទាំងក្រៅបន្ទប់សវនាការ។ អ្វីដែលខ្ញុំចង់ឆ្លើយតបនោះ គឺបើសិនណា នេះជាជំហរដែលត្រូវប្រកាន់យកដោយមេធាវីខាងដើមបណ្ដឹងរដ្ឋប្បវេណី នោះ អ្ហ៎!នេះជាការសាកសួរ ដេញដោលបែបក្ដាស៊ីក។ ដូច្នេះ យើងខ្ញុំជឿជាក់ថា គឺជារឿងក្ដី ហើយជានីតិវិធីដែលគេបានប្រើប្រាស់ នៅ អាយ.ស៊ី.ធី.វ៉ាយ ហើយដែលមេធាវីការពាក្ដីត្រូវលើកករណីរបស់ខ្លួនមកសាកសួរដេញដោលទៅ

ដល់សាក្សី។ នេះគឺជាអ្វីដែលត្រូវបានច្រានចោលដោយអតីតចៅក្រមម្នាក់នៅ អាយ.ស៊ី.ធី.វ៉ាយ នៅក្នុងរឿងក្ដីរបស់ *មីឡូសេវិច*។ មិនអ្វីខុសឆ្គងនោះទេ ក្នុងការតាំងសំណួរ ពីព្រោះថាវាផ្ដល់ឱកាសឲ្យសាក្សីពន្យល់ ហើយថាតើសាក្សីទទួលយក ឬក៏បដិសេធ? នេះគឺជាវិធីដែលគេធ្វើការសាកសួរតទល់នៅក្នុងដំណើរការនៃការសាកសួរតទល់។ នេះគឺខ្ញុំសូមរំឮកទៅដល់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ហើយវិធីនេះគឺវាសមស្របបំផុតក្នុងការសាកសួរសំណួរក្នុងទម្រង់បែបនេះ។ ហើយបើការសម្រេចផ្សេងខុសនេះ នោះពិតជាមិនត្រឹមត្រូវនោះទេ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់ស្របជាមួយមេធាវីការពារក្ដី គឺនៅក្នុងរឿងក្ដី-- ហើយការតាំងសួរទៅនឹងសាក្សី កុំឲ្យតែបង្កឲ្យមានបញ្ហា។ ហើយមេធាវីការពារក្ដីត្រូវតែធ្វើម៉េចឲ្យវាមានទំនុកចិត្តនៅមានមូលដ្ឋានសមហេតុសមផល។ ហើយក្នុងនេះផងដែរ គឺថាដូចដែលមេធាវីការពារក្ដីរបស់ អៀង សារី បានលើកឡើងថានេះគឺជាការផ្ដល់ឱកាសឲ្យសាក្សីផ្ដល់ជាមតិយោបល់។ យើងអាចធ្វើដូច្នេះតែនៅក្នុងចុងបញ្ចប់នៃរឿងក្ដី ហើយនិងដើម្បីបង្កលក្ខណៈឲ្យអង្គជំនុំជម្រះថ្លឹងថ្លែងទៅដល់ភស្តុតាងនេះដោយផ្ទាល់តែម្ដង។

[០៩:៣៧:១៩]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីជាតិ-- អ៊ំ មេធាវីការពារក្ដីលោក ខៀវ សំផន!

**លោក អាកទូរ វែកគែន៖**

សូមអរគុណលោកប្រធាន។ បាទ ខ្ញុំចង់បញ្ជាក់ខ្លីថា ការនាំមុខទៅដល់សាក្សីនេះ គឺជាការអនុវត្តជាញឹកញាប់នៅចំពោះមុខតុលាការអន្តរជាតិនៅប្រទេសរវ៉ាន់ដា។ នេះគឺជារបៀបដែលធ្វើឲ្យសាក្សីឆ្លើយតប ឬក៏ធ្វើការសន្និដ្ឋាន។ ទោះបីជាថា ការសន្និដ្ឋាននោះ មិនធ្វើឲ្យភាគីទាំងអស់សប្បាយចិត្តយ៉ាងណាក៏ដោយ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

[០៩:៣៨:១៣]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំ-- យើងមិនមែននៅតុលាការយូហ្គោស្លាវីនោះទេ គឺថាយើងនៅកន្លែងយើងនេះ គឺថាយើងកំពុងតែសួរទៅសាក្សី។ ហើយអង្គជំនុំជម្រះទើបតែបានលើកឡើងកាលពីប៉ុន្មានថ្ងៃមុននេះ អ្នកស្រី ខាតវ៉ាយថ៍ បាននិយាយថា-- លើកឡើងពីបញ្ហានេះ ហើយខ្ញុំមិនមែនជំទាស់ទៅនឹងការអត្ថាធិប្បាយរបស់សាក្សីទេ ប៉ុន្តែទៅខាងភាគីការពារក្តី។ ហើយដោយខ្ញុំយល់ឃើញថា គាត់មិនមែនចោទសំណួរ គឺថាគាត់ធ្វើការអត្ថាធិប្បាយ។ ហើយខ្ញុំសង្កេតឃើញថា នៅពេលដែលខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺពេលដែលធ្វើការអត្ថាធិប្បាយ ខាងភាគីការពារក្តីជំទាស់រហូត។ ហើយអ៊ីចឹង នៅពេលដែលអង្គជំនុំជម្រះចេញសេចក្តីសម្រេចហើយ កាលនោះ ចៅក្រម ខាតវ៉ាយថ៍ បានចេញសេចក្តីសម្រេច។ អ៊ីចឹង សូមឲ្យគោរពសេចក្តីសម្រេចនេះទាំងអស់គ្នា។

**ប្រធានអង្គជំនុំ៖**

លោក ម៉ៃខល ផេសមិន មានអីតបទៅនឹងការជំទាស់នេះដែរឬទេ?

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំសង្ឃឹមថា នៅចុងបញ្ចប់នៃថ្ងៃនេះ ខ្ញុំនឹងទទួលបាននូវម៉ោងបន្ថែម ពីព្រោះគឺថាម៉ោងរបស់ខ្ញុំត្រូវបានគេប្រើប្រាស់ច្រើនណាស់។

[០៩:៣៩:៣០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះនឹងមិនបន្ថែមឲ្យទេ ពីព្រោះលោកសុំតែ១៥នាទីទេ កាលដើមឡើយ។ ហើយចុងក្រោយ លោកសុំបន្ថែមមួយម៉ោង យើងគិតថា៤៥នាទីបូកជាមួយនឹងការរំខានពីម្សិលមិញ ហើយទំនងជាការរំខាននៅថ្ងៃនេះផងដែរ។ បើពុំដូច្នេះទេ យើងនឹងសម្រេចកែប្រែវិញ យើងឲ្យតែ១៥*មីនុត*ពីម្សិលមិញ ហើយសល់ប៉ុន្មានយើងទូទាត់គ្នានៅថ្ងៃនេះ។ យើងនឹងកត់ត្រាម៉ោងឲ្យបានត្រឹមត្រូវបំផុត មើលនៅម៉ោងតវ៉ាជំទាស់នេះ។ ទំនងជាយើងនឹងខិតខំដើម្បីកំហិតពេលវេលា ឲ្យបានជាក់ច្បាស់នៅក្នុងកិច្ចដំណើរការដេញដោលចាប់ពីនេះទៅ គឺយើងនឹងខិតខំឲ្យអស់ពីលទ្ធភាពក្នុងការកំណត់ កំហិតនូវពេលវេលាក្នុងការដេញដោលនេះ។

[០៩:៤០:២១]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤២:២២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះ សម្រេចលើការតវ៉ាជំទាស់របស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការតាំងសំណួរចុងក្រោយរបស់មេធាវីខ្លួន ជា ចំពោះសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច គឺការជំទាស់ហ្នឹង គ្មានប្រសិទ្ធភាព។ ជន-- សាក្សីត្រូវឆ្លើយតបនឹងសំណួរនេះ ប៉ុន្តែមុននឹងបន្តទៀត អង្គជំនុំជម្រះសូមជម្រាបភាគីនៃរឿងក្តីថានៅ អ.វ.ត.ក យើងនេះ អង្គជំនុំជម្រះនឹងមិនអនុវត្តនូវនីតិវិធីនៃការសួរតទល់ តាមវិធាននៃការតទល់គ្នានៅ-- ដែលអនុវត្តនៅតុលាការអន្តរជាតិ អាយ.ស៊ី.ធី.អ៊រ និង អាយ.ស៊ី.ធី.វ៉ាយ ឡើយ។ អ៊ីចឹង ចែកគ្នាឲ្យដាច់រវាងសំណួរអម្បាញ់មិញនេះ ដែលអនុញ្ញាតឲ្យឆ្លើយតប ប៉ុន្តែវិធានដែលអនុវត្តនៅតុលាការអន្តរជាតិ អាយ.ស៊ី.ធី.អ៊រ និង អាយ.ស៊ី.ធី.វ៉ាយ នោះមិនត្រូវយកមកអនុវត្តនៅតុលាការនេះទេ។

[០៩:៤៣:៤០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៣:៥៨]

**ប្រធានអង្គជំនុំ៖**

ហើយសូមរំឭកដល់ភាគីផងដែរ ជាពិសេសលោកមេធាវីការពារក្តី ម៉ែខល ផេសមិន សូមរៀបចំនូវការតាំងសំណួរសាមញ្ញៗ ងាយយល់ ដើម្បីអាចមានលទ្ធភាពក្នុងការឆ្លើយតបបាន។ អាចទំនងជាប្រជាពលរដ្ឋខ្មែរកម្រិតយល់ដឹងអំពីកម្រិតវប្បធម៌ទូទៅចំពោះអ្នកជំនាន់មុន ប្រហែលជាមានកម្រិត មិនទំនងដូចជាបណ្តាប្រទេសជឿនលឿននៅលើពិភពលោកទេ។ អ៊ីចឹង ការតាំងសំណួរឯណាដែលវែងដែលមានលក្ខណៈស៊ីជម្រៅហួសហេតុនោះ ទំនងជាកម្រិតនៃការយល់ដឹងរបស់សាក្សីដែលនឹងផ្តល់សក្ខីកម្មនៅទីនេះ អាចហួសពីសមត្ថភាពដែលគាត់អាចស្តាប់បាននិងយល់បាន។

[០៩:៤៤:៣៦]

ដូច្នេះការស្វែងរកការពិតមិនមែនចាំបាច់ត្រូវតែសួរ តាំងសំណួរស៊ីជម្រៅរហូតដល់សាក្សីឆ្លើយមិនរួចទើបមានន័យថា “រកយុត្តិធម៌-- ស្វែងរកយុត្តិធម៌” បាននោះឡើយ។ សំខាន់គឺអាចផ្តល់សក្ខីកម្មនិងបាននិយាយការពិតដែលគាត់បានដឹងប្រាប់ដល់អង្គជំនុំជម្រះ។ នោះជាការត្រឹមត្រូវហើយក្នុងការ

ស្វែងរកការពិត។ ទំនងជាសាក្សីអាចភ្លេចនូវសំណួរដែលលោកសួរ អ៊ីចឹងលោក ម៉ៃខល ផេសមិន អាចតាំងសំណួរ រំឭកសំណួរចុងក្រោយរបស់លោកឡើងវិញ ដើម្បីឲ្យសាក្សីឆ្លើយតប។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ឌុច លោកចង់ឲ្យខ្ញុំសួរឡើងវិញឬ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន មេធាវីគប្បីស្តាប់បញ្ជាតុលាការ។

[០៩:៤៥:៤៣]

**ស៖** បាទអ៊ីចឹង ខ្ញុំសូមអានសំណួរឡើងវិញ ឌុច ដើម្បីឲ្យងាយស្រួលស្តាប់ ខ្ញុំមិនជឿថា លោកអាចចងចាំអក្សរសរសេរដោយផ្ទាល់ដៃរបស់ នួន ជា បានទេ។ ខ្ញុំជឿជាក់ថា លោកគ្រាន់តែសន្មតថា នេះគឺជាអក្សរដៃរបស់លោក នួន ជា ដោយសំអាងទៅលើកាលបរិច្ឆេទ និងសំអាងទៅលើចំណារនោះ។ តើនេះជារឿងអ៊ីចឹងមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសន្និដ្ឋាន ឬក៏អះអាង វាឈរលើមូលដ្ឋានច្រើន។ ទីមួយ អ្នកដែលមានកាតព្វកិច្ចចារនៅលើឯកសារស-២១ បាន មានតែ សុន សេន, នួន ជា ហើយនិង ប៉ុល ពត ក្រៅពីនោះគ្មានអ្នកណាចារលើឯកសារស-២១ បានទេ។ នេះជាសមត្ថកិច្ចរបស់ខាងលើដែលនៅគ្រប់គ្រងខ្ញុំ។ មិនអាចអ្នកណាល្មើសសមត្ថកិច្ចនេះបានទេ។ ទីពីរ នៅឯកសារដែលខ្ញុំរំឭកឡើងវិញនោះគឺឯកសារចម្លើយសារភាពរបស់ឈ្មោះ គង់ គៀន ដែលលោកមេធាវីជួយឲ្យលេខកូដនោះ។ បើ សុន សេន គាត់សរសេរថា “ជូនបងនួន ផ្ទាល់ហើយ” អានេះវាភស្តុតាងមួយទៀតហើយ។ នេះជាបញ្ហាទីពីរ។

[០៩:៤៧:៤៣]

បញ្ហាទីបី អក្សរបងនួន ពីរបីម៉ាត់ទេ។ ខ្ញុំមិនមែនវង្វេងស្មោះ ឬក៏មិនប៊ានអះអាងក្នុងឋានៈជាអ្នកបច្ចេកទេសតាមដានវិភាគអក្សរ ទម្រង់អក្សរដៃរ។ ក៏ប៉ុន្តែដល់ខ្ញុំធ្លាប់ឃើញខ្លះ សមត្ថកិច្ចរួមផ្សំហើយពាក្យដែល បងខៀវ គាត់សរសេរទៀត វាធ្វើឲ្យខ្ញុំអាចប៊ាននិយាយថា ក្នុងឯកសារនោះជាចំណាររបស់ បងនួន នេះខ្ញុំនិយាយពីចំណារនៅលើឯកសាររបស់ឈ្មោះ គង់ គៀន។ នេះខ្ញុំសូមបញ្ចប់ប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ ប៉ុន្មាននាទីមុននេះ ពេលលោកឆ្លើយទៅនឹងសំណួរមួយរបស់ខ្ញុំ គឺថាលោក

ឆ្លើយថា “ខ្ញុំស្ថិតនៅក្រោមការគ្រប់គ្រងរបស់ នួន ជា ពីឆ្នាំ៧៨ ដល់៧៩”។ នៅពេលណាជាក់លាក់ដែលលោកស្ថិតនៅក្រោមការគ្រប់គ្រងរបស់ នួន ជា នៅក្នុងឆ្នាំ១៩៧៨ នោះ?

[០៩:៤៩:១០]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមបញ្ជាក់ថា ខ្ញុំស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ បងនួន ចាប់តាំងពីថ្ងៃ១៥ សីហា ១៩៧៧។ ខ្ញុំអធិប្បាយជូនតុលាការអំមិញ គួរណាស់តែលោកមេធាវីយល់ហើយ។ យើងនិយាយអំពីសំបុត្រប៉ុន្មានច្បាប់ដែល បងនួន គាត់សរសេរផ្ញើមកខ្ញុំ។ ដូច្នេះខ្ញុំគិតថាហើយ គិតត្រឹមពី៧៨មក ដើម្បីស្រួលគិតលេខ តាមសំណួររបស់លោកដែលឲ្យខ្ញុំគិតរយៈកាលវេលា ដែលខ្ញុំសំបុត្ររបស់ បងនួន មួយរយៈកាលដែលខ្ញុំឃើញ នែ៎ ចំណាររបស់ នែ៎ បងនួន នៅលើឯកសារដែល នេត ថាយ័រ វាយកទៅបង្ហាញខ្ញុំ។ ដូច្នេះអត់មានច្របូកច្របល់ទេ ស្រពេចស្រពិលទេ។ រយៈកាលដែលខ្ញុំស្ថិតនៅក្រោមការគ្រប់គ្រងរបស់បងនួន គឺចាប់តាំងពីថ្ងៃ៨ សីហា ១៩៧៧។ ក្នុងរយៈកាលនុ៎ង សំបុត្រដែលខ្ញុំបានទទួលពីបងនួន ប្រហែលជាក្នុងឆ្នាំ១៩៧៨ សំបុត្របីបួនច្បាប់ប៉ុននុ៎ងទេ។ បួន-- ច្បាស់ជាបួនច្បាប់។ ដូច្នេះវាអត់មានអីខ្ញុំទៅបន្លំកាលបរិច្ឆេទទេ។ សូមបញ្ជាក់បញ្ហានេះច្បាស់។

**ស៖** នៅថ្ងៃទី២០ ខែមីនា ២០១២ លោកបានជម្រាបទៅចៅក្រមថា សុន សេន ត្រូវបានបញ្ជូនទៅអ្នកលឿង នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៨ ហើយកាលបរិច្ឆេទនេះមិនបានបកប្រែ-- បកប្រែខុសជាភាសាអង់គ្លេសទៅដាក់ថា ថ្ងៃទី១៨ ខែមេសា ទៅវិញ។ ឌុច តើវាត្រឹមត្រូវទេ ដែល សុន សេន គឺត្រូវបានបញ្ជូនទៅអ្នកលឿង នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៨?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន សូមលោកមេធាវី កាត់មួយកំណាត់ខាងដើមរបស់លោកចេញ ដើម្បីឲ្យបញ្ហាវាសួរទៅច្បាស់។ ខ្ញុំសូមនិយាយឆ្លើយតែមួយកំណាត់ខាងចុងទេ។ មួយកំណាត់ខាងចុងគឺលោកសួរខ្ញុំ ថាតើ សុន សេន ពិតជាទៅអ្នកលឿងនៅថ្ងៃ១៥ ខែសីហា ១៩៧៨មែន-- អ៎!៧៧ មែនឬអី។ ពិតជាមែន!

[០៩:៥២:០០]

**ស៖** នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០២ លោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេតនៃតុលាការយោធានៅភ្នំពេញ គឺឯកសារ ខ្ញុំនិយាយអំពីឯកសារទីពីរ ក្នុងចំណោមឯកសារប្រាំពីរ ដែលមានលេខ D288/6.15.041 លេខ ERN ជាភាសាខ្មែរ 00320808 អង់គ្លេស 00327353 ខ្ញុំរកលេខ ERN

មិនឃើញទេ។ លោកបាន-- លោកចាំទេនៅពេលលោកផ្តល់ចម្លើយនៅមុខតុលាការឃោធា?

លោកចង់ឲ្យខ្ញុំសួរសំណួរឡើងវិញឬ?

**ឆ៖** លោកសួរថាម៉េចអំមិញ? ខ្ញុំឮតែលោកអធិប្បាយពីរឿងថ្ងៃណា ខែណា។ ខ្ញុំទៅចាំដល់ថ្ងៃយ៉ាងម៉េច? ឥឡូវបញ្ចាំងមក! នៅលើអេក្រង់នេះ ហើយនិងឲ្យឯកសារក្រដាសមកខ្ញុំមក។ រឿងតាំងពីនៅតុលាការឃោធានោះ។

**ស៖** ខ្ញុំសូមអាន សូមដកស្រង់សម្តីរបស់លោកនូវកាលបរិច្ឆេទដែលលោកបានចោទប្រកាន់ទៅលើ នួន ជា ថា គ្រប់គ្រងមកលើលោកនៅស-២១។ ខ្ញុំសូមដកស្រង់សម្តី "នៅពេល ណាត ជាប្រធាន ប៉ង់ និង លីន ក៏បានមកស-២១ ម្តង ឬពីរដងតែប៉ុណ្ណោះ។ ប៉ុន្តែនៅពេល ណាត ចាកចេញទៅ ប៉ង់ និង លីន បានមកស-២១ ជាញឹកញាប់។ ជាពិសេសបន្ទាប់ពី នួន ជា បានមកគ្រប់គ្រងស-២១ ដោយផ្ទាល់។ ហើយអ្នកទាំងពីរនេះអាចទៅណាក៏បាន។ នៅថ្ងៃទី១៥ ខែកក្កដា ៧៧ នួន ជា បានមកស-២១"។ នេះគឺអ្វីដែលលោកបានប្រាប់ទៅសហចៅក្រមស៊ើបអង្កេត។ តើលោកចាំទេ?

**លោក វីល្លៀម ស្មីត៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

*(និយាយមិនបើកក្បាលមីក្រូហ្វូន)*

[០៩:៥៥:១២]

**ប្រធានអង្គជំនុំ៖**

លោកនិយាយបើកក្បាលមីក្រូផង អត់បើក្បាលមីក្រូភាគីផ្សេងទៀត អត់បានស្តាប់ឮទេ អ្នកបកប្រែអត់មានការបកប្រែដែរ។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមឲ្យបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ ហើយបើសាក្សីត្រូវការឯកសារក្រដាសនេះ ក៏សូមជូនដល់គាត់ដែរ ដោយសារតែសាក្សីរូបនេះ គឺថាបានផ្តល់ចម្លើយរយ:ពេលប្រហែលជា៣០០ម៉ោងឯណោះ។ ដូច្នេះ ខ្ញុំសូមពិនិត្យឲ្យមើលថា វាមានសុក្រឹតភាព ឬក៏

យ៉ាងណា ដើម្បីឲ្យសាក្សីអាចមានលទ្ធភាពពិនិត្យមើលឯកសារ។ ដូចមិនមានហេតុផលណាមួយ ដែលថាដាក់ឲ្យគាត់ឋិតក្នុងស្ថានភាពមួយ ដែលមិនអាចឆ្លើយបាននោះទេ។

**លោក ម៉ៃខល ផេសមិន៖**

លោក លោកស្រីចៅក្រម ខ្ញុំសូមឆ្លើយតបទៅនេះ គឺថាខ្ញុំចង់រំឭកការចងចាំឡើងវិញ។ ប៉ុន្តែខ្ញុំចង់ឲ្យគាត់ឆ្លើយទៅនឹងសំណួររបស់គាត់ជាមុនសិន ថាតើ ឌុច គាត់ចាំនូវអ្វីដែលគាត់បានឆ្លើយទៅសហចៅក្រមស៊ើបអង្កេតដែរឬក៏អត់នោះ។ ហើយបន្ទាប់មក ខ្ញុំនឹងឲ្យឯកសារជាក្រដាសទៅឲ្យគាត់។

[០៩:៥៦:៣៣]

**លោក វីណ្ស៉ៀម ស្មីត៖**

ទាក់ទងទៅនឹងចំណុចនេះគឺមេធាវីការពារក្ដី គឺយកឯកសារជា បកប្រែជាភាសាអង់គ្លេសមកប្រើប្រាស់នេះ ហើយសាក្សីរូបនេះគឺថា គាត់ចង់-- ចង់ឲ្យសាក្សីរូបនេះឆ្លើយឲ្យបានត្រឹមត្រូវ។ អ៊ីចឹងគាត់ត្រូវមើលឯកសារជាភាសារបស់គាត់ផ្ទាល់។ ដូច្នេះ មិនត្រូវយកឯកសារ ដែលបកប្រែជាភាសាអង់គ្លេសនោះទេ។

**ប្រធានអង្គជំនុំ៖**

ការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញា ត្រឹមត្រូវ។ ដូច្នេះ មុននឹងដេញដោលឯកសារនេះ មេធាវីអន្តរជាតិការពារក្ដី នួន ជា ផ្ដល់ឯកសារជាភាសាខ្មែរ ឲ្យដល់សាក្សីជាឯកសារជាក្រដាស។ ហើយនិងបញ្ចាំងឯកសារនោះនៅលើអេក្រង់ទូរទស្សន៍ផង។

ដើម្បីជាប្រតិចារឹក លោកមេធាវីសូមបង្ហាញនូវអត្តសញ្ញាណឯកសារ ដែលដាក់ឲ្យទៅសាក្សីពិនិត្យដែលលោកប៉ុនប៉ងក្នុងការដេញដោល ពាក់ព័ន្ធនឹងឯកសារនេះផង ដើម្បីឲ្យមានការកំណត់ត្រាត្រឹមត្រូវ។

[០៩:៥៩:០១]

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំបានផ្ដល់លេខឯកសារជូនហើយ ខ្ញុំជឿថា ERN ជាភាសាខ្មែរ ហើយនិងលេខឯកសារ D ផងដែរ នេះគឺលេខឯកសារ ខ្ញុំបានផ្ដល់ជូនជាចុងក្រោយនេះ។

**ប្រធានអង្គជំនុំ៖**

លោកបញ្ជាក់ឡើងវិញ! រំឭកឡើងវិញឲ្យច្បាស់លាស់មក!

**លោក ម៉ៃខល ផេសមិន៖**

ERN ជាភាសាអង់គ្លេស 00327353 ហើយលេខ ERN ជាភាសាខ្មែរ 00320808 ទៅដល់ 09។ មន្ត្រីគ្រប់គ្រងសំណុំរឿងរបស់ខ្ញុំ កំពុងតែដាក់ឯកសារទៅលើអេក្រង់កុំព្យូទ័រ តើលោកប្រធានអនុញ្ញាតឱ្យខ្ញុំបង្ហាញនៅលើអេក្រង់ទេ។

**ប្រធានអង្គជំនុំ៖**

អំមិញយើងបានបង្គាប់រួចហើយ ឱ្យបុគ្គលិកជំនួយការបង្ហាញឯកសារនៅលើអេក្រង់ទូរទស្សន៍។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ឌុច តើលោកអាចកត់សម្គាល់ ឬក៏ចំណាំបាននូវឯកសារដែលបង្ហាញនេះ លោកបាននៅលោកអាចចាំឯកសារនេះបានទេ?

លោក ឌុច តើលោកអាចបញ្ជាក់ជូនតុលាការបានទេថា អត្ថបទនេះគឺជាអត្ថបទដែលមានខ្លឹមសារត្រឹមត្រូវ? បាទថាការបកប្រែទៅហ្នឹងគឺ ត្រឹមត្រូវជាភាសាខ្មែរហ្នឹងដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន អត្ថបទនេះការបកប្រែអំមិញត្រឹមត្រូវហើយ។

[១០:០២:១៩]

**ស៖** សូមអរគុណ។ តើ នួន ជា ធ្លាប់ទៅ ស-២១ ដែរឬទេ ដូចដែលលោកប្រាប់ទៅតុលាការយោធានោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន និយាយពី នួន ជា ទៅស-២១ ជារឿងដែលធ្វើឱ្យខ្ញុំភ្ញាក់ផ្អើល។ បង នួន មិនដែលទៅដល់ ស-២១ ទេ។ បង ខៀវ ទៅប្អូនដង។ ហើយដល់មានកាលបរិច្ឆេទច្បាស់លាស់អ៊ីចឹងធ្វើឱ្យខ្ញុំភ្ញាក់ផ្អើល។

**ស៖** តើ នួន ជា បានទទួលបន្ទុកលើស-២១ ទេ នៅថ្ងៃទី១៥ កក្កដា ១៩៧៧?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ថ្ងៃ១៥ សីហា ១៩៧៧ តាំងពីពេលនោះមក នួន ជា ទទួលបន្ទុកផ្ទាល់ជួបខ្ញុំ ហៅខ្ញុំទៅជួបធ្វើការដោយផ្ទាល់។ ពីលើកមុនមក គាត់នៅតែពីលើ សុន សេន ទេ។

**ស៖** សូមអរគុណ។ ខ្ញុំសូមយោងទៅរកឯកសារមួយទៀតលេខ IS20.20 ខ្មែរ ERN 00072210 អង់គ្លេស ERN 00002623 បារាំង ERN 00324725 ជាបទសម្ភាសន៍ដោយ នេត ថាយ័រ ដែលលោកបាននិយាយខាងដើមនោះដែរ ដែលគាត់តំណាងឱ្យសារព័ត៌មាន *ហ្វា អ៊ីសស្ទើន*

*អេខូណូមិក រីវ្យូ* ដែលនៅក្នុងបទសម្ភាសន៍នោះ លោកបានដកស្រង់ដោយនិយាយដូចខាងក្រោមនេះ បាទ។ ហើយខ្ញុំដកស្រង់សម្ដីលោក ដែលលោកនិយាយនោះទៅទៀត គឺមិនបានបកប្រែទេ គឺជាភាសាដើម លោកបាន លោកប្រាប់ នេត ថាយ័រ ថាតាមបទសម្ភាសន៍នោះ "បន្ទាប់ពីរំដោះមកនៅឆ្នាំ១៩៧៥ ខ្ញុំរាយការណ៍ជូន ផ្ទាល់ទៅ សុន សេន នៅខែកក្កដា ឆ្នាំ១៩៧៨ ខ្ញុំបានប្ដូរទៅនួន ជានៅពេលដែល សុន សេន បានចេញទៅបញ្ជាការនៅភូមិភាគបូព៌ាជាមួយវៀតណាម"។ កាលបរិច្ឆេទនោះ គឺឆ្នាំ១៩៧៨ហ្នឹង គឺបញ្ជាក់ពីរដងនៅក្នុងចំណុចនោះ។ តើលោកនៅចាំទេ? ចាំថាលោកបាននិយាយពីរឿងនេះប្រាប់ទៅ នេត ថាយ័រ នោះ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

សាក្សីកុំអាលឆ្លើយ-- ទាន់ឆ្លើយ ពីព្រោះមានបញ្ហាតវ៉ា។

[១០:០៦:១០]

**លោក វីណ្ស៉េម ស្មីត៖**

តំណាងសហព្រះរាជអាជ្ញា សូមអរគុណលោកប្រធាន។ បើសិនជា មេធាវីផ្ដល់ឯកសារលើក្រដាសជូនសាក្សីជាការល្អ ពីព្រោះថាបើមិនដូច្នេះ គាត់មិនអាចអានច្បាស់លាស់ ហើយលើកលែងតែផ្ដល់លើក្រដាស បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ មេធាវីសូមផ្ដល់ឯកសារអម្បាញ់មិញនេះជាក្រដាសមកសាក្សីពិនិត្យ!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងអនុវត្តតាម។ បាទ សូមមន្ត្រីតុលាការមេត្តាជួយ ខ្ញុំមានអត្ថបទបកប្រែពីអង់គ្លេសមកជាភាសាខ្មែរ ហើយខ្ញុំជឿថា អត្ថបទនេះបានបង្ហាញនៅលើអេក្រង់ហើយ ហើយសូមគោរពតាមតុលាការ ខ្ញុំជូនអត្ថបទជាភាសាខ្មែរដែលបកពីអង់គ្លេសនេះជូនទៅលោកសាក្សី បាទ។

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន។ នេត ថាយ័រ ខ្ញុំបានជម្រាបតុលាការប៉ុន្មានថ្ងៃមុនរួចហើយ។ ខ្ញុំនិយាយតែមួយម៉ាត់ជាមួយវាទេ ហើយវាយកទៅអត្ថាធិប្បាយមួយកំភ្លួសពីរកំភ្លួស។ ដូច្នេះ កាលបរិច្ឆេទនៅក្នុងនេះមិនត្រឹមត្រូវទេ។ កាលបរិច្ឆេទដែល នេត ថាយ័រ និយាយមិនត្រឹមត្រូវទេ។

[១០:០៨:២២]

**ស៖** លោកដឹងថា តើលោកដឹងទេថា បទសម្ភាសន៍នោះគេបានថតជាខ្សែអាត់នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន។ នៅពេលដែល នេត ថាយ័រ វាទៅជួបខ្ញុំ ខ្ញុំអត់ឃើញមានម៉ាស៊ីនថតខ្សែអាត់ទេ។ នីក ដងឡុប វាមានម៉ាស៊ីនថតរូប ឯ នេត ថាយ័រ ដៃទទេទេ។ មានថតខ្សែអាត់ តែ គ្រីស្ទ ប៉េស៊ូ ទេ។ ហើយអា នេត ថាយ័រ នេះវាទៅឡេមឡឺមៗក្បែរ គ្រីស្ទ ប៉េស៊ូ ហ្នឹង។ វាមានខ្សែអាត់ឯណា។

**ស៖** លោកបញ្ជាក់ថា គ្រីស្ទ ប៉េស៊ូ ហើយលោកក៏បានប្រាប់ ប៉េស៊ូ នោះផងដែរ ហើយ គាត់បានសម្ភាសលោក ហើយមានកំណត់ត្រា ហើយគាត់ក៏បានដកស្រង់សម្តីលោកនិយាយថា នួន ជា បានទទួលតំណែងតហ្នឹង ឆ្នាំ១៩៧៨ ទេ មិនមែន១៩៧៧ នោះទេ។ តើលោកចាំថា លោកបានប្រាប់ ប៉េស៊ូ ថា នួន ជា មកស្នងបន្តនោះ គឺ១៩៧៨ តើលោកនៅចាំថាប្រាប់គាត់ អ៊ីចឹងទេ?

**លោក វីល្លៀម ស្មីត៖**

សូមអនុញ្ញាតតុលាការបង្គាប់ឲ្យមេធាវីជូនឯកសារលើក្រដាសជូនលោកសាក្សីផង កន្លែងដែលដកស្រង់នេះ។

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំកត់សម្គាល់ថាសហព្រះរាជអាជ្ញា ហើយនិងៗសាក្សីតែស្នើសុំឲ្យបង្ហាញឯកសារ នៅពេលដែលសម្តី ឌុច ហើយនិងកំណត់ហេតុនោះ វាផ្ទុយគ្នា។

**លោក វីល្លៀម ស្មីត៖**

មិនមែនដូច្នេះទេ គឺថាជាទូទៅ គឺយើងត្រូវផ្តល់ឯកសារលើក្រដាសជូនសាក្សីគ្រប់ពេលទាំងអស់ដែលមេធាវីថាបែបនោះ គឺមិនត្រឹមត្រូវទេ។ ថាកាលណាសម្តីខ្ញែងនឹងចម្លើយ ថាយើងខ្ញុំតែងតែជំទាស់ដូច្នេះត្រឹមត្រូវទេ។

**លោក ម៉ៃខល ផេសមិន៖**

ឥឡូវនេះ ខ្ញុំមាន--

[១០:១០:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ ការកត់សម្គាល់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិត្រឹមត្រូវ! ដូច្នេះចាប់ពីនេះទៅ

ឲ្យជាក់ច្បាស់ ភាគីដែលមានបំណងដាក់ឯកសារណាមួយក៏ដោយ ក្នុងពេលវេលាណាក៏ដោយ ទោះបីជាឯកសារនោះ ជាការគាំទ្រនឹងបញ្ជាក់ទៅលើឯកសារដែលដេញដោលពីមុនៗក៏ដោយ ត្រូវរៀបចំតាមបែបមួយ គឺផ្តល់ឯកសារជាក្រដាសឲ្យទៅសាក្សី ហើយនិងដាក់បង្ហាញនៅលើអេក្រង់កុំព្យូទ័រ ដើម្បីឲ្យកិច្ចដំណើរការនេះ គឺបានរលូនទៅអ៊ីចឹងគ្រប់ពេល។ ហើយដោយឡែក គឺបុគ្គលិកជំនួយការរបស់មេធាវី ឬក៏របស់ភាគី ដែលផ្តល់ឯកសារដើម្បីលើកយកមកដេញដោលនៅចំពោះមុខអង្គជំនុំជម្រះគ្នា គឺយើងអនុញ្ញាតឲ្យដាក់បញ្ចាំងឯកសារនោះតែម្តង នៅពេលណាដែលសំណើសុំរបស់មេធាវីមានបំណងដាក់ឯកសារនោះដេញដោលចំពោះមុខសាក្សី ឬក៏មុខសញ្ញាគោលដៅដទៃទៀត ដែលមានបំណងដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ។

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីមេធាវីយកជូនសាក្សីពិនិត្យ! ហើយមុននឹងបុគ្គលិកជំនួយការមេធាវីដាក់ឯកសារបញ្ចាំងលើអេក្រង់កុំព្យូទ័រ។

[១០:១២:២៨]

**សួរដោយលោក ម៉ៃខល ផេសមិនៈ**

**សៈ** ខ្មែរ ERN នៅលើទំព័រនេះ គឺ 00160879 អង់គ្លេស ERN គឺ 0018505។ សូមលោកអានអត្ថបទនៅត្រង់កន្លែងនេះបាទ។ នៅក្នុងប្រអប់ពណ៌ក្រហម នៅត្រង់ចំណុចលេខ៦។

**លោក កាំង ហ្គេកអ៊ាវៈ**

**ឆៈ** ជម្រាបប្រសាសន៍លោកប្រធាន។ ខ្ញុំសូមអានដូចតទៅ៖ “ក្នុងឆ្នាំ១៩៧៨ គាត់ត្រូវបានគេបញ្ជូនទៅសមរភូមិមុខ នៅបូព៌ា ហើយនួន ជា ក៏មកជំនួសគាត់ ហើយគឺជាមេ។ អ្នកគ្រប់គ្រងខ្ញុំ ហើយខ្ញុំបានផ្ញើចម្លើយសារភាពទៅជូនគាត់”។ ហ្នឹង ខ្ញុំសូមបញ្ចប់ការអានប៉ុណ្ណេះ។

**សៈ** ឌុច តើលោកនៅចាំទេ គឺពីរថ្ងៃកន្លងទៅនេះ នៅពេលដែលខ្ញុំចាប់ផ្តើមសួរសំណួរទៅលោកមួយចំនួននោះ ខ្ញុំសួរថាតើលោកធ្លាប់បានបញ្ជាក់ថា ថ្ងៃទី១៥ សីហា ឆ្នាំ១៩៧៧ ត្រូវដែរឬទេ? ហើយលោកឆ្លើយថា អ៊ឺ! ខ្ញុំតែងតែឆ្លើយត្រូវ ចាំត្រូវ ជានិច្ច។ តើលោកនៅចាំពាក្យហ្នឹងទេ?

**ឆៈ** សូមលោកប្រធានបញ្ជាឲ្យលោកមេធាវីសំណួរនេះម្តងទៀត។ ១៧ សីហា ឯណាស្អី--

[១០:១៤:៤៨]

**ប្រធានអង្គជំនុំៈ**

លោកមេធាវីរៀបចំសំណួរចុងក្រោយនេះ ម្តងទៀត ដើម្បីឲ្យសាក្សីងាយស្តាប់ ហើយនិងយល់

បាន នូវខ្លឹមសារ និងគោលបំណងនៃការសួរ ដើម្បីអាចឆ្លើយតបនឹងសំណួររបស់លោកបានត្រឹមត្រូវ។

**សួរដោយលោក ម៉ៃខល ផេសមិនៈ**

**ស៖** ឌុច ពីរថ្ងៃកន្លងទៅនេះ ខ្ញុំបានសួរលោកថា ថាតើអាចទៅរួចទេ ដែលលោកអាចច្រឡំខុស អំពីកាលបរិច្ឆេទហ្នឹងខុស? គឺខ្ញុំនិយាយថា គឺថ្ងៃ១៥ សីហា ១៩៧៧ ថាតើលោកធ្លាប់ច្រឡំទេកាល បរិច្ឆេទនោះ? ហើយលោកឆ្លើយថា អ្ហឺ! ខ្ញុំមិនដែលច្រឡំទេ។ ខ្ញុំប្រាកដណាស់ថ្ងៃខែឆ្នាំហ្នឹង។ តើលោក ចាំថា លោកនិយាយបែបហ្នឹងទេ?

[១០:១៥:៤៦]

**លោក កាំង ហ្កេកអ៊ាវៈ**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន រឿងជួប បងនួន ចាប់ផ្តើមពីថ្ងៃ១៥ សីហា ១៩៧៧ គ្មាន ថ្ងៃណាផ្សេងទៀតទេ ខ្ញុំអត់និយាយជាមួយអ្នកណាពីថ្ងៃឯណាផ្សេងទៀតទេ។ ច្បាស់ណាស់ គឺថ្ងៃ១៥ សីហា ១៩៧៧ អត់ប្រកែកទេ។ រួចម៉្ងៃនោះអ្នកណាសួរ ដូចជា ព្រះរាជអាជ្ញាសួរថាម៉េចក៏ចាំ? ខ្ញុំថា សុន សេន តូចជាង នួន ជា ឡើងពីជួបអ្នកតូចទៅជួបអ្នកធំ ធ្វើឲ្យខ្ញុំចាប់អារម្មណ៍ អ៊ីចឹងហើយខ្ញុំកត់ ទុក។ នេះគឺ១៥ សីហា ១៩៧៧ អត់ប្រកែក ខ្ញុំអត់ច្រឡំ។

**ស៖** តើលោកអាចពន្យល់តុលាការបានទេ ចំពោះកាលបរិច្ឆេទផ្សេង? ហេតុអ្វីបានជាឆ្នាំ១៩៩៩ លោកបែរជាថា ថាខែកក្កដា ឆ្នាំ១៩៧៨ ទៅវិញ? បាទហើយនៅទីនេះ លោកនិយាយថា ១៥ សីហា ១៩៧៧ ទៅវិញ? ថាតើលោកអាចពន្យល់តុលាការពីវិធីណាដែលធ្វើឲ្យលោកភ័ន្តច្រឡំឲ្យខុសកាលបរិច្ឆេទ ពីរបែបនេះនោះ?

[១០:១៧:២១]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ដោយហេតុនេះហើយបានជាយើងខ្ញុំទាររកខ្សែអាត់ដែល នេត ថាយ័រ អ៉ំសូមទោស ដែល គ្រីស្តូហ្វ័រ ប៉េស៊ូ ថតសំឡេងខ្ញុំ។ សូមបញ្ជាក់ថា ខ្សែអាត់នុ៎ងអត់មាន ជូនមួយបាច់មកឲ្យខ្ញុំទុកជា ជាច្បាប់ចម្លងឲ្យមកខ្ញុំមួយបាច់ទេ។ ដូច្នេះខ្ញុំសូមទាំងអស់គ្នា រួមទាំង តុលាការផងពិនិត្យមើលខ្សែអាត់ដើមរបស់ខ្ញុំ ដែល គ្រីស្តូហ្វ័រ ប៉េស៊ូ ថត។

**ស៖** ឌុច ខ្ញុំសួរទៅលោកថា ហេតុការណ៍ដែលលោករៀបរាប់ជាច្រើនដង មិនបានកើតឡើង នោះទេ។ នេះហើយជាមូលហេតុដែលលោកច្រឡំកាលបរិច្ឆេទនោះ តើអ៊ីចឹងមែនឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំមិនដែលនិយាយពីរឿងឯណានោះ ពិតជាខ្ញុំនិយាយតែ

ជួប បងនួន ចាប់តាំងពីថ្ងៃ១៥ សីហា ១៩៧៧។ មកច្រើនដង មិនច្រើនដងម៉េច សូមឲ្យមេធាវីប្រមូលមក ១៥ សីហា ១៩៧៧ ហ្នឹង ប៉ុន្មាន? ប៉ុន្មានឯកសារដែលខ្ញុំនិយាយ? យកមកប្រៀបធៀបប្រៀបមកហើយនិងអាឯកសារចម្លងនេះ។ ១៧ ឯណាទុំង ប៉ុន្មាន? មានប៉ុន្មានឯកសារ?

[១០:១៩:៣០]

**ស៖** ខ្ញុំសួរទៅលោកថា សុន សេន នៅតែជាមេរបស់លោក ទោះបីជាគាត់ទៅៗសមរភូមិនៅបូព៌ាហើយក៏ដោយ ហើយលោកមិនដែលរាយការណ៍ ឬក៏ទទួលការណែនាំពី នួន ជា ទេ ក្នុងអំឡុងនោះ។ តើមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំមិនដែលឆ្លើយថា ខ្ញុំមិនដែលរាយការណ៍ឲ្យ នួន ជា ទេ ខ្ញុំរាយការណ៍ឲ្យ សុន សេន ទេ។ គ្រប់ពេលវេលាខ្ញុំនិយាយថា ខ្ញុំនៅមានការទាក់ទងជាមួយនឹង សុន សេន មិនបានផ្ទាល់ទេ តាមរយៈរលកអាកាស កន្លះខែ មួយខែម្តង ជួបគ្នា។ ដូច្នេះ ខ្ញុំរាយការណ៍ជូន នួន ជា ជាប្រចាំ បីថ្ងៃម្តង។ អានេះគាត់ហៅខ្ញុំទៅធ្វើការ បីបួនថ្ងៃយ៉ាងយូរណាស់ប្រាំថ្ងៃម្តង។ ខ្ញុំមិនដែលបាននិយាយសោះ ពាក្យដែលខ្ញុំមិនរាយការណ៍ឲ្យ នួន ជា អីទៅរាយការណ៍ឲ្យ សុន សេន អត់ទេ។ មេខ្ញុំ ខ្ញុំនៅតែជួបគាត់តាមរលកអាកាស។

**ស៖** ឌុច ដើម្បីប្តូរទៅប្រធានបទមួយផ្សេង អំពីការរំដោះភ្នំពេញ។ នៅក្នុងដំណាក់កាលស៊ើបសួរ ស៊ើបអង្កេតនោះ លោកបានបញ្ជាក់ដោយសង្ខេបថា ពីការរំដោះទីក្រុងឆ្នាំ១៩៧៥។ ក្នុងចំណោមនោះ គឺថាលោកបានបញ្ជាក់ថា កងទ័ពដែលចូលរួមក្នុងការរំដោះទីក្រុងនៅថ្ងៃទី១៧ មេសា នោះគឺទ័ពមកពីបូព៌ា មកពីភូមិភាគឧត្តរ ហើយនិងពីភូមិភាគនិរតី ហើយនិងភូមិភាគពិសេសផងដែរ។ សំណួររបស់ខ្ញុំជូនលោកគឺថា តើលោកនៅចាំទេអ្នកណាជាអ្នកកាន់កាប់លើកងទ័ពទាំងនោះក្នុងឆ្នាំ១៩៧៥នោះ?

[១០:២១:៥០]

**ឆ៖** អ្នកដែលកាន់កាប់កងទ័ពតាមលក្ខន្តិកៈបក្ស ហើយនិងតាមការអនុវត្តជាក់ស្តែង នៅពីលើគេជាកំពូល គឺ ប៉ុល ពត, នួន ជា។ ឯចំណែកក្នុងសមរភូមិនោះ លេខាភូមិភាគទាំងអស់ ទៅនៅជុំទុំងដែលជាម្ចាស់កងទ័ពគ្រប់ភូមិភាគ។ ខាងភូមិភាគឧត្តរមាន កុយ ធួន ហើយនិង កែ ពក។ ខាងភូមិភាគពិសេសមាន វន វ៉េត ហើយនិង សុន សេន។ ខាងភូមិភាគនិរតី គឺមាន តាម៉ុក ហើយនិង ជូ ជេត។ ឯចំណែកខាងបូព៌ា ត្រូវតែ បងភឹម មក។ នេះជាគោលការណ៍។

**ស៖** ថាតើមេបញ្ជាការកងភូមិភាគទាំងអស់នោះមានអ្នកណាម្នាក់នៅរស់ដល់រាល់ថ្ងៃទេ?

**ផ៖** បញ្ហាការគ្រប់ភូមិភាគអត់ទេ ស្លាប់អស់ហើយ។

**ស៖** តើលោកបានឮអំពីជម្លោះដែលបានកើតឡើងរវាងកងពលផ្សេងៗ ដែលរំដោះភ្នំពេញក្រោយពីៗរំដោះភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែរឬទេ?

**ផ៖** សូមបញ្ជាក់ថា លោកមានប្រសាសន៍ស្អីទំនាស់រវាងកងទ័ព គ្មានទេ។ ទំនាស់រវាងកងទ័ពគ្មានទេ។

**ស៖** តើលោកស្គាល់ ហេង សំរិន ដែរឬទេ?

[១០:២៤:០៨]

**ផ៖** ហេង សំរិន បច្ចុប្បន្នប្រធានសភាកម្ពុជាប្រជាធិបតេយ្យ-- សូមទោស ប្រធានសភាព្រះរាជាណាចក្រកម្ពុជា។ ប្រធានរដ្ឋសភា។

**ស៖** តើលោកធ្លាប់បានជួបគាត់ទេ?

**ផ៖** ខ្ញុំឃើញរូបគាត់តាមទូរទស្សន៍។

**ស៖** តើលោកនៅចាំទេ ដែលលោកបានផ្តល់បទសម្ភាសន៍ទៅ ប៉ែន យៀរនិន នៅឆ្នាំ១៩៩៩ ដែលរៀបរាប់អំពីការជម្លៀសភ្នំពេញ ហើយតួនាទីរបស់កងពលមួយៗក្នុងការជម្លៀសក្រុងភ្នំពេញនោះ?

**អ្នកបកប្រែ៖** សូមកែតម្រូវការរំដោះទេ មិនមែនការជម្លៀសទេ។ ពីអ្នកបកប្រែបាទ។

**ផ៖** ខ្ញុំសូមជម្រាបលោកប្រធានថា ខ្ញុំមិនដែលស្គាល់ ប៉ែន យៀរនិន ស្អីនោះទេ។

**ស៖** តើលោកដឹងអំពីការសម្ភាសជាមួយលោក ហេង សំរិន ទេ នៅពេលដែលលោកបានមកដល់តុលាការនៅទីក្រុងភ្នំពេញនេះ នៅកន្លែងនេះ?

**ផ៖** អ្នកណាទៅសម្ភាស បងរិន សូមមេធាវីបញ្ជាក់ឲ្យស្រួល?

[១០:២៦:០០]

**ស៖** គឺបុគ្គលម្នាក់ដែលលោកនិយាយដែលមិនស្គាល់នោះគឺ ប៉ែន យៀរនិន គាត់បានសម្ភាសគាត់។ អ៊ីចឹងគឺថាខ្ញុំសួរទៅសំណួរមួយទៀតគឺឯកសារ ដែលមានបទសម្ភាសន៍នោះគឺ D313/1.2.406.1 ទំព័រនោះគឺថា ដាក់លេខច្រឡំគ្នា ប៉ុន្តែទំព័រដែលខ្ញុំយោងនោះគឺចាប់ផ្តើមពី ៣៥ រហូតទៅដល់ ៤៤។ ខ្មែរ ERN 00713945 រហូតដល់ 54 អង់គ្លេស ERN 00651878 រហូតដល់ 83 បារាំង ERN 00743349 រហូតដល់ 54។ បាទ ទំព័រទាំងអស់នោះគឺមានសេចក្តីពណ៌នាលម្អិត អំពីតួនាទីរបស់លោក ហេង សំរិន នៅក្នុងពេលដែលរំដោះទីក្រុងភ្នំពេញ។

**លោក វីល្លៀម ស្មីត៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក វីល្លៀម ស្មីត៖**

*(និយាយមិនបើកក្បាលមីក្រូហ្វូន)*

**ប្រធានអង្គជំនុំ៖**

លោកបើកក្បាលមីក្រូផង!

**លោក វីល្លៀម ស្មីត៖**

ដូចដែលតុលាការបានសម្រេចហើយថា ឯកសារដែលសាក្សីមិនដឹងទេ មិនស្គាល់ទេ ហើយបើសិនជាខ្លឹមសារជាក់លាក់នៃឯកសារនោះ មិនគប្បីដាក់ជូនសាក្សី លើកលែងតែប្រធានបទទូទៅ កម្មវត្ថុទូទៅតែប៉ុណ្ណោះដែលអាចលើកឡើងបាន។ ដូច្នេះ ព្រះរាជអាជ្ញាគិតថា វាមានសារៈសំខាន់ ដើម្បីឲ្យមេធាវីការពារចង្អុលបង្ហាញថា ឯកសារណាដែលគាត់យោង ហើយនៅពេលដែលគាត់ចូលទៅជំហានបន្ទាប់ទៀត និយាយពីចំណុចសំខាន់ជាក់លាក់បញ្ជូនទៅសាក្សីនោះគឺ តុលាការបានសម្រេចហើយថា មិនសមស្របនឹងធ្វើបែបនោះទេ ប៉ុន្តែខ្លឹមសារទូទៅអាចនឹងលើកយកមកបាន។ អ៊ីចឹងយើងខ្ញុំស្នើថា សូមឲ្យគោរពទៅតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះថា ឯកសារទាំងឡាយដែលអាចនឹងចាត់ទុកថាដាក់ចំពោះមុខអង្គជំនុំជម្រះនោះគឺ សហព្រះរាជអាជ្ញាបានស្នើហើយ មានការសម្រេចគឺថា អាចនឹងក្លាយទៅជាភស្តុតាងនៅក្នុងរឿងក្ដីបាន ហើយនិងតម្លៃនៃឯកសារនោះគឺថា អាចនឹងដេញដោលតិចជាងអ្វីដែលមាននៅក្នុងឯកសារហ្នឹងទាំងស្រុង។ ដូចជាមេធាវីការ នួន ជា គឺថាជំទាស់ឯកសារទាំងអស់ដែលដាក់ជូនចំពោះមុខតុលាការ លើកលែងតែកោះសាក្សីហ្នឹងមក។

[១០:២៨:៥៣]

នៅពេលដែលគាត់លើកឡើងពីចំណុចជាក់លាក់ នៅក្នុងឯកសារនោះមកសួរសាក្សីនោះ ដូចជាគាត់បានលើកឡើងថា ភស្តុតាងនោះដែលតាមពិតមិនមែនថា ភស្តុតាងហ្នឹង តាមពិតមិនទាន់បានទទួលស្គាល់នៅឡើយនោះទេ ដោយការសម្រេចរបស់តុលាការនោះគឺថា ខ្លឹមសារទូទៅអាចនឹងលើកឡើងបាន ប៉ុន្តែខ្លឹមសារជាក់លាក់មិនអាចនោះទេ ដោយហេតុថា មិនអាចចាត់ទុកជាភស្តុតាងដែលត្រូវស្ដាប់ទេ

លើកលែងតែមានសេចក្តីសម្រេច របស់អង្គជំនុំជម្រះ ទៅលើករណីដែលបានលើកឡើងខាងដើមនេះជាមុនសិន។

**លោក ម៉ៃខល ផេសមិន៖**

ប្រសិនបើសហព្រះរាជអាជ្ញា លើកឡើងថា បើសិនជាគប្បីកោះលោក ហេង សំរិន មកធ្វើសាក្សីយើងគាំទ្រ ហើយខ្ញុំនឹងសួរលម្អិតនោះទេ។ ខ្ញុំនឹងសួរសំណួរជាទូទៅ អំពីអង្គហេតុដែលបញ្ជាក់នៅក្នុងឯកសារនេះទៅសាក្សីឲ្យលោកឆ្លើយបាទ។

[១០:៣០:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះសិនទៅ!

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣៦:០៥]

លោកមេធាវី អញ្ជើញក្រោកឈរ!

ឯកសារដែលលោកយោងទៅសំដៅដើម្បីប៉ុនប៉ងក្នុងការសួរដេញដោលសាក្សីនេះ តើមាននៅក្នុងសំណុំរឿង០០២ ដែរឬទេ?

**លោក ម៉ៃខល ផេសមិន៖**

បាទ លោកប្រធាន។ ខ្ញុំជឿថា វាមាននៅក្នុងសំណុំរឿង ពីព្រោះខ្ញុំបានផ្តល់លេខឯកសារជា D និងជា ERN ហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ប្រហែលជាដោយសារនេះ គឺលោកនិយាយថា ខ្ញុំជឿថាជាភាសាអង់គ្លេស គឺលោកច្បាស់ទេ លោកពិតទេ ថាពិតជាមាននៅក្នុងសំណុំរឿងនេះ?

**លោក ម៉ៃខល ផេសមិន៖**

ប្រហែលជាសហព្រះរាជអាជ្ញាអាចជួយឆ្លើយខ្ញុំបាន។

**លោក វីល្លៀម ស្មីត៖**

គឺថាវាមាននៅក្នុងសំណុំរឿងហើយ ក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញាហើយ ដាក់ជូនអង្គជំនុំ ចំពោះមុខអង្គជំនុំជម្រះ។

**លោក ម៉ៃខល ផេសមិន៖**

យើងខ្ញុំក៏បានដាក់ឯកសារនេះ ចូលក្នុងបញ្ជីឯកសាររបស់ខាងយើងខ្ញុំដែរ។

[១០:៣៧:៣៥]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទៅយកឯកសារជាក្រដាសដាក់ជូនសាក្សីពិនិត្យ។

ន៎ែៗ! ឥឡូវមិនបាច់ទេអ៊ីចឹង។

លោកមេធាវី! ដោយសារឯកសារដែលលោកបានលើកឡើងអម្បាញ់មិញនេះជាបទសម្ភាសន៍ ជាមួយនឹងបុគ្គលមួយផ្សេងទៀត គឺសម្ដេច ហេង សំរិន ហើយដែលមិនមានវត្តរបស់សាក្សីរូបនេះ នៅក្នុងអំឡុងពេលនៃសម្ភាសទេ។ បានន័យថា គាត់មិនបានដឹងអំពីដំណើរការសម្ភាស ក៏ដូចជាខ្លឹមសារ នៃសេចក្ដីសម្ភាសនោះឡើយ។ ដូច្នេះ លោកមេធាវីមានសិទ្ធិក្នុងការតាំងសំណួរចំពោះសាក្សីបាននូវ សំណួរទូទៅ ដោយមិនត្រូវដកស្រង់យកនៅផ្នែកណាមួយមកតាំងសំណួរចំពោះសាក្សីឡើយ។ ទន្ទឹមនឹង នេះដែរ គឺសាក្សីដូចគ្នា សាក្សីត្រូវស្ដាប់នូវការតាំងសំណួរ ហើយមិនគប្បីឆ្លើយតបទៅនឹងសំណួរដោយ ស្មានៗនោះឡើយ។ ប្រសិនបើសាក្សីដឹងអំពីហេតុការណ៍ អំពីព្រឹត្តិហេតុ អំពីបញ្ហានានាដែលពាក់ព័ន្ធ ទៅនឹងខ្លឹមសារនៃសំណួរ លោកអាចឆ្លើយតបនឹងសំណួរនោះបាន ចៀសវាសក្នុងការឆ្លើយស្មានៗ ពី ព្រោះនេះជារឿងមួយដោយឡែក ហើយយកមកតទល់ជាមួយនឹងលោក។ អ៊ីចឹងគឺអនុវត្តដូច្នេះ។

[១០:៣៩:៤៤]

មេធាវី!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំ បើយល់អំពីសេចក្ដីបង្គាប់នេះហើយ គឺខ្ញុំក្រឡេកទៅមើលនាឡិកា ឃើញថាដល់ម៉ោងសម្រាកហើយ។ ថាតើលោកប្រធានចង់ឲ្យខ្ញុំបន្តទៅទៀត ឬក៏ៗត្រូវឈប់សម្រាក សិន។ នេះជាសំណួរទូទៅរបស់ខ្ញុំហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បន្តឲ្យចប់បញ្ហាហ្នឹងទៅ!

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ឌុច លោកដឹងទេ នៅពេលរំដោះទីក្រុងភ្នំពេញហ្នឹង តើលោក ហេង សំរិន មានតួនាទីជាអ្វីដែរ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន នៅពេលរំដោះភ្នំពេញ បងរិន ជាអនុលេខាកងពល៣ នៃភូមិភាគបូព៌ា។ នេះបញ្ហា ខ្ញុំបានរាយការណ៍ជូនសហចៅក្រមស៊ើបអង្កេតផងដែរ។

**ស៖** លោកមិន-- លោកជឿជាក់ថាប្រាកដជាកងពលលេខ៣ ហើយមិនមែនជាកងពលលេខ១ទេឬ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បងរិន ជាអនុលេខារបស់កងពល៣ នៃភូមិភាគបូព៌ា។ លេខាឈ្មោះ ពៅ ហាក់។

**ស៖** តើលោកស្គាល់ឈ្មោះរបស់បងលោក ហេង សំរិន ដែរទេ ដែលគាត់ក៏ជាមេបញ្ជាការកងទ័ពដែរ?

**អ្នកបកប្រែ៖**

បាទអ្នកបកប្រែសូមកែតម្រូវ។ **ស៖** លោកស្គាល់ប្អូនរបស់លោក ហេង សំរិន ទេ គាត់ក៏ជាមេបញ្ជាការកងទ័ពរូបដែរ?

[១០:៤២:៣០]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំស្គាល់។ ប្អូនរបស់បងរិនហ្នឹង ឈ្មោះ តាល់។

**ស៖** លោកដឹងថា តួនាទីរបស់គាត់មានតួនាទីអ្វីដែរ នៅពេលរំដោះទីក្រុងភ្នំពេញនុ៎ះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន។ មិត្តតាល់ លេខាកងទ័ពជើងទឹកប្រចាំការអ្នកលឿងឈ្មោះ កងពល២៩០។

**ស៖** តើអ្នកណាជាលេខាកងពលលេខ២ នៃភូមិភាគបូព៌ា?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន។ ខ្ញុំមិនដឹងទេ។

**ស៖** ឌុច តើលោកដឹងថាទីក្រុងត្រូវបានខណ្ឌ១ដាច់ពីគ្នាពីរជាពីរបីប្លុក នៅពេលរំដោះទីក្រុង

ភ្នំពេញនៅថ្ងៃ១៧ មេសា ៧៥ ដោយមានកងទ័ពមកពីភូមិភាគនីមួយៗ គឺថាគ្រប់គ្រងទីក្រុងភ្នំពេញដែលត្រូវខណ្ឌចែកគ្នានោះ តើលោកចាំទេ?

[១០:៤៤:២៧]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំចូលមកភ្នំពេញថ្ងៃ២០ មិថុនា ១៩៧៥ ដល់ក្រោយមកបានខ្ញុំដឹងថា ខ្ញុំរស់នៅក្នុងតំបន់ដែលកងពល៧០៣រំដោះ និងការពារសុវត្ថិភាពទីក្រុងហ្នឹង។ ដីរបស់ ស-២១ នេះ វាស្ថិតនៅក្នុងកងពល-- ទេ កងពល៧០៣ នៅខាងជើងផ្លូវមុនីវង្សទេ។ ឯចំណែកដីដែលខ្ញុំនៅ គឺស្ថិតនៅក្នុងកងពល៥០២។ ការការពារសុវត្ថិភាពរបស់កងពល៥០២។ ដូច្នេះ ភ្នំពេញទាំងមូលចែកជាតំបន់ ទៅតាមការដែលកងពលនីមួយៗចូលមករំដោះដើម្បីរួមចំណែកគ្នាកសាង-- ការពារសុវត្ថិភាពទីក្រុង។

**ស៖** សូមអរគុណ។ លោក ហេង សំរិន ក៏បានជម្រាបទៅ ប៉ែន យៀរនិន ដែរថា កងទ័ពនៃផ្នែកនីមួយៗមិនអនុញ្ញាតឲ្យដើរហើរចូលទៅក្នុងតំបន់ដែលគ្រប់គ្រងដោយកងទ័ពផ្នែកមួយទៀតទេ--

**លោក វីល្លៀម ស្មីត៖**

ខ្ញុំគិតថា មេធាវីការពារក្តី គឺលើក គួរលើកឡើងនូវបញ្ហាដែលបានសម្ភាស មិនឲ្យលើកឡើងបញ្ហាជាក់លាក់ណានោះមួយនោះទេ។ ប៉ុន្តែ ឥឡូវនេះគាត់យកការសម្ភាសនេះ យកខ្លឹមសារនៃការសម្ភាសនេះ យកមកប្រើប្រាស់ ហើយលោកប្រធានបានបង្គាប់រួចហើយ។ ដូច្នេះខ្ញុំសូមឲ្យលោកប្រធានបង្គាប់ទៅមេធាវីការពារក្តីឲ្យនិយាយអំពីខ្លឹមសារទូទៅទៅបានហើយ កុំនិយាយទៅលើចំណុចជាក់លាក់ណាមួយនោះ ហើយលោកប្រធានក៏បានបង្គាប់ម្តងរួចទៅហើយ។ សូមអរគុណ។

[១០:៤៦:៤៧]

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** បាទ ខ្ញុំសូមសួរឡើងវិញ តើលោកបានដឹងថាទីក្រុងត្រូវបានបែងចែកទៅជាភូមិភាគនីមួយៗស្ថិតនៅក្នុងការគ្រប់គ្រងរបស់ភូមិភាគនីមួយៗ ហើយក៏កងទ័ពរបស់ភូមិភាគនីមួយៗមិនឲ្យធ្វើដំណើរចូលទៅតំបន់ដែលត្រូវភូមិភាគដទៃទៀតគ្រប់គ្រងនោះទេ។ តើលោកបានដឹងរឿងនេះទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមនិយាយសាឡើងវិញពាក្យដែលខ្ញុំបានរាយការណ៍ជូនតុលាការអំមិញ។ តំបន់ភ្នំពេញត្រូវបែងចែកទៅតាមកងពលដែលរំដោះបាន។ ទីណាកាន់កាប់ទីនុំង

ដើម្បីរក្សាសុវត្ថិភាពក្រុងភ្នំពេញ។ នេះច្បាស់លាស់។ ឯចំណែកគោលការណ៍ ហាមមិនឲ្យដើរ វាជាគោលការណ៍រួមរបស់បក្សកុម្មុយនីស្តកម្ពុជា។ ខ្ញុំនៅក្នុងភូមិភាគពិសេស ខ្ញុំមិនអាចមកចូលភ្នំពេញបានទេ។ គេចាប់ឥឡូវហ្នឹង បើអត់សំបុត្រដើរផ្លូវ។ នៅភ្នំពេញខ្លួនឯងហ្នឹងក៏ដោយ ដើរធ្វេចធ្វាចអត់សំបុត្រដើរផ្លូវចាប់។ ម៉ូតូអ្នកណាដែលគ្មានសិទ្ធិជិះ គេចាប់ដក។ នេះច្បាស់លាស់។ ដូច្នេះមិនមែនអ្នកណាជាអ្នកណា បញ្ហានេះវាចេញពី ប៉ុល ពត មក។

[១០:៤៨:២៧]

**ស៖** សូមអរគុណ។ យើងទើបតែបាននិយាយអំពីលោក ហេង សំរិន និងប្អូនប្រុសរបស់គាត់ ដែលជាមេបញ្ជាការដែលបានចូលរួមមករំដោះទីក្រុងភ្នំពេញ។ សំណួររបស់ខ្ញុំ គឺថាតើលោកស្គាល់មេបញ្ជា ឬក៏អនុមេបញ្ជាការកងពលដទៃទៀត ដែលបានចូលរួមរំដោះទីក្រុងភ្នំពេញដែរឬទេ? ហើយថាតើមានអ្នកណាខ្លះដែលរស់រានមានជីវិតរហូតមកទល់នឹងសព្វថ្ងៃនេះដែរទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ប្រធានកងពលដែលចូលរំដោះភ្នំពេញហ្នឹងនិយាយមួយប៉ែក។ ប្រធានកងពលរបស់យុទ្ធភូមិភាគ-- របស់ភូមិភាគនីមួយៗនិយាយមួយប៉ែកទៀត។ ប្រធានកងពលដែលចូលមករំដោះភ្នំពេញបើតាមខ្ញុំដឹង គឺនៅសល់រស់ពីរនាក់។ បងម៉ុត ឈ្មោះពេញលេញ មាស ម៉ុត និង ស្វ៊ែ ម៉េត។ ឯចំណែកម្នាក់ទៀត ឃឹម ពីន ដូចឮថាសមរភូមិ-- ពលីនៅក្នុងសមរភូមិ ខ្ញុំមិនទាន់ច្បាស់ តែរកដំណឹង បងពីន រកអត់ទាន់ឃើញ។ ហើយអ្នកជំនួសគាត់ មិត្តឌី ប្រហែលជានៅរស់។ នេះនៅក្នុងកងពលមជ្ឈិម។ សូមបញ្ជាក់ថា ខែកក្កដា ១៩៧៥ កងទ័ពភូមិភាគនីមួយៗ គេសុំ--មជ្ឈិម សុំពីកងទ័ពពីភូមិភាគនីមួយៗ មួយភូមិភាគជូនអីពីរកងពល ជូនអីបីកងពល យកមកបញ្ចូលជាកងទ័ពមជ្ឈិម។ នេះខ្ញុំនិយាយពីត្រឹមថ្នាក់កងទ័ពមជ្ឈិម អ្នកដែលនៅរស់ប៉ុណ្ណឹង បើតាមខ្ញុំនៅចាំ។

**ស៖** តើមានមេបញ្ជាការដទៃទៀតដែលមកពីភូមិភាគផ្សេងៗនោះ នៅរស់រានមានជីវិតដល់សព្វថ្ងៃ លោកនៅមានស្គាល់ខ្លះទេ?

[១០:៥១:០៥]

**ឆ៖** មេបញ្ជាការដែលនៅរស់ទល់សព្វថ្ងៃច្រើនដែរ ដែលកើតក្រោយ ដែលចាត់តាំងក្រោយ។ មេបញ្ជាការជំនាន់ឆ្នាំ៧៥ ឥឡូវស្លាប់បាត់ទៅហើយ សំ ប៊ិត។ ឯចំណែកម្នាក់ទៀតហ្នឹង គឺបង រិន នេះឯងដែលលោកកំពុងតែសួរខ្ញុំនេះ ហេង សំរិន ហ្នឹង។

**ស៖** សូមអរគុណលោក។ យោងទៅតាមលោក ហេង សំរិន គឺថានៅក្នុងឆ្នាំ១៩៧៥ គឺមិនមាន

ការបញ្ជាឲ្យសម្លាប់មន្ត្រីរបស់ លន់ នល់ ទេ--

**លោក វីណ្ឌៀម ស្មីត៖**

ខ្ញុំសូមជំទាស់។ មេធាវីការពារក្តីនៅពេលនេះ គឺថាបានស្រង់យកពាក្យសម្តីជាក់លាក់នៅក្នុងឯកសារយកមកសាកសួរសាក្សី។ នេះមិនមែនជាភស្តុតាងដែលបានដាក់ជូននៅចំពោះមុខអង្គជំនុំជម្រះនោះទេ។ ហើយបើធ្វើដូច្នេះ គឺថាយើងខ្ញុំសូមឲ្យដាក់ភស្តុតាងនេះនៅចំពោះមុខអង្គជំនុំជម្រះ ហើយឲ្យអង្គជំនុំជម្រះជាអ្នកធ្វើការសម្រេច។ ដូច្នេះគាត់កំពុងតែសួរនាំមុខសាក្សីរូបនេះហើយ។ ដូច្នេះខ្ញុំសូមឲ្យអង្គជំនុំជម្រះមេត្តាណែនាំទៅដល់-- ឲ្យសួរជាខ្លឹមសារទូទៅ មិនត្រូវឲ្យសួរសាក្សីរូបនេះដើម្បីប្រឆាំងទៅបុគ្គលដទៃទៀតណានោះទេ។ សូមអរគុណ។

[១០:៥២:៥៤]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី នួន ជា យើងរំឭកសាជាថ្មីម្តងទៀត។ ទីមួយ យើងអរគុណ ហើយនិងការកត់សម្គាល់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដែលបានលើកឡើងបញ្ជាក់ម្តងហើយម្តងទៀត ហើយយើងសង្ឃឹមថា មេធាវីវិជ្ជាជីវៈនឹងស្តាប់យល់ ហើយនិងខិតខំធ្វើការដេញដោលអនុវត្តសិទ្ធិរបស់ខ្លួនតាមការណែនាំ និងការកំណត់របស់អង្គជំនុំជម្រះ។ មេធាវីអាចតាំងសំណួរចំពោះសាក្សីនេះបាននូវសំណួរទូទៅដោយមិនត្រូវដកស្រង់យកផ្នែកណាមួយជាក់លាក់ នៅក្នុងបទសម្ភាសន៍ ឬកំណត់ហេតុសួរដេញដោលបុគ្គលផ្សេងទៀតមកតាំងសំណួរចំពោះសាក្សីនេះ ឬក៏សាក្សីដទៃទៀតឡើយ។ នេះជាការរំឭកសាជាថ្មីម្តងទៀត ហើយទំនងជាងាយចងចាំទេ ដែលមិនពិបាកអីឲ្យចាំប៉ុន្មានទេនូវបញ្ហាត្រឹមប៉ុននេះ។

[១០:៥៤:១៤]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបញ្ចប់ផ្នែកនៃការរំដោះទីក្រុងភ្នំពេញត្រឹមនេះហើយ តើលោកប្រធានអនុញ្ញាតឲ្យខ្ញុំបន្តចូលប្រធានបទមួយទៀត ឬក៏ៗសម្រាក ឬយ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

បាទឥឡូវដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយដប់ប្រាំទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ អនុរក្សមន្ទីរឃុំឃាំងអញ្ជើញសាក្សី កាំង ហ្កេកអ៊ាវ ទៅកាន់បន្ទប់សម្រាកសម្រាប់សាក្សី ហើយនិងឲ្យ

អញ្ជើញគាត់មកកាន់បន្ទប់សវនាការកន្លែងផ្តល់សក្ខីកម្មវិញនៅម៉ោងដប់មួយ និងដប់ប្រាំនាទី។

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីឲ្យលោក អៀង សារី!

[១០:៥៥:០៤]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម លោក អៀង សារី ថ្ងៃនេះសូមលះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះសម្រាប់ថ្ងៃនេះទាំងស្រុងតែម្តង។ ប៉ុន្តែ សូមចូលរួមសវនាការពីបន្ទប់រង់ចាំខាងក្រោម ដោយហេតុថាមូលហេតុសុខភាព ជាពិសេសបញ្ហាឈឺចង្កេះឆ្អឹងខ្នង និងជើង។

អាស្រ័យហេតុនេះសូមលោកប្រធានមេត្តាពិចារណា និងសម្រេច។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានស្តាប់នូវសំណើសុំរបស់លោក អៀង សារី ដែលឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិមិនចូលរួមតាមដានកិច្ចដំណើរការសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ដោយទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីប្រព័ន្ធ-- តាមរយៈប្រព័ន្ធសោតទស្សន៍ពីបន្ទប់ឃុំខ្លួនមួយនៅខាងក្រោមបន្ទប់សវនាការនេះ សម្រាប់រយៈពេលពីនេះទៅរហូតដល់ចប់សវនាការថ្ងៃនេះ ដោយមូលហេតុបញ្ហាសុខភាព។ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិមិនចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ដោយទៅបន្តតាមដានកិច្ចដំណើរ ពីចម្ងាយពីបន្ទប់ឃុំខ្លួន ស្ថិតនៅក្រោមបន្ទប់សវនាការនេះតាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលពេញមួយថ្ងៃនេះ។

[១០:៥៦:២៦]

តែក្រុមមេធាវីការពារក្តីត្រូវប្រគល់មកអង្គជំនុំជម្រះភ្លាម នូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ អៀង សារី ដោយមានចុះហត្ថលេខា ឬក៏ផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទផង។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់ជនជាប់ចោទរូបនេះអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់កិច្ចដំណើរការសវនាការពីនេះរហូតដល់ចប់សម្រាប់

ថ្ងៃ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដែលបានរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍ សម្រាប់ជនជាប់ចោទរូបនេះអាចតាមដាន និងចូលរួមកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៥៧ នាទី ដល់ម៉ោង ១១:២០ នាទី)*

[១១:២០:៤៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ លោកតំណាងអយ្យការមានបញ្ហាអីទេ? សូមអញ្ជើញ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់លើកបញ្ហាមួយ។ ទាក់ទងទៅនឹងបទសម្ភាសន៍ IS20.19 ត្រូវបានដាក់ជូនសាក្សី នៅក្នុងបទសម្ភាសន៍នោះគាត់បាននិយាយថា នៅឆ្នាំ១៩៧៨ គាត់ថា នួន ជា ជំនួស សុន សេន គឺថា មានកត់ត្រានៅក្នុងបទសម្ភាសន៍នោះ ដែលបានបង្ហាញរួចហើយ។

លោក លោកស្រីចៅក្រម ខ្ញុំសូមរំឭកដល់មេធាវីការពារថា សេចក្ដីដកស្រង់នេះ មិនមែនយកចេញអំពីប្រតិចារឹកនៃបទសម្ភាសន៍ទេ គឺគត់ត្រា-- គឺដកស្រង់មកពីកំណត់ហេតុដែលភ្ជាប់ជាមួយបទសម្ភាសន៍ ប៉ុន្តែមិនឆ្លុះបញ្ចាំងនៅក្នុងប្រតិចារឹកនៃបទសម្ភាសន៍នោះទេ។ ហើយក៏សូមពន្យល់អំពីវិធីថាហេតុអ្វីបានព័ត៌មាននៅលើកំណត់នេះ? ព័ត៌មាននេះមិនច្បាស់ទេ។ ខ្ញុំសូមកំណត់ថា ប្រតិចារឹកនៃបទសម្ភាសន៍នោះគឺមិនមានខ្លឹមសារនេះទេ គឺខ្លឹមសារដែលមានឆ្នាំនេះគឺថា អាចនៅលើកំណត់ដៃដែលភ្ជាប់មកជាមួយប្រតិចារឹកទេ។

[១១:២២:១៩]

បញ្ហាមួយទៀត ទាក់ទងទៅនឹងការលើកឡើងដោយមេធាវីការពារថា ហេង សំរិន មានតែ

មេដឹកនាំ-- អ៎! មេបញ្ជាការម្នាក់ដែលនៅរស់ ដែលរំដោះទីក្រុងភ្នំពេញ។ ដូច្នេះ នៅក្នុងកងពល ហើយ វរសេនាតូច TCW-5 (ស៊ីក), TCW-356 នោះ គឺសាក្សីនឹងមកបំភ្លឺ។ ហើយនៅក្នុងករណីនេះ អង្គជំនុំជម្រះមិនទាន់បានសម្រេចនោះទេ អំពីការជម្លៀសដោយបង្ខំជាផ្នែកនៃសំណុំរឿងក្តី។ ប៉ុន្តែសម្រាប់កំណត់ត្រាតុលាការគឺថា មេបញ្ជាការកងពលតូច វរសេនាតូច នេះគឺថា យើងនឹងមិនទាន់តុលាការសម្រេចថា នឹងកោះហៅសាក្សីណាមកបំភ្លឺតុលាការនៅឡើយទេ។

**ប្រធានអង្គជំនុំ៖**

អរគុណនូវការសង្កេតរបស់តំណាងសហព្រះរាជអាជ្ញា។

សូមអញ្ជើញលោក ផេសមិន!

[១១:២៣:២៤]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបំភ្លឺបញ្ហាមួយចំនួន។ ខ្ញុំៗពិនិត្យប្រតិចារឹកជាភាសាបារាំង ប៉ុន្តែសហព្រះរាជអាជ្ញាលើកឡើងត្រូវហើយ។ នៅពេលដែលគាត់បញ្ជាក់ថា ចំណុចដកស្រង់ដែលខ្ញុំលើកព្រឹកមិញនេះ គឺមិនមែនចេញមកពីខ្លឹមសារនៃការសម្ភាសទេ គឺផ្អែកទៅលើកំណត់ដៃ។ បាទ គឺថា នៅក្នុង តាសាញ សំឡូត នៅថ្ងៃ២០, ២៩ មេសា ឆ្នាំ១៩៩៩ ហើយកំណត់ត្រាដើមហ្នឹងជាភាសាបារាំង ដែលកត់ត្រាឡើងដោយ គ្រីស្ទ ប៉េស្ទ័ ហើយខ្ញុំជឿថា នេះជាបទសម្ភាសន៍មួយដែល ឌុច បានយោងទៅរកជាញឹកញាប់នៅក្នុងពេលដែលគាត់ឆ្លើយនោះ។

[១១:២៤:១៨]

ទាក់ទងទៅនឹងមេបញ្ជាការវិញ ខ្ញុំបានសួរសាក្សីឲ្យដាក់ឈ្មោះ វាយឈ្មោះ នៃមេបញ្ជាការកងពលដែលនៅរស់ ហើយតាមគាត់-- តាមពិតនោះគឺថាមានចំណុចគួរឲ្យចាប់អារម្មណ៍ដែលយើងបានឮ សាក្សីបញ្ជាក់ថា មេបញ្ជាការជាន់ក្រោមនោះ គាត់បាននិយាយមួយចំនួន ហើយនៅថ្នាក់កងពលគឺថា មិនទាន់ទៅដល់វរសេនាតូច ឬក៏វរសេនាធំនៅឡើយទេ។ ប៉ុន្តែយើងដឹងថា ប្អូនប្រុសរបស់លោក ហេង សំរិន នោះក៏មិនមែនជាជនសង្ស័យនៅក្នុងរឿងក្តីនេះទេ ហើយក៏នឹងមិនត្រូវកោះមកបំភ្លឺនៅក្នុងរឿងក្តីនេះនោះទេ តាមដែលខ្ញុំយល់។

**លោក វីល្លៀម ស្មីត៖**

ដើម្បីកត់ត្រាត្រឹមត្រូវគឺថា ហើយនៅក្នុងកំណត់ត្រាតុលាការគឺថា គាត់មិនមែនជាប្រធានកងពល

នោះទេ ហើយគាត់ជាអនុសេនា បាទ កងវរសេនាធំនោះទេ។ បាទ អនុលេខា។

**លោក ម៉ៃខល ផេសមិន៖**

យើងខ្ញុំយល់ស្របជាមួយសហព្រះរាជអាជ្ញា។ អ៊ីចឹង ខ្ញុំសូមអនុញ្ញាតបន្តសួរសាក្សីទៅទៀត លោកប្រធានបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ឌុច ដើមបណ្ដឹងរដ្ឋប្បវេណីបានបង្ហាញឲ្យលោកមើលនូវលិខិតមួយចំនួន សំបុត្រមួយចំនួន ដែល ស៊ូ ម៉េត សរសេរមកកាន់លោកនៅក្នុងឆ្នាំ១៩៧៧។ តើលោកយល់ទេថា សំបុត្រទាំងអស់នោះ ដែលខ្ញុំនិយាយហ្នឹងសំបុត្រប្រភេទណា? សំបុត្រអ្វី?

**ឆ៖** សំបុត្រដែល សុន សេន ណែនាំឲ្យ ស៊ូ ម៉េត សរសេរតាមរយៈគាត់មកខ្ញុំ។

[១១:២៦:៤៦]

**ស៖** បាទ ពិតហើយ។ ហ្នឹងហើយដែលអ្វីលោកនិយាយ ហើយលោកក៏និយាយប្រាប់តុលាការ ផងដែរថា មិនផ្ញើមកលោកដោយផ្ទាល់ទេ ប៉ុន្តែលោកបានទទួលឯកសារនោះពី សុន សេន។ តើត្រូវទេ?

**ឆ៖** ត្រឹមត្រូវ!

**ស៖** ប្រធានបទនេះ ក៏បានពិភាក្សាដេញដោលក្នុងរឿងក្ដីរបស់លោកដែរ ខ្ញុំយល់ឃើញថា អ៊ីចឹង។ នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះនេះ បានបញ្ជាក់ថា ខ្ញុំសូមដកស្រង់ពីសាលក្រមមួយនេះ ហើយខ្ញុំសូមឲ្យលោកឆ្លើយតបទៅនឹងសាលក្រម ហើយបានពន្យល់ពីលិខិតនោះ "គឺថាសំបុត្រនោះគឺ បានផ្ដល់មកឲ្យលោក គឺ សុន សេន ជាអ្នកឲ្យលោកដោយផ្ទាល់លោក ហើយអង្គជំនុំជម្រះបញ្ជាក់ថា ការបញ្ជាក់នេះគឺ មិនគួរឲ្យជឿជាក់បានទេ"។ ដូច្នេះ តើលោកអាចមានចម្លើយទេ ទាក់ទងទៅនឹង សេចក្ដីដកស្រង់ពីសាលក្រមនេះ?

[១១:២៨:០៥]

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ!

**លោក វីណ្ឌៀម ស្មីត៖**

ការជំទាស់ទៅលើ មិនត្រឹមតែលើអង្គហេតុ ដែលថាមានការចោទប្រកាន់នោះទេ ក៏ប៉ុន្តែក៏ត្រូវសួរសាក្សី ឲ្យគាត់ផ្តល់យោបល់ទៅលើសេចក្តីសម្រេចរបស់តុលាការ ក៏មិនសមស្របនោះដែរ។ បាទ ហើយប៉ុន្តែបើគាត់យកខ្លឹមសារនៃការចោទប្រកាន់ទៅលើ-- មកសួរសាក្សីគឺអាចបាន។ ប៉ុន្តែបើសួរសាក្សីឲ្យផ្តល់យោបល់ទៅលើសាលក្រមរបស់តុលាការ ខ្ញុំមិនគិតថា អាចនឹងធ្វើឲ្យបង្ហាញអង្គហេតុអ្វីទូលំទូលាយដែលតុលាការត្រូវសម្រេចទេ។ គាត់គប្បីតែសួរពីមូលដ្ឋានរបកគំឃើញ ហើយនិងការពិចារណា។ បើមិនដូច្នោះទេ គឺថាបើយើងសួរអ៊ីចឹង ដូចជាឲ្យសាក្សីឲ្យគាត់វិនិច្ឆ័យទៅលើសាលក្រមរបស់តុលាការអ៊ីចឹង។ នេះជាសំណួរដែលមិនសមស្របទេ ដែលយើងខ្ញុំសូមជំទាស់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី កាណាវាស!

[១១:២៩:១៤]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន សូមជម្រាបសួរលោក លោកស្រីចៅក្រម។ ខ្ញុំមិនយល់ស្របជាមួយសហព្រះរាជអាជ្ញានោះទេ។ ដូចដែលយើងនៅចាំច្បាស់ហើយថា យើងមានយើងបានស្នើទាំងពីអង្គជំនុំជម្រះ ទាំងពីសហព្រះរាជអាជ្ញា ដើម្បីបង្ហាញអ្វីជាចំណុចជាក់លាក់របស់អង្គជំនុំជម្រះ ឬក៏សហព្រះរាជអាជ្ញាជឿថា មេធាវីការពារនោះគឺថា ឬក៏សាក្សីនេះមិនស្មោះត្រង់ក្នុងដំណើរការរឿងក្តី០០១នោះ។ យើងបានស្នើបែបនោះ ដើម្បីឲ្យយើងអាចប្រឈមដេញដោលចំពោះគាត់។ យើងជឿជាក់ថា វាមិនសមស្របទេ បើសិនសួរសាក្សីរូបនេះ ឲ្យផ្តល់យោបល់ ថាតើសហព្រះរាជអាជ្ញាដែលគាត់ជឿថាគាត់មិនស្មោះត្រង់ឲ្យគ្រប់គ្រាន់នោះទេ នៅក្នុងរឿងក្តីមុននោះ។ តែបើសិនជាគាត់ប្រកាន់ជំហរថា គាត់ពិតប្រាកដ១០០ភាគរយ គឺថាយើងអាចនឹងសួរដេញដោលពីភាពជឿជាក់បានរបស់គាត់។ អ៊ីចឹងហើយអង្គជំនុំជម្រះអនុញ្ញាតឲ្យយើងសួរទៅគាត់ ថាអង្គជំនុំជម្រះរកឃើញគាត់ថាមិនសូវស្មោះត្រង់ មិនបង្ហាញការពិតទាំងស្រុងនោះ ហើយឲ្យគាត់បង្ហាញយោបល់នោះ គឺអាចនឹងធ្វើឲ្យសាក្សីគាត់ស្ថិតនៅក្នុងរឿងក្តីនោះ គឺថាគាត់អាចហួសពីសមត្ថភាពរបស់គាត់។ អ៊ីចឹងហើយគាត់ យើងអាចថា យើងសួរ

គាត់ថានិយាយនៅក្នុងសហចៅក្រមស៊ើបអង្កេត នៅជាមួយសហព្រះរាជអាជ្ញា។ ប៉ុន្តែបើគាត់និយាយនៅទីនេះថា នៅទីនេះគាត់បង្ហាញថាភាពស្មោះត្រង់១០០ភាគរយ អាហ្នឹងជាករណីមួយដែលអាចទាញសេចក្ដីសន្និដ្ឋានថា បើយើងយកចំណុចផ្សេងមកតទល់ទើបយើងអាចដឹងថា ចំណុចណាមួយដែលពិតប្រាកដ។ អ៊ីចឹងហើយយើងគប្បីថា យើងគប្បីតែប្រើសិទ្ធិហ្នឹងបាន យើងដើម្បីស្វែងរកការពិត យើងគាត់យើងគួរតែសួរគាត់អំពីបញ្ហានេះ។

[១១:៣១:១៣]

សហព្រះរាជអាជ្ញាអះអាងម្ដងហើយម្ដងទៀតថា សាក្សីរូបនេះជាសាក្សីពិសេសជា*យូទិក* ដែលយើងឮពីសហព្រះរាជអាជ្ញាច្រើនដងណាស់អំពីថាដើម្បីបំពេញនូវអង្គហេតុ។ នេះហើយខ្ញុំបានស្ដាប់។ អ៊ីចឹងហើយនេះគឺថាជាការសមស្របដែលថាអាចសួរសំណួរបែបនេះបាន។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកសហព្រះរាជអាជ្ញា!

[១១:៣១:៤២]

**លោក វីណ្ដៀម ស្មីត៖**

លោកប្រធាន មេធាវីការពាររបស់លោក អៀង សារី គឺយល់ច្រឡំពីបញ្ហា១មិនថា តើត្រូវសួរមិនសួរសាក្សីនោះទេ ថាតើគាត់បង្ហាញភាពស្មោះត្រង់មិនស្មោះត្រង់នោះ។ គឺមេធាវីអាចសួរគាត់ដេញដោលពីរឿងហ្នឹង។ យើងមិនជំទាស់ពីបញ្ហានោះទេ។ ហើយម្យ៉ាងទៀតមិនមែនជាបញ្ហាថាតើមេធាវីការពារ ឬក៏ភាគីណាមួយមាន១សិទ្ធិដាក់រឿងក្ដីឲ្យសាក្សីសម្រេចនោះទេ ហើយយើងជម្រាបតុលាការថាភាគីមានសិទ្ធិ ហើយអង្គជំនុំជម្រះអាចកត់ត្រា អាចពិចារណា ថាតើណាត្រូវ ណាខុស? ហើយយើងយល់ស្របទាំងស្រុង ប៉ុន្តែអ្វីដែលយើងជំទាស់នោះ គឺថាការសួរឲ្យសាក្សីឲ្យផ្ដល់យោបល់លើមតិរបស់ចៅក្រម។

[១១:៣២:២៧]

ប្រសិនបើមេធាវីការពារចង់បង្ហាញនូវចំណុចខ្វែងគ្នា មិនស្របគ្នារបស់-- ភស្តុតាងនៅក្នុងប្រតិចារឹករឿងក្ដី០០១ ទៅសាក្សី ហើយឲ្យគាត់ផ្ដល់យោបល់ យើងមិនជំទាស់ទេ ការធ្វើបែបនោះ។ ប៉ុន្តែអ្វីដែលយើងជំទាស់នោះគឺមេធាវីការពារនិយាយប្រាប់សាក្សី។ តើលោកគិតដូម្ដេចអំពីមតិយោបល់របស់ចៅក្រម? នេះហើយ១មិនគប្បីដាក់រឿងក្ដីឲ្យសាក្សីសម្រេចទេ។ យើងគប្បីតែដាក់ខ្លឹមសារនៃការ

ចោទប្រកាន់នៃរបកគំហើញជូនសាក្សីឲ្យគាត់បញ្ជាក់។ គាត់អាចបញ្ជាក់នៅក្នុងសាលក្រម ថាខ្ញុំសួរលោកថា លោកមានឥទ្ធិពលដ៏សំខាន់ទាក់ទងទៅនឹងការចាប់មនុស្សនៅស-- មកស-២១ ហើយអាចអង្គហេតុដែលចោទប្រកាន់ ដែលអាចរកឃើញនៅក្នុងអង្គហេតុ។ ប៉ុន្តែមិនត្រូវសួរសាក្សីឲ្យសាក្សីថា តើសាក្សីគិតដូចម្តេចអំពីមតិយោបល់របស់ចៅក្រមនេះ គឺអាចធ្វើឲ្យមានទឡ្ហីករណ៍ធ្វើឲ្យគាត់មានការស្រពេចស្រពិល។

អ៊ីចឹងហើយបើយើងៗធ្វើបែបនេះគឺថាឲ្យគាត់ឆ្លើយដោយត្រង់ គឺមិនគប្បីឲ្យគាត់គិតពិចារណាទៅលើមតិរបស់អ្នកដទៃនោះទេ។ បាទ សូមអរគុណ។

[១១:៣៣:៤៦]

**ប្រធានអង្គជំនុំ៖**

លោក ម៉ៃខល កាណាវាស មុន! ដើម្បីបញ្ចប់បញ្ហាឲ្យ-- ចុងក្រោយគឺទៅមេធាវី ផេសមិន។ សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមដោយសង្ខេបទេ ខ្ញុំមិនចង់ខាតពេលទេ។ សំខាន់ណាស់ ឲ្យច្បាស់លាស់គឺយើងបានដាក់សំណើពីមុន គឺថាសុំសហព្រះរាជអាជ្ញាបញ្ជាក់ឲ្យច្បាស់ ថាអ្វីដែលគាត់ជឿជាក់ថាសាក្សីមិនស្មោះត្រង់នោះ។ សហព្រះរាជអាជ្ញាឆ្លើយនោះ គឺថាតាមពិតយើងមិនសួរប្រើភស្តុតាងណាមួយដែលជឿជាក់សាក្សីមិនស្មោះត្រង់ទេ ប៉ុន្តែបើយើងចូលដល់ចំណុចជាក់លាក់ ឥឡូវព្រះរាជអាជ្ញាប្រាប់យើងថា រកនឹកមើលនៅក្នុងប្រតិចារឹកដែលជាមូលហេតុដែលយើងត្រូវតែសួរសំណួរទូទៅវិញ។ សហព្រះរាជអាជ្ញាហើយនិងអង្គជំនុំជម្រះបានសន្និដ្ឋានថា សាក្សីមិនសូវស្មោះត្រង់។ តែឥឡូវយើងគិតដូចម្តេច? ឲ្យគាត់ឆ្លើយ ផ្អែកលើចម្លើយ យើងអាចថាបានចម្លើយជាក់លាក់ពីសាក្សីរូបនេះ។

[១១:៣៤:៤៨]

អ៊ីចឹងហើយអ្វីដែលយើងសួរសំណួរទូទៅមិនគប្បីមានការបង្ខំឲ្យយើងថា អ្វីដែលព្រះរាជអាជ្ញាមាននៅក្នុងគំនិតក្នុងការកំណត់ឲ្យសាក្សីមិនស្មោះត្រង់ ប៉ុន្តែខ្ញុំមិនឃើញថា នៅក្នុងអ្វីដែលខ្ញុំជម្រាបតុលាការវាហាក់ដូចជាៗ ការផ្ទេរការទទួលខុសត្រូវពីប្រាំបី ប្រាំបួនខែមុនដែលយើងមានសវនាការដែលយើងមានបែបប្រតិបក្ខដែលថាឲ្យភាគីតទល់គ្នានោះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ម៉ៃខល ផេសមិន!

[១១:៣៥:២៥]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំព្យាយាមឲ្យធ្វើម៉េច ឲ្យអត្ថប្រយោជន៍ដល់ការជំនុំជម្រះឲ្យសាក្សីគាត់ឆ្លើយទៅនឹងសេចក្តីសន្និដ្ឋានសំខាន់នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះ ដែលខ្ញុំយល់ថា គឺផ្អែកទៅលើការវាយតម្លៃលើអង្គហេតុទាំងអស់នៅក្នុងរឿងក្តីនេះ។

**ប្រធានអង្គជំនុំ៖**

អង្គុយចុះសិនទៅ អង្គជំនុំជម្រះពិចារណាសម្រេចសិន។

[១១:៣៦:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣៧:១៦]

**ប្រធានអង្គជំនុំ៖**

បាទ ក្រោយពីបានពិភាក្សាគ្នា អង្គជំនុំជម្រះសម្រេចថាសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងការតាំងសំណួរចុងក្រោយបង្អស់របស់មេធាវី នួន ជា គឺមានប្រសិទ្ធភាព។ ដូច្នេះសាក្សីមិនចាំបាច់ឆ្លើយតបទៅនឹងសំណួរដែលសួរចុងក្រោយដោយមេធាវី ផេសមិន ចំពោះលោកទេ។ ហើយអង្គជំនុំជម្រះសូមរំឭកលោកមេធាវីថា សូមលោកចៀសវាសនូវការតាំងសំណួរបែបនេះ ហើយសំណួរផ្សេងទៀតអាចប្រព្រឹត្តទៅបានដោយសំណួរជាក់លាក់ពាក់ព័ន្ធទៅនឹងអង្គហេតុទាំងឡាយដែលមានការពាក់ព័ន្ធនឹងការចោទប្រកាន់ចំពោះគាត់រយៈពេលកន្លងមកបាន។ ប៉ុន្តែមិនឲ្យគាត់ធ្វើគំនិត មតិយោបល់ជាសេចក្តីសន្និដ្ឋានទេ។ ហើយដើម្បីបញ្ជាក់ច្បាស់ សូមឲ្យលោកស្រី ស៊ីលវៀ ខាតវ៉ាយថ៍ បញ្ជាក់បញ្ហានេះបន្ថែមទៀត ពីព្រោះបញ្ហានេះក៏វាជារឿងស្មុគស្មាញដែរ។

បាទ សូមអញ្ជើញលោកស្រីចៅក្រម!

[១១:៣៨:២៧]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ សេចក្តីសង្ខេប ដែលលោកប្រធានទើបតែសម្រេចឡើង គឺថាអង្គ

ជំនុំជម្រះជំនុំជម្រះជំទាស់ ឬក៏រក្សានូវអ្វីដែលសហព្រះរាជអាជ្ញាបានជំទាស់នោះ បញ្ហានៃការអាចតាំងសំណួរទៅសាក្សីរូបនេះៗ គឺអាចសន្និដ្ឋានទៅលើការចោទប្រកាន់របស់មេធាវីការពារក្ដី នួន ជា ដែលឱ្យសាក្សីនេះធ្វើការផ្ដល់មតិយោបល់។ មិនតម្រូវឱ្យសាក្សីរូបនេះ ធ្វើការផ្ដល់មតិយោបល់មកដល់សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះទេ។ អ្វី-- តាមការអនុញ្ញាតរបស់លោកប្រធាន នៅក្នុងដំណាក់កាលនេះគឺថាមានការធ្វើឱ្យអង្គជំនុំជម្រះមានការ មានភាពច្របូកច្របល់ដោយមានការជំទាស់ ហើយបន្ទាប់មកមានការបដិសេធតបទៅវិញ។

ប្រសិនណាជា លោក លោកស្រីចង់ជំទាស់ ឬក៏ការបដិសេធទៅវិញ គឺថាសូមឱ្យផ្ដល់ឱកាសទៅឱ្យភាគីដែលបានលើកឡើងធ្វើការជំទាស់តវ៉ាសាជាថ្មីឡើងវិញ។ សូមអរគុណ។ សូមបញ្ជាក់ឱ្យច្បាស់ចំណុចនេះ។

[១១:៣៩:០៣]

**លោក ម៉ៃខល ផេសមិន៖**

សំណើដែលលើកនោះ ខ្ញុំចង់បង្ហាញជូនអង្គជំនុំជម្រះនូវផ្នែកមួយនៃឯកសារភាពយន្តខ្លីទេ ដែលមានការសម្ភាសយ៉ាងវែងជាមួយសាក្សីរូបនេះ។ ខ្ញុំដឹងថា ខ្សែភាពយន្តគឺនឹងត្រូវយកចាក់បង្ហាញហើយ។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីបង្ហាញផ្នែកមួយដ៏ខ្លីទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីណ្សៀម ស្មីត៖**

លោកប្រធាន ខ្ញុំមិនដែលបានឃើញ ឬក៏បានឮអំពីឯកសារនេះពីមុនមកនោះទេ។ ខ្ញុំគិតថាឯកសារដែលមេធាវីការពារក្ដីលើកឡើងមិនមាននៅក្នុងសំណុំរឿងនោះទេ។ ហើយវាអាចមាននៅក្នុងបញ្ជីដែលគាត់ទើបប្រគល់មកពីយប់មិញ។

[១១:៤១:០៤]

លោក លោកស្រីចៅក្រម ទាក់ទងទៅនឹងការដាក់ឯកសារថ្មីនៅចំពោះមុខអង្គជំនុំជម្រះ វិធាន ៨៧(៤) គឺឱ្យមេធាវីការពារក្ដីបង្ហាញឱ្យឃើញថាហេតុអីត្រូវ មិនដាក់ឯកសារហ្នឹងឱ្យបានទាន់ពេលវេលានោះ។ ខ្ញុំ យើងខ្ញុំយល់ឃើញថា ឯកសារខ្សែភាពយន្តនេះ គឺថាចេញមកនៅពេលណាទេ ហើយមិនដឹងថាមាននៅក្នុងសំណុំរឿង ឬក៏យ៉ាងណាទេ។ ប៉ុន្តែមេធាវីការពារក្ដីត្រូវតែឆ្លើយតបទៅនឹងលក្ខខណ្ឌ

ដែលបានកំណត់នៅក្នុងវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ដែលអនុញ្ញាតឲ្យ-- ដែលថាចែងថា "ប្រសិនបើណាជាភាគីណាមួយដាក់ឯកសារថ្មីៗ ធ្វើឲ្យមានការភ្ញាក់ផ្អើលដោយមិនមានការចាត់ចែងឲ្យបានគ្រប់គ្រាន់នោះទេ។ នោះ គឺថាត្រូវតែកំណត់ឲ្យបានច្បាស់លាស់"។ ដែលថាឯកសារនេះ អាចនឹងត្រូវធ្វើការបង្ហាញនៅពេលវេលាក្រោយ រហូតទាល់តែភាគីបង្ហាញឯកសានេះ ឲ្យបានច្បាស់លាស់ជាមុនសិន។

[១១:៤២:១១]

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំជឿជាក់ថា ឯកសារនេះ គឺជាខ្សែភាពយន្តមួយដែលមានចំណងជើងថា "ឌី ម៉ាស់ អូហ្វ ហេល" នេះ-- "ម៉ាស្ទើ អូហ្វ ឌី ហ្វក់ជ៍ អូហ្វ ហេល"។ ខ្ញុំចង់បង្ហាញជូនសាក្សី ខ្ញុំមិនចង់ដាក់នៅចំពោះមុខអង្គជំនុំជម្រះទេ។ ពីព្រោះថា វិធាន៨៧(៤) មិនអនុវត្តចំណុចនេះទេ។ ខ្ញុំសូមបង្ហាញតែផ្នែកខ្លីទេ។ ខ្ញុំចង់ដាក់បែបនេះ ដើម្បីជជីកសួរដេញដោលរកឲ្យឃើញនូវភាពស្មោះត្រង់របស់សាក្សីរូបនេះ។ ហើយបើខ្ញុំចាំមិនច្រឡំ។ ឧទាហរណ៍ នៅពេលដែលមានការសម្ភាសដោយការចោទសួរទៅលើ ឌី.ស៊ី.ខេម នេះ គឺថាទាំងសហព្រះរាជអាជ្ញា ក៏ដូចមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានយកគេហទំព័រយកមកប្រើប្រាស់ ដែលមិនស្ថិតនៅក្នុងសំណុំរឿងនោះទេ។ ហើយខ្ញុំឃើញមិនមានការព្រមានណាមួយទៅដល់សហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងទៅនឹងការប្រើ*វេបសាយ*របស់ ឌី.ស៊ី.ខេម នោះទេ។

[១១:៤៣:២៦]

ដោយយកគេហទំព័រនេះ មកធ្វើការជជីកសួរដេញដោលដល់សាក្សី។ គឺទាំងសហព្រះរាជអាជ្ញា ទាំងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ គឺខ្ញុំមិនចង់យកឯកសារនេះ មកដាក់មុខអង្គជំនុំជម្រះដើម្បីបង្ហាញនូវយថាភាពនៃឯកសារនេះនោះទេ។ ខ្ញុំចង់ឲ្យតែសាក្សីរូបនេះ ឆ្លើយតបទៅនឹងអ្វីដែលគាត់បានឆ្លើយនៅក្នុងឯកសារនេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១១:៤៤:០៣]

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន យើងខ្ញុំយល់ស្របដែលថាមានកាលៈទេសៈមួយចំនួនដែលនឹងអាចកើតមានឡើង

នៅពេលដែលឯកសារណាមួយ វាមានសារៈសំខាន់នៅពេលក្រោយៗមកទៀត ទាក់ទងទៅនឹងយថាភាពរបស់ឯកសារនេះ។ យើងខ្ញុំមិនស្នើសុំថា គ្រប់ឯកសារទាំងអស់ត្រូវតែដាក់មុខអង្គជំនុំជម្រះនោះទេ។ ជាការពិតហើយ មេធាវីការពារក្តីរបស់ នួន ជា បានដឹងច្បាស់ហើយ ថាតើគោលបំណងអីដែលគាត់ចង់ប្រើឯកសារនេះ ហើយហេតុម៉េចគាត់មិនដាក់នៅចំពោះមុខអង្គជំនុំជម្រះ? គាត់លើកឡើងថាគាត់ចង់សួរតទល់តែសាក្សីតែប៉ុណ្ណោះ។ ប៉ុន្តែខ្ញុំដឹងថា ខ្សែភាពយន្តរបស់ រិទ្ធី ផាន គឺថាបានដាក់បញ្ចូលក្នុងបញ្ជីទើបតែពីយប់មិញនេះ ហើយដែលមេធាវីការពារក្តីរូបនេះ នឹងប្រើប្រាស់នៅក្នុងថ្ងៃនេះ។ ហើយខ្ញុំដឹងថា ឯកសារភាពយន្តនេះ មិនមាននៅលើបញ្ជីឯកសាររបស់គាត់ទេ។

[១១:៤៥:០០]

ខ្ញុំយល់ឃើញថា គាត់មិនអនុវត្តទៅតាមការបង្គាប់របស់អង្គជំនុំជម្រះទេ ដែលថាឯកសារយ៉ាងហោចណាស់ ឬក៏ខ្លីបំផុត ត្រូវដាក់ឲ្យបានរយៈពេល២៤ម៉ោង នៅមុខអង្គជំនុំជម្រះ។ ដូច្នេះនេះ គឺជាបញ្ហានៃការជូនដំណឹងទេ។ មេធាវីការពារក្តីមានឯកសារនេះ ប៉ុន្តែមិនបានដឹងបញ្ចូលនៅក្នុងបញ្ជីឯកសារនោះទេ។ ហេតុដូច្នេះ នៅក្នុងផ្នែក-- នៅក្នុងពេលនេះវាអាចមានការពាក់ព័ន្ធ ប៉ុន្តែយើងខ្ញុំសូមជំទាស់រហូតដល់ពេលយើងខ្ញុំបានឃើញឯកសារនេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

[១១:៤៥:៣៩]

**លោក ម៉ៃខល ផេសមិន៖**

ហេតុផលដែលថា មិនមានឯកសារនេះនៅលើបញ្ជីឯកសារ ដោយសារវាមិនមានលេខយោង។

**ប្រធានអង្គជំនុំ៖**

បាទការជំទាស់របស់មេធាវី-- របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ត្រឹមត្រូវ មានអានុភាព។ ដូច្នេះ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យដាក់បញ្ចាំងនូវខ្សែភាពយន្តនោះ ទោះបីផ្នែកណាមួយក៏ដោយនាពេលនេះទេ។

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំ យើងខ្ញុំសូមស្នើសុំឲ្យមានការបញ្ជាក់ឲ្យបានច្បាស់ថាតើនៅពេលណាទើបខ្ញុំអាចបង្ហាញផ្នែកខ្លីនៃខ្សែភាពយន្តនេះបាន ឬក៏សហព្រះរាជអាជ្ញាចង់បានខ្សែភាពយន្តថតចម្លង។ ផ្នែកខ្លីនេះគឺថា នឹង

សូមបង្ហាញតែមួយនាទីទេ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤៧:៤១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ខាតវ៉ាយថ៍! អង្គជំនុំជម្រះប្រគល់ភារៈជូនលោកស្រីដើម្បីឆ្លើយតបទៅនឹង និងបំភ្លឺទៅនឹងអ្វីដែលបានលើកឡើងដោយមេធាវី ផេសមិន មេធាវីអន្តរជាតិការពារក្តីលោក នួន ជា។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ មេធាវីការពារក្តីត្រូវដាក់ពាក្យសុំ ដោយអនុវត្តតាមវិធាន៨៧(៤) ក្នុងការដាក់ឯកសារថ្មី។ លោក ផេសមិន យល់ទេ? សូមអរគុណ។ ប្រសិនណាជាពាក្យសុំនេះ គឺថាទទួលបាននូវជោគជ័យត្រូវបានទទួលការទទួលយក នោះនឹងអាចបង្ហាញនូវខ្សែភាពយន្តនេះបានហើយ។ តែលោកត្រូវតែអនុវត្តឲ្យស្របទៅនឹងវិធាន៨៧(៤)នេះ។ សូមអរគុណ។

[១១:៤៨:៥២]

**លោក ម៉ៃខល ផេសមិន៖**

យើងខ្ញុំត្រឡប់ចូលមកបញ្ហានេះបន្ទាប់ពីសម្រាកពិសាបាយថ្ងៃត្រង់ហើយ។ ដោយសារតែខ្ញុំបានបានទទួលដំណឹងថា យើងខ្ញុំមិនបានដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ ដើម្បីក្នុងគោលបំណងនៃការសួរតទល់សាក្សីនេះ។ បើសិនណាជាព័ត៌មាននេះមិនត្រឹមត្រូវ ឬក៏យ៉ាងណានោះ-- ខ្ញុំហាក់បីដូចជាច្របូកច្របល់បន្តិច សូមជម្រាបជូនអង្គជំនុំជម្រះ។ ខ្ញុំសូមបន្តការតាំងសំណួរតទៅទៀត។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ឌុច នៅថ្ងៃចុងក្រោយបំផុតនៃសវនាការកាត់សេចក្តីរបស់រូបលោក លោកស្នើសុំឲ្យមានការដោះលែងរូបលោកទាំងស្រុងតែម្តង ហើយមេធាវីរបស់លោក ការ សាវុត្ថ នៅពេលនោះបាននិយាយថា គឺថាត្រូវតែដោះលែងរូបលោកឲ្យផុតពីការចោទប្រកាន់ ដោយសារតែលោកធ្វើតាមបង្គាប់របស់បក្សកុម្មុយនីស្តកម្ពុជា ហើយបក្សកុម្មុយនីស្តកម្ពុជាគឺជាឧក្រិដ្ឋជនដែលស្ថិតនៅខាងក្រោយវាំងននេះ។ តើលោកអាចពន្យល់ទៅតុលាការបានទេ ថាតើចំណុចនេះវាមានន័យយ៉ាងដូចម្តេចដែរ?

[១១:៥០:៤២]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ចំណុចនេះ ខ្ញុំពិតជាបានទាមទារអ៊ីចឹងមែន។ ដោយឈរលើគោលគំនិតច្បាប់នៃការបង្កើត អ.វ.ត.ក ដែលកាត់ទោសតែអ្នកទទួលខុសត្រូវខ្ពស់បំផុត និងអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យ។ នេះខ្ញុំយល់ឃើញអ៊ីចឹង ទើបខ្ញុំទាមទារថាខ្ញុំមិនមែនស្ថិតនៅក្នុងអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតទេ។ ព្រោះអ្នកទទួលខុសត្រូវខ្ពស់បំផុតពីលើខ្ញុំគឺមាន សុន សេន និង នួន ជា។ ពីលើនោះទៀតមាន ប៉ុល ពត។ នេះ ខ្ញុំពិតជាទាមទារអ៊ីចឹងមែន។

[១១:៥១:៣៧]

**ស៖** ឌុច ខ្ញុំសូមសួរលោកដូច្នេះ។ តើលោកមាននិន្នាការណាមួយចង់រួចផុតពីការទទួលខុសត្រូវដែរឬទេ? ហើយខ្ញុំសូមសួរលោកទៀតថា លោកបានទម្លាក់កំហុសមកលើ នួន ជា ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅមន្ទីរស-២១ ដែលជាផ្នែកមួយនៃការកាប់សម្លាប់នេះ ហើយខ្ញុំសូមសួរលោកថា នួន ជា មិនដែលគ្រប់គ្រងស-២១ ឬក៏បង្គាប់បញ្ជាទៅដល់ស-២១ ទេ។ នួន ជា គ្រាន់តែជាមនុស្សម្នាក់ហើយមេដឹកនាំម្នាក់ ហើយលោកបានជ្រើសរើសរូបគាត់មកធ្វើការទម្លាក់កំហុស នៅពេលដែល សុន សេន បាត់ខ្លួនទៅនោះ។ ខ្ញុំសូមចោទសំណួរនេះទៅលោក ហើយលោកអាចមានប្រតិកម្មតបមកវិញដែលថាលោកមិនអាចយកការទទួលខុសត្រូវនេះបានទេ ជាការទទួលខុសត្រូវទៅលើអំពើរបស់លោកនេះបានទេ។ តាមការពិតលោកគឺជាមនុស្សភូតកុហក ហើយលោកបានប្រឌិតនូវចម្លើយរបស់លោកថែមទៀតផង។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកតំណាងព្រះរាជអាជ្ញា!

[១១:៥៣:១៤]

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន ការជំទាស់នេះគឺថា សំណួរនេះគឺជាសំណួរមួយលក្ខណៈធ្ងន់ធ្ងរ ហើយដែលវាធ្វើឱ្យមួយក្នុងចំណោមប្រាំ-- គឺដូច្នេះអ្វីដែលខ្ញុំស្នើសុំគឺថា សុំឱ្យបំបែកសំណួរទាំងប្រាំនេះឱ្យទៅជាមួយសំណួរៗម្តង ខ្លីៗបានហើយ ហើយការដែលចោទប្រកាន់ថា សាក្សីរូបនេះគឺជាមនុស្សកុហកភូតភរនេះគឺជាការចោទប្រកាន់មួយធំធេង ធ្ងន់ធ្ងរណាស់។ គួរតែបញ្ជាក់ថាតើគាត់ប្រាប់កន្លែងណាដែលមិនច្បាស់ផ្តល់សក្ខីកម្មកន្លែងណាដែលមិនច្បាស់លាស់ មិនស្មោះត្រង់។ មិនគ្រាន់តែក្រោកឡើងនិយាយថា អ្នកឯងជាមនុស្សកុហកភូតភរ។ ដូច្នេះ វាហាក់បីដូចជា ឃ្លាតចាកឆ្ងាយពេក ដើម្បីឱ្យទទួលបាននូវចម្លើយ

ដ៏ស្មោះត្រង់ពិតប្រាកដនោះ។

[១១:៥៤:២០]

ខ្ញុំសូមឲ្យមេធាវីការពារក្តី បំបែកសំណួរនេះខ្លីៗ ដោយលើកនូវចំណុចជាក់លាក់ៗណាមួយមកចោទសួរសាក្សីរូបនេះ។ សូមអរគុណ។

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំនឹងធ្វើតាមសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ។ ខ្ញុំនឹងបំបែកសំណួរដែលខ្ញុំបានសួរ។

**ប្រធានអង្គជំនុំ៖**

អរគុណច្រើនណាស់ដែលលោកបានមានការភ្ញាក់រឭក ហើយដឹងពីបញ្ហានេះ! ប៉ុន្តែមុននឹងផ្តល់វេទិកាឲ្យលោក គឺមេធាវីដែលប្រើពាក្យនិយាយទៅកាន់សាក្សីថា និយាយកុហក។ ពាក្យសម្តីបែបនេះរបស់មេធាវីមិនត្រូវលើកឡើងនៅពេលនេះទៅកាន់សាក្សីដូច្នេះទេ។ អង្គជំនុំជម្រះសូមជម្រាបលោកមេធាវីថា ការវាយតម្លៃទៅលើភស្តុតាងដែលបានដេញដោល ដែលមាននៅក្នុងឯកសារ ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះជាភារកិច្ចរបស់អង្គជំនុំជម្រះពិនិត្យពិចារណាវាយតម្លៃ ជឿ ឬមិនជឿ ដោយឥស្សរចិត្តរបស់ខ្លួន នៅក្នុងអំឡុងពេលពិចារណាសម្រេចសេចក្តី ក្រោយពីភាគីទាំងអស់បានធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល។

[១១:៥៦:០៦]

អង្គជំនុំជម្រះបានស្តាប់ពាក្យពេចន៍របស់លោក ដែលនិយាយបែបនេះចំនួនពីរលើកមកហើយទាំងពីម្សិលមិញ ទាំងថ្ងៃនេះ។ អង្គជំនុំជម្រះយល់ថា លោកមេធាវីដែលមានវិជ្ជាជីវៈជាមេធាវីអន្តរជាតិមិនគួរប្រើប្រាស់នូវពាក្យពេចន៍ទាំងអស់នេះ ដើម្បីឲ្យធ្វើការផ្សព្វផ្សាយនូវវប្បធម៌នេះនៅក្នុងប្រព័ន្ធ-- មានឥទ្ធិពលដល់ប្រព័ន្ធតុលាការជាតិទេ។

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមសង្ខេបដើម្បីផ្តល់ឱកាសឲ្យសាក្សីរូបនេះឆ្លើយតប។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ឌុច រឿងដែលថាលោកមិនឆ្លើយមិនស្មោះត្រង់ ហើយលោកបានទម្លាក់កំហុសមកលើ នួន ជា ចំពោះឧក្រិដ្ឋកម្មដែលលោកបានប្រព្រឹត្តឡើង ដែលលោកគឺជាអ្នកទទួលខុសត្រូវដោយផ្ទាល់តែម្តង។

**លោក វីល្លៀម ស្មីត៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១១:៥៧:៤៦]

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន គឺថាយើងកំពុងតែចូលទៅចំណុចមួយទៀត។ ខ្ញុំសូមលើកសំណួរថា "លោកឯង គឺជាមនុស្សមិនស្មោះត្រង់។ ហើយលោកបានទម្លាក់កំហុសមកលើ នួន ជា ចំពោះសកម្មភាពរបស់លោក"។ អ្វីដែលខ្ញុំស្នើសុំគឺថា មេធាវីការពារក្តី គេថា លោកឆ្លើយមិនស្មោះត្រង់ទេ នៅពេលដែលលោកផ្តល់ចម្លើយពាក់ព័ន្ធទៅនឹងការពាក់ព័ន្ធរបស់លោក នួន ជា នៅស-២១។ ហើយទាក់ទងនឹងភាពស្មោះត្រង់ គឺទាក់ទងទៅនឹងចំណុចជាក់លាក់ គឺមិនមែនទាក់ទងទៅនឹងចំណុចទូទៅនោះទេ។

[១១:៥៨:២៧]

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ឌុច លោកយល់សំណួរខ្ញុំដែរ?

**ប្រធានអង្គជំនុំ៖**

លោកអាចតបតនឹងការជំទាស់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិទេ? បើមិនជំទាស់ទេ អង្គជំនុំជម្រះសម្រេចថា ការជំទាស់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិមានប្រសិទ្ធភាព។ សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរ ដែលសួរដោយមេធាវីអន្តរជាតិការពារក្តីចុងក្រោយ-- សំណួរចុងក្រោយរបស់លោកមេធាវីការពារក្តីអន្តរជាតិ នួន ជា ដែលបានសួរលោកនេះទេ។

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន ខ្ញុំគិតថា សំណួររបស់ខ្ញុំគឺច្បាស់លាស់ហើយ។ ខ្ញុំបានលើកឡើងថា សាក្សីរូបនេះគឺមិនស្មោះត្រង់ទេ នៅពេលដែលគាត់និយាយអំពីតួនាទីរបស់ នួន ជា ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើង គឺថាគាត់បានទម្លាក់កំហុសមកលើកូនក្តីរបស់យើងខ្ញុំ ចំពោះអំពើដែលគាត់បានប្រព្រឹត្ត។ ហើយគាត់មាននិន្នាការទម្លាក់កំហុសបែបនេះ គឺថានៅពេញមួយជីវិតរបស់គាត់ហើយ។ ដូច្នេះ ខ្ញុំសូម-- ដូចទើបខ្ញុំសួរសំណួរនេះ។

[១១:៥៩:៤៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចរួចហើយ មិនឲ្យឆ្លើយតបទេ ចំពោះសំណួរនេះ ឲ្យ ទាញឲ្យ ទីមួយគឺប្រមាថដល់សាក្សី នៅតែប្រើពាក្យ “កុហក” នៅតែប្រើពាក្យ “ភូត”។ កុំដាក់សម្ពាធទៅលើសាក្សី។

បញ្ហាទីពីរឲ្យសាក្សីឆ្លើយជាលទ្ធផលនូវសេចក្តីសន្និដ្ឋាននូវការយល់ដឹងផ្ទាល់ខ្លួន ការវាយតម្លៃលើភស្តុតាងដេញដោលនេះ គឺជាសមត្ថកិច្ចរបស់អង្គជំនុំជម្រះ ដែលនឹងត្រូវពិនិត្យពិចារណាសម្រេចនៅក្នុងអំឡុងពេលគិតបន្ទាប់ពីធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលដោយភាគី។

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន ខ្ញុំមិនមានសំណួរតទៅទៀតទេ គឺថាដើម្បីជាប្រតិចារឹក គឺថាខ្ញុំមិនមែនជាមនុស្សម្នាក់ដែលប្រើពាក្យនេះមុនគេទេ សាក្សីបានប្រើពាក្យនេះមកដាក់ខ្ញុំមុនគេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី ម៉ៃខល កាណាវាស!

[១២:០០:៥៨]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមផ្តល់មតិយោបល់លើបញ្ហានេះ គឺថាយើងនៅពិភាក្សាគ្នាពីរបីឆ្នាំឯណោះនៅក្នុងសវនាការនេះ។ ដូច្នេះសម្រាប់ខ្ញុំគឺថា សហព្រះរាជអាជ្ញាខ្លួនគាត់នៅពេលបើកធ្វើការសេចក្តីបើក គាត់បានហៅជនជាប់ចោទថាជាមេឃាតក នោះជាការលើកឡើងមិនត្រឹមត្រូវទេ។ ដូច្នេះកាលដែលយើងគ្រាន់តែលើកថាគាត់ឆ្លើយស្មោះត្រង់ មិនស្មោះត្រង់ សំណើសុំដោយគោរពរបស់ខ្ញុំ គឺថាវាមិនមានជាបញ្ហាត្រឹមត្រូវនោះទេ។ យើងថា ខ្ញុំយល់ស្របជាមួយសហព្រះរាជអាជ្ញាអាចរៀបសំណួរឡើងវិញនេះ គឺជាតាក់តិកនៃការចោទសួរ។ ដូច្នេះសំណួរខ្លះនោះ គឺថាអាចនឹងគ្រាន់តែបំបែកវាដើម្បីឲ្យមានលក្ខណៈច្បាស់លាស់។ ដូច្នេះបើសិនណាជាមិនបានទទួលចម្លើយទេ យើងអាចកែតម្រូវសំណួរនៅផ្នែកទីមួយ ផ្នែកពីរយ៉ាងដូច្នេះបាន នេះទីមួយ។ ទីពីរ ទាក់ទងទៅនឹងខ្សែភាពយន្តវិញនេះ គឺសម្រាប់យើងខ្ញុំ គឺយើងខ្ញុំយល់ឃើញថា តាំងបានចេញតាំងពីខែមករា ឆ្នាំ២០១២ មកម្ល៉េះ នៅប្រទេសបារាំងហ្នឹង។ ហើយនៅក្នុងប្រទេសកម្ពុជា ខ្ញុំដឹងថាខ្សែភាពយន្តនេះបានបង្ហាញ បញ្ចាំងជូនខ្សែភាពយន្តសាធារណៈតាំងពីមុន ឌុច ចូលខ្លួនមកម្ល៉េះ។ ដូច្នេះ វាជាការត្រឹមត្រូវហើយ ដែលអាចអនុញ្ញាតឲ្យអង្គ

ជំនុំជម្រះពិចារណាក្នុងពេលសម្រាកពិសាបាយថ្ងៃត្រង់។ ដូច្នេះ ខ្ញុំស្នើសុំឲ្យអង្គជំនុំជម្រះមេត្តាពិចារណាទទួលយកនូវខ្សែភាពយន្តនេះដើម្បីធ្វើការបញ្ចាំងខ្សែភាពយន្តឲ្យទាំងភាគីទាំងអស់ សហព្រះរាជអាជ្ញាក៏ដូចជាភាគីដទៃទៀតបានយល់ជ្រាប ហើយនិងដើម្បីជាស្មារតីនៃការបង្ហាញនូវការពិតថាតើដំណាក់កាលនីតិវិធីនេះវាមានប្រសិទ្ធភាពយ៉ាងណានោះ? ហើយក៏អនុញ្ញាតឲ្យអង្គជំនុំជម្រះពិចារណាសម្រេចឡើងវិញ។ ដូច្នេះ សំណើសុំរបស់ខ្ញុំគឺស្នើសុំនូវៗអនុវត្តនូវវិធាន៨៧(៤) នៅគ្រប់សំណុំទាំងអស់។ សូមអរគុណលោកប្រធាន។

[១២:០៣:១០]

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកមេធាវី ម៉ៃខល កាណាវាស អ៎! ម៉ៃខល ផេសមិន!

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំសូមគាំទ្រចំពោះសំណើសុំរបស់មេធាវីការពារក្តី អៀង សារី។ គឺថាយើងមិនចាំបាច់ដាក់សំណើសុំទៅលើចំណុចនេះដូចដែលសហព្រះរាជអាជ្ញា ក៏ដូចមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានយកគេហទំព័ររបស់ ឌី.ស៊ី.ខេម មកប្រើប្រាស់ដោយមិនសុំការអនុញ្ញាតពីអង្គជំនុំជម្រះនោះទេ។ ហើយបើសិនណាជាវាមានការបញ្ហាណាមួយ យើងខ្ញុំសុំឲ្យមានការណែនាំពីអង្គជំនុំជម្រះ។

យើងខ្ញុំបានទទួលខ្សែអាត់ចម្លងភាពយន្តនេះ ហ្វីលចម្លងនៃខ្សែភាពយន្តនេះ ហើយខ្ញុំគិតថាទទួលបានពីរសប្តាហ៍មកហើយ ដើម្បីឲ្យបានច្បាស់លាស់គឺថាខ្ញុំនៅរសៀលនេះ លោកមេធាវី ហ្សាស្តេប៉ៅ គឺថាគាត់នឹងសួរទៅលើប្រធានបទផ្សេង ហើយបន្ទាប់មកមេធាវីការពារក្តីជាតិនៃក្រុមរបស់យើងខ្ញុំនឹងសួរបន្តទៅទៀត។ តែពេលនេះ គឺថាខ្ញុំសូមបញ្ចប់សំណួរខ្ញុំត្រឹមប៉ុណ្ណោះ ប៉ុន្តែក្រុមរបស់ខ្ញុំមិនទាន់ចប់នៅឡើយទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១២:០៥:០៥]

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ជាការពិតហើយ អ្វីដែលមេធាវីការពារក្តី អៀង សារី បានលើកឡើង គឺត្រឹមត្រូវ ការព្រួយបារម្ភរបស់ខ្ញុំនោះ គឺសំណួរចុងក្រោយរបស់ នួន ជា គឺថាគាត់មិនត្រូវដាក់

ការតាំងសំណួរទៅលើអង្គហេតុណាមួយជាក់លាក់-- ត្រូវដាក់អង្គហេតុណាមួយជាក់លាក់យកមកសួរមុននឹងនិយាយថាគាត់ឆ្លើយមិនពិត ឬក៏ថាមុននឹងថាសាក្សីនេះរូបនេះកុហកនោះ។ ដើម្បីឆ្លើយតបទៅនឹងពាក្យថា "មិនស្មោះត្រង់"នេះ គឺជាការស្មានទៅវិញនោះទេ។

[១២:០៥:៤៧]

ទាក់ទងទៅនឹងខ្សែភាពយន្តវិញ ការព្រួយបារម្ភរបស់យើងខ្ញុំ គឺដូចថាមិនទាន់មានការសំណើសុំនៅលើបញ្ជីឯកសារដែលត្រូវដាក់នៅក្នុងបញ្ជីឯកសារនោះនៅឡើយនោះទេ។ ដូច្នេះ ខ្ញុំសូមជំទាស់។ ហើយសុំសំណើសុំឱ្យមេធាវីការពារក្តី ដាក់សំណើសុំទៅលើបញ្ជីឯកសារនោះ ទោះណាមិនមានលេខឯកសារយោងក៏ដោយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំគ្រាន់តែលើកមតិខ្លីទេ ពាក់ព័ន្ធនឹងការបញ្ចាំងឯកសារនៅក្នុងវេបសាយរបស់ ឌី.ស៊ី.ខេម។ ជាការពិត លោក លោកស្រីចៅក្រមបានធ្លាប់អនុញ្ញាតពិតប្រាកដមែននៅពេលដែលសួរទៅលើសាក្សីមកពីខាង ឌី.ស៊ី.ខេម ក៏ប៉ុន្តែក្រោយពីពេលនោះ លោកចៅក្រមប្រធានបានរំឭកជាញឹកញាប់ទៅដល់ភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ ឱ្យដាក់ឯកសារសុំការអនុញ្ញាតជាមុន មុននឹងមានការលើកឯកសារនោះយកមកប្រើប្រាស់នៅក្នុងសវនាការនេះ នេះវាមិនមែនជាតែម្តង ឬក៏ពីរដងទេ គឺលោកចៅក្រមបានរំឭជាញឹកញាប់ ហើយភាគីគួរតែគោរពទៅតាមអ្វីដែលជាវិធានដែលត្រូវតែអនុវត្ត។ ហើយដែលលោក លោកស្រីចៅក្រមបានរំឭកនេះ។

[១២:០៧:១៧]

អ៊ីចឹងចំពោះករណីខ្សែភាពយន្តរបស់លោក រិទ្ធី ប៉ាន់ ក៏ដូចគ្នាដែរ លោកមេធាវីអន្តរជាតិការពារក្តីឱ្យលោក នួន ជា លោកគួរតែដាក់សំណើសុំជាមុន ដើម្បីសុំឱ្យមានការអនុញ្ញាតពីចៅក្រម-- លោកចៅក្រមដើម្បីយកមកប្រើប្រាស់នៅក្នុងពេលនេះដែរ។ សូមអរគុណ។

[១២:០៧:៤១]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំគ្រាន់តែចង់ថែមបញ្ហាពីរ ទាក់ទងទៅនឹងគេហទំព័រ ឌី.ស៊ី.ខេម គេថាមិនមែនយើងទេ គឺថាជាក្រុមការពារក្ដីដែលបង្ហាញជាដំបូងទៅដល់លោក វ៉ាន់ ថាន់ដារ៉ា។ អានេះខ្ញុំចង់បញ្ជាក់ចំណុចនេះ។ ហើយមួយទៀតទាក់ទងទៅនឹងឯកសារ ខ្ញុំនៅតែមិនយល់ដដែល គឺថាអង្គជំនុំជម្រះបានកំណត់ច្បាប់ហើយ ថាបានជម្រាបម្សិលមិញហើយ ហើយព្រឹកមិញក៏ដែរថា គឺត្រូវដាក់សំណើ ហើយសុំឲ្យខាងការពារក្ដីដាក់សំណើទៅ ហើយខាងអង្គជំនុំជម្រះ ហើយនិងខាងសហព្រះរាជអាជ្ញានឹងពិចារណា ហើយអ៊ីចឹងគឺនេះបញ្ហាវាៗពិបាក ខ្ញុំឃើញថាហាក់ដូចជា ម៉េចក៏ពិបាកនឹងគោរពវិធានហ្នឹងម៉្លេះ? ព្រោះថាការសម្រេចហ្នឹង វាមានហើយ ហើយរំឭកច្រើនដងណាស់ទៅហើយ ហើយមួយម៉ោងមុនហ្នឹងក៏បានរំឭកដែរ។

[១២:០៨:៤៨]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ អ៊ីចឹងអង្គជំនុំជម្រះបញ្ជាក់ជំហរឡើងវិញ។ ទីមួយ គឺតម្កល់សេចក្ដីសម្រេចដែលបានសម្រេចអម្បាញ់មិញ មុនអំមិញនេះបន្តិចលើបញ្ហាសំណើសុំដាក់ អ្វី!ខ្សែភាពយន្តដោយមេធាវីនួន ជា ដែលបានសម្រេចដោយលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដែលបានទទួលសិទ្ធិពីប្រធានអង្គជំនុំជម្រះក្នុងការបញ្ជាក់ឆ្លើយតបទៅនឹងបញ្ហានេះ ហើយដើម្បីបញ្ជាក់បន្ថែមឲ្យច្បាស់ គឺអង្គជំនុំជម្រះសុំរំឭកនិងជម្រាបដល់ភាគីដែលពាក់ព័ន្ធនឹងរឿងក្ដីថា ចំពោះឯកសារនិងភស្តុតាងថ្មីគឺសុំឲ្យអនុវត្តទៅតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង។ ដើម្បីច្បាស់យើងអានឲ្យភាគស្ដាប់ម្ដងទៀត។

[១២:០៩:៣៥]

វិធាន៨៧ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក វិធាននៃភស្តុតាង ត្រង់ចំណុច៤ចែងថា “ក្នុងអំឡុងពេលសវនាការ តាមគំនិតផ្ដួចផ្ដើមរបស់អង្គជំនុំជម្រះ ឬតាមការស្នើសុំរបស់ភាគី អង្គជំនុំជម្រះអាចកោះហៅ ឬស្ដាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភស្តុតាងថ្មីដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។ គ្រប់ភាគីដែលបានស្នើសុំ ត្រូវបញ្ជាក់ពីមូលហេតុនៃការស្នើសុំនេះឲ្យបានច្បាស់លាស់ អង្គជំនុំជម្រះនឹងធ្វើសេចក្ដីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន៨៧(៣) ខាងលើ។ ភាគីដែលស្នើសុំត្រូវធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថាសក្ខីកម្ម ឬភស្តុតាងដែលបានស្នើសុំនោះ ខ្លួនពុំអាចរកបាននៅមុនពេលចាប់ផ្ដើមជំនុំជម្រះ”។ នេះ

ដើម្បីឲ្យច្បាស់លាស់លើខ្លឹមសារ ដែលមានចែងដូចនេះ ហើយអង្គជំនុំជម្រះអះអាងថា គឺអំណឺះតទៅមិនឃ្លាតពីការអនុវត្តដ៏ត្រឹមត្រូវ និងទៀងទាត់នូវបទប្បញ្ញត្តិដែលមានចែងនៅក្នុងវិធាន៨៧(៤)នេះឡើយ។

ឥឡូវនេះ អង្គជំនុំជម្រះដល់ពេលសមល្មមនឹងសម្រាកពិសាត្រង់ថ្ងៃហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាត្រង់ថ្ងៃ ចាប់ពីពេលនេះទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀល សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ អនុរក្សមន្ទីរឃុំឃាំងអញ្ជើញសាក្សីទៅកាន់បន្ទប់សម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនៅរសៀលនេះ នៅម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវី មៃខល ផេសមិន!

[១២:១១:៣៩]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ កូនក្តីរបស់ខ្ញុំសូមលះបង់សិទ្ធិវត្តមាននៅក្នុងទីនេះ ហើយខ្ញុំសូមជម្រាបថា គាត់ទៅតាមដានសវនាការនៅក្នុងបន្ទប់ខាងក្រោមពីចម្ងាយ លោកប្រធានសូមពិចារណា។

**ប្រធានអង្គជំនុំ៖**

បាទ បានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលធ្វើបានឡើង តាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិមិនចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការនៅក្នុងបន្ទប់សវនាការនេះ ដោយសូមទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមប្រព័ន្ធសោតទស្សន៍ពីបន្ទប់ឃុំខ្លួនមួយនៅខាងក្រោមបន្ទប់សវនាការនេះ ក្នុងអំឡុងពេលសវនាការរសៀលនេះ។ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីរបស់គាត់ ដែលសុំលះបង់សិទ្ធិមិនចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមបន្ទប់សវនាការនេះ តាមរយៈប្រព័ន្ធសោតទស្សន៍ ពេញមួយរសៀលនេះ។

[១២:១២:៣៨]

តែក្រុមមេធាវីការពារក្តីនួន ជា ត្រូវប្រគល់មកឲ្យអង្គជំនុំជម្រះភ្ជាមនូវលិខិតលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការរបស់លោក អៀង សារី-- អ៉ំ របស់លោក នួន ជា ដោយមានផ្តិតមេដៃ ឬក៏ចុះហត្ថលេខា ជាក់ច្បាស់ពីជនជាប់ចោទ។ បង្គាប់ឲ្យផ្នែកសោតទស្សន៍តភ្ជាប់

ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ដែលរៀបចំសម្រាប់គាត់។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងពីររូបទៅកាន់បន្ទប់រង់ចាំខាងក្រោម ហើយនៅរសៀលនេះ បង្គាប់ឲ្យនាំខ្លួនជនជាប់ចោទ ខៀវ សំផន មកកាន់បន្ទប់សវនាការឲ្យបានមុនម៉ោងមួយសាមសិបនាទី។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:១៣ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:០៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោល ចំពោះសាក្សីរូបនេះ អង្គជំនុំជម្រះសូមធ្វើការកត់សម្គាល់អំពីសំណើសុំរបស់មេធាវីការពារក្តីលោក អៀង សារី ហើយនិងលោក មានការគាំទ្រដោយមេធាវីការពារក្តី នួន ជា លើបញ្ហាដាក់ខ្សែភាពយន្តជាផ្ទាល់មាត់។ អង្គជំនុំជម្រះតម្រូវឲ្យមេធាវីដែលមានបំណងក្នុងការដាក់នូវខ្សែភាពយន្តជាឯកសារថ្មីនេះ ជាលាយលក្ខណ៍អក្សរដោយមានអនុវត្តទៅតាមខ្លឹមសារនៃបទប្បញ្ញត្តិដែលមានចែងនៅក្នុងវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង។ ហើយនិងទុកឱកាសដល់ភាគីផ្សេងទៀតក្នុងការធ្វើសារណាតបផងដែរ ប្រសិនបើភាគីផ្សេងទៀតមានបំណងធ្វើដូច្នេះ។ បាទធ្វើហ្នឹងក្នុងរយៈពេលបីថ្ងៃ។

[១៣:៣៤:៣៤]

សូមអញ្ជើញលោកក្រុមមេធាវីការពារក្តីលោក នួន ជា! អង្គជំនុំជម្រះផ្តល់វេទិកាជូនក្រុមមេធាវីការពារក្តី ដើម្បីបន្តការសួរដេញដោលចំពោះសាក្សី។

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** ឌុច ខ្ញុំនឹងសួរសំណួរមួយចំនួនទៅលោក។ លោកដឹងចម្លើយអស់ហើយ ប៉ុន្តែខ្ញុំចង់ឲ្យដឹងច្បាស់ថាតើចម្លើយទាំងអស់នេះមានន័យដូចម្ដេច? សំណួរទីមួយ ថាតើលោកផ្ទាល់ធ្លាប់ចូលរួមការប្រជុំរបស់គណៈមជ្ឈិម ឬក៏គណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ ចាប់ពីឆ្នាំ១៩៧៥ រហូតដល់ ១៩៧៩?

[១៣:៣៥:៣៤]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បក្ខជនធម្មតាមិនចូលរួមប្រជុំជាមួយគណៈមជ្ឈិមទេ ហើយកាន់តែមិនមានសិទ្ធិចូលរួមជាមួយនឹងគណៈអចិន្ត្រៃយ៍មជ្ឈិមទៀត។

**ស៖** ឌុច នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកធ្លាប់អានកំណត់ហេតុអង្គប្រជុំរបស់គណៈមជ្ឈិម ឬក៏គណៈអចិន្ត្រៃយ៍ដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន អត់ទេ។

**ស៖** ប្រហែលជាពីរបីសប្ដាហ៍មុននេះ យើងបានពិភាក្សាលើឯកសារដូចខាងក្រោមនេះជាច្រើនដង។ ខ្ញុំចង់ឲ្យប្រាកដនៅលើបញ្ហានេះ នៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ តើលោកបានអានកំណត់ហេតុគណៈអចិន្ត្រៃយ៍ចុះថ្ងៃទី០៩ តុលា ឆ្នាំ១៩៧៥ ឬក៏កំណត់ហេតុអង្គប្រជុំនៃគណៈអចិន្ត្រៃយ៍ថ្ងៃទី០៣ មីនា ឆ្នាំ១៩៧៦ ដែលមានកំណត់ហេតុហ្នឹងបានដាក់ដេញដោលកាលពីមុននោះ?

[១៣:៣៦:៥៨]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន នៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ខ្ញុំមិនដែលបានឃើញឯកសារនេះទេ។

**ស៖** តើត្រូវដែរឬទេ លោកបានអានឯកសារនោះលើកដំបូងគឺនៅក្នុងដំណាក់កាលស៊ើបអង្កេតនៃរឿងក្ដីរបស់លោក?

**ឆ៖** ឯកសារណាមួយ?

**ស៖** ឯកសារដែលៗអះអាងថា ជាកំណត់ហេតុនៃគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី០៩ តុលា ១៩៧៥ ហើយនិងថ្ងៃទី៣០ មីនា ឆ្នាំ១៩៧៦ បាទពីរនេះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១៣:៣៧:៥៨]

**លោក វីល្លៀម ស្មីត៖**

ខ្ញុំគិតថា សហមេធាវីនិយាយខុសអំពីកំណត់ហេតុអង្គប្រជុំថ្ងៃ៣០ មីនា ឆ្នាំ៧៦ នោះគឺជារបស់គណៈមជ្ឈិម មិនមែនគណៈអចិន្ត្រៃយ៍ទេ។

**លោក ហ្សាស្តេ ប៉ោ៖**

សូមអភ័យទោស! លោកប្រធានខ្ញុំបាននិយាយបានខុស។ ខ្ញុំនិយាយអំពីកំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍ចុះថ្ងៃទី៣០ មីនា ឆ្នាំ១៩៧៦ បាទ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីមានឯកសារទេ ដើម្បីដាក់ជូនសាក្សីពិនិត្យ។ ដោយឯកសារច្រើន មានបានត្រៀមឯកសារជាក្រដាសសម្រាប់ដាក់ជូនសាក្សីពិនិត្យទេ?

**លោក ហ្សាស្តេ ប៉ោ៖**

លោកប្រធាន ខ្ញុំបានរៀបចំឯកសារលើក្រដាស។ ខ្ញុំសូមអនុញ្ញាតមិនបង្ហាញឯកសារទាំងអស់ដែលបានពិភាក្សាលម្អិតរួចហើយ ដោយខ្ញុំយល់ថាភាគីទាំងអស់រាប់ទាំងសាក្សីផង បានស្គាល់ឯកសារ- - ខ្លឹមសារនៃឯកសារទាំងនេះហើយ។ ដូច្នេះ សូមអនុញ្ញាតតុលាការ ខ្ញុំសូមបន្តទៅដោយសារថា ពេលវេលាសម្រាប់ខ្ញុំវាខ្លីពេក។ អ៊ីចឹងខ្ញុំសួរនូវសំណួររបស់ខ្ញុំបន្តទៅទៀត។

[១៣:៣៩:២១]

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** នៅក្នុងសវនាការកាលពីថ្ងៃអង្គារកន្លងទៅ ថ្ងៃទី០៣ មេសា លោកបានឆ្លើយសំណួរដូចខាងក្រោម៖ “តើ សុន សេន និង នួន ជា ធ្វើអ្វីទាក់ទងនឹងចម្លើយសារភាពក្រោយពួកគាត់បានទទួល?” ហើយលោកបានឆ្លើយថា “សូមអរគុណលោកប្រធាន។ គណៈអចិន្ត្រៃយ៍បក្ស នួន ជា, សុន សេន ក្តីគឺត្រូវសម្រាយអ្វីត្រូវធ្វើចំពោះគណៈអចិន្ត្រៃយ៍ ខ្ញុំមិនបានដឹងអំពីបញ្ហានោះទេ។ វាហួសពីសមត្ថកិច្ចរបស់ខ្ញុំ”។ តើលោកប្រកាន់យកចម្លើយនេះដែរឬទេ លោកសាក្សី?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ការបកប្រែចុះឡើងដូចជាមិនសូវស្រួលស្តាប់សោះ។ តើមេធាវីអាចមានប្រតិចារឹកបង្ហាញខ្ញុំទេ?

**លោក ហ្សាស្តេ ប៉ោ៖**

សូមគោរពលោកប្រធាន បើសិនជាសាក្សីសុំប្រតិចារឹកសេចក្តីលម្អិតទាំងអស់នេះ គឺថាខ្ញុំត្រូវការពីរថ្ងៃទៀតសម្រាប់សួរសាក្សី។ ខ្ញុំសួរថាគាត់យល់ច្បាស់ពីសំណួររបស់ខ្ញុំ ហើយបើសិនជាចាំបាច់ខ្ញុំដកស្រង់សម្តីរបស់គាត់ពីរថ្ងៃកន្លងទៅ ហើយខ្ញុំសួរគាត់ឲ្យឆ្លើយទៅនឹងសំណួរខ្ញុំ។ សូមតុលាការណែនាំឲ្យសាក្សីឆ្លើយទៅសំណួររបស់ខ្ញុំថា តើគាត់ប្រកាន់យកចម្លើយរបស់គាត់ពីពីរថ្ងៃនោះដែរឬទេ?

[១៣:៤១:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤២:០០]

**ប្រធានអង្គជំនុំ៖**

ជានីតិវិធីក្នុងការដេញដោល ជាឯកសារនៅចំពោះមុខអង្គជំនុំជម្រះ ៗបានសម្រេចរួចហើយថាភាគីដែលមានបំណងចង់ដកស្រង់នូវខ្លឹមសារ នូវឯកសារណាមួយត្រូវរៀបចំនូវឯកសារនោះ ដើម្បីជាក្រដាសដាក់ជូនមកសាក្សីពិនិត្យមុននឹងដេញដោល។ ដូច្នេះលោកមេធាវីត្រូវអនុវត្តទៅតាមវិធាន ដែលកំណត់ជាទូទៅនេះ ពីព្រោះជំនឿនៅក្នុងការដកស្រង់ឡើងវិញ នៃការឆ្លងកាត់ការបកប្រែភាសាពីពីរៗត្រឡប់នេះ វានឹងអាចមានបញ្ហាមិនមានជំនឿស៊ប់នៅក្នុងការស្តាប់ខ្លឹមសារត្រឹមត្រូវ។ បញ្ហាទីពីរ ចំពោះមុខនេះ ប្រសិនបើមិនអាចដំណើរការដូច្នេះបានៗទេ សូមឲ្យមេធាវីជាតិការពារក្តីលោក នួន ជា ដែលជាក្រុមជាមួយគ្នារបស់លោកហ្នឹង គឺអានប្រតិចារឹកជាភាសាខ្មែរដែលលោកមានបំណងក្នុងការដកស្រង់នេះ ប្រសិនបើរៀបចំមិនទាន់ទេ ដើម្បីឲ្យការដំណើរការនេះវាជាក់ច្បាស់។ ហើយក៏ជម្រាបលោកផងដែរ មិនមែនឲ្យលោកមានឱកាសគ្រាន់តែលើកឡើងនូវបញ្ហាដែលមិនរលូន មិនបានត្រៀមខ្លួន ដើម្បីរៀបចំបែបបទនៅក្នុងការតាំងសួរដេញដោលនេះ សុំពេលវេលានោះឡើយ។ ពេលវេលា អង្គជំនុំជម្រះនឹងពិចារណាកម្រិតតែមានការជំទាស់តវ៉ា ពីភាគីផ្សេងៗទៀតនៅក្នុងអំឡុងពេលដេញដោលប៉ុណ្ណោះ។

[១៣:៤៤:០០]

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហ្សាស្តេ ប៉ោះ**

**ស៖** ខ្ញុំនឹងបន្តទៅចំណុចបន្ទាប់របស់ខ្ញុំ សាក្សីលោកបាននិយាយថា ចំពោះសហចៅក្រមស៊ើបអង្កេតថា លោកមិនដឹងអំពីសេចក្តីលម្អិតថា តើថ្នាក់លើធ្វើការក្នុងចំណោមគ្នាគាត់នោះទេ។ សំណួររបស់ខ្ញុំគឺថា សាមញ្ញទេ តើលោកដឹងសេចក្តីលម្អិតអំពីវិធី ដែលថ្នាក់លើធ្វើការក្នុងចំណោមពួកគាត់ដែរឬទេ?

[១៣:៤៤:៤៥]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ឯកសារខ្ញុំនៅក្នុងរយៈកាលស៊ើបអង្កេតដូចច្រើនដែរ។ គួរណាស់តែខ្ញុំបានទទួលច្បាប់ជាលាយលក្ខណ៍អក្សរ ហើយនិងច្បាប់បញ្ជាំងលើនេះ ដើម្បីរំឭកឡើងវិញ ដើម្បី-- ដូចជាខ្ញុំបានជម្រាបលោកប្រធានហើយ លោកប្រធានក៏បានរំឭកអំមិញដែរ។ ការបកប្រែភាសាចុះឡើងល្អៀង។

**ស៖** ឧុច ខ្ញុំមិនសួរពីឯកសារទេ ខ្ញុំសួរឲ្យលោកឆ្លើយសំណួររបស់ខ្ញុំ។ តើលោកដឹងពីវិធីលម្អិតដែលថា របៀបដែលពួកគាត់ធ្វើការរវាងគ្នានិងគ្នា លោកដឹង ឬមិនដឹង តែប៉ុណ្ណឹង? តែប៉ុណ្ណឹងទេបាទ។

**ឆ៖** អរគុណលោកប្រធាន។ ឥឡូវសំណួរលោកត្រឹមតែចុងក្រោយប៉ុណ្ណឹង បានៗខ្ញុំនិយាយ។ ការធ្វើការងាររបស់អចិន្ត្រៃយ៍មជ្ឈិម។ ឲ្យខ្ញុំដឹងច្បាស់គឺអត់ដឹងទេ ក៏ប៉ុន្តែជាគោលការណ៍គឺដឹង ព្រោះមេខ្ញុំប្រាប់ ដូចជាប្រជុំដើម្បីសម្រេចចាប់ ឈូក មេប្រាប់ ឲ្យខ្ញុំរៀបចំឯកសារដើម្បីឲ្យគាត់ធ្វើការងារ។ ដូច្នេះមិនដឹងសោះ មិនមែន រួចបើដឹងគ្រប់ពេលវេលា ក៏មិនត្រូវ។

[១៣:៤៦:២៨]

**ស៖** លោកក៏បានបញ្ជាក់ដែរថា នៅពេលដែលគេសួរលោកថាតើលោកដឹង ឬមិនដឹង ថាតើ នួន ជា ធ្វើអ្វីជាមួយនឹងចម្លើយសារភាពបន្ទាប់ពីលោកបញ្ជូន ដែលលោកអះអាងថា បញ្ជូនទៅគាត់នោះ លោកបានឆ្លើយថា ខ្ញុំមិនដឹងទេ។ ឥឡូវនេះ ខ្ញុំសួរលោក តើលោកដឹង ឬទេ ឧុច ថាតើ នួន ជា យកចម្លើយសារភាពទៅធ្វើអ្វី បន្ទាប់ពីដែលលោកអះអាងថា បញ្ជូនទៅគាត់នោះ តើគាត់យកចម្លើយសារភាពនោះទៅធ្វើអ្វីទៀត? លោកស្តាប់ខ្ញុំមិនឮដោយសារមីក្រូហ្វូនខ្ញុំមិនទាន់បើក ឬដូចម្តេចបាទ?

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤៧:៥៨]

**ប្រធានអង្គជំនុំ៖**

សំណួរនេះ សំណួរច្រំដែល សាក្សីមិនបាច់ឆ្លើយតបទេ។

**លោក ហ្សាស្ដើ ប៉ៅ៖**

សូមអរគុណលោកប្រធាន។

[១៣:៤៨:២៣]

**សួរដោយលោក ហ្សាស្ដើ ប៉ៅ៖**

**ស៖** ឌុច លោកបានបញ្ជាក់ថា ជូនទៅសហចៅក្រមស៊ើបអង្កេតនោះ ខ្ញុំសូមអនុញ្ញាតដាក់ឯកសារ D86/27 នៅលើអេក្រង់ ហើយលោកបានប្រាប់តុលាការ-- ចៅក្រមអង្កេតថា ខ្ញុំសូមជម្រាបថា របបនេះ ជារបបឧក្រិដ្ឋចាប់ពីឆ្នាំ១៩៨៣មកទេ។

**លោក ហ្សាស្ដើ ប៉ៅ៖**

ហើយប្រសិនបើ-- បាទ សូមអនុញ្ញាតបង្ហាញឯកសារ D86/27 លើអេក្រង់ ហើយសូមលោកប្រធានអនុញ្ញាត។ ខ្ញុំនឹងផ្ដល់ឯកសារលើក្រដាសជូនទៅសាក្សីដើម្បីពិនិត្យ ហើយនិងដែលមានគូសចំណាំត្រង់ចំណុចដកស្រង់ផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីមេធាវី ដាក់ជូនទៅសាក្សីពិនិត្យ!

លោកមេធាវីបញ្ជាក់ពីលេខ ERN នៃឯកសារហ្នឹងផងដើម្បីជាប្រតិចារឹក!

[១៣:៤៩:៣៨]

**លោក ហ្សាស្ដើ ប៉ៅ៖**

អង់គ្លេស ERN 00195603 ខ្មែរ ERN 00195594 បារាំង ERN 00195613។

សូមអភ័យទោស ខ្ញុំថា ខុស ខ្ញុំមើលឯកសារមុន ឯកសារដែលខ្ញុំនឹងនិយាយនេះគឺ ខ្មែរ ERN 00187653 អង់គ្លេស ERN 00204342 ហើយបារាំង ERN 00186172។ ដូច្នេះលោកបានឃើញឯកសារហើយលោកសាក្សី លោកអានតាមការបកប្រែអង់គ្លេសនេះ គឺខ្ញុំចាប់ផ្ដើមគិតថារបបនេះជារបបឧក្រិដ្ឋ គឺចាប់ពីឆ្នាំ១៩៨៣ ទេ។ សំណួរខ្ញុំសួរទៅលោកគឺថា ហេតុអ្វីបានជាត្រូវប្រើពេលរហូតទាល់តែឆ្នាំ១៩៨៣ ទើបបានលោកដឹងថារបបនោះជារបបឧក្រិដ្ឋ?

[១៣:៥១:០៣]

**ឌះ** ប្រសាសន៍លោកប្រធាន ដំបូងខ្ញុំសូមអានអត្ថបទនៅក្នុងឯកសារនេះ ដែលបង្ហាញជូន។ ខ្ញុំសូមកាត់ចោលខាងដើម ព្រោះខាងដើមហ្នឹងគូសប្រអប់ហ្នឹងចូលទៅឃ្លាមុន "វន វេត នៅថ្ងៃ២ វិច្ឆិកា ១៩៧៨ ខ្ញុំមានការព្រួយបារម្ភចំពោះអាយុជីវិតខ្ញុំ។ ខ្ញុំអាចនិយាយថាចាប់នេះ ខ្ញុំអាច-- អំ! ខ្ញុំអាចនិយាយថាខ្ញុំចាប់គិតថា របបនេះជារបបឧក្រិដ្ឋ ចាប់តាំងពីឆ្នាំ១៩៨៣មក។ តាមរយៈនេះខ្ញុំចង់និយាយថា នៅឆ្នាំ១៩៨៣ ខ្ញុំចូលរៀនវគ្គ រៀនសូត្រវគ្គ ចូលរៀន-- ចូលក្នុងវគ្គរៀនសូត្រមួយធ្វើឡើងដោយ នួន ជា នៅសំឡូត បន្ទាប់ពីការរំលំរលាយបក្សកុម្មុយនីស្តកម្ពុជាជាផ្លូវការ"។

[១៣:៥២:១៨]

**សះ** សូមអរគុណ។ នេះគឺឆ្លុះបញ្ចាំងទៅចម្លើយដែលលោកឆ្លើយទៅសហចៅក្រមស៊ើបអង្កេត។ សំណួររបស់ខ្ញុំគឺថា ហេតុអ្វីក៏លោកមិនបានដឹងហេតុការណ៍នេះមុនពេលហ្នឹង? ដោយសារថាលោកជាប្រធានស-២១ ផងនោះ? តើហេតុអ្វីបានជាលោកមិនបានដឹងពីឧក្រិដ្ឋភាព ពីភាពឧក្រិដ្ឋកម្មនៅរបបនោះនៅពេលដែលលោកជាប្រធានមន្ទីរសន្តិសុខនោះហើយនោះ?

**ឌះ** ជម្រាបប្រសាសន៍លោកប្រធាន ដើម្បីនឹងនិយាយថារបបមួយមានធាតុពិតឧក្រិដ្ឋ វាទាមទារការយល់ដឹងច្រើនជ្រុងជ្រោយបន្តិច មុននឹងហ៊ាននិយាយ មិនមែនចេះតែនិយាយៗទៅបានទេ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

[១៣:៥៣:២៩]

**សះ** សូមអរគុណដែលលោកបានឆ្លើយ។ ខ្ញុំសូមអនុញ្ញាតបន្តទៅផ្នែកមួយទៀត ប្រធានបទថ្មីមួយគឺៗជាការស្រាវជ្រាវដែលលោកបានធ្វើប្រឆាំងនឹងរដ្ឋដែលលោកបានធ្វើ ហើយលោកបានបញ្ជាក់ពីបញ្ហានេះច្រើនដង បីបួនដងចំពោះអង្គជំនុំជម្រះ ហើយក៏លោកបញ្ជាក់នៅក្នុងចម្លើយចំពោះសហចៅក្រមស៊ើបអង្កេត លោកបានចង្អុលបង្ហាញថា លោកបានអាន បានសិក្សាឯកសារទាំងឡាយ ហើយ និងសៀវភៅដែលទាក់ទងទៅនឹងសម័យកម្ពុជាប្រជាធិបតេយ្យ។ ឥឡូវនេះ ខ្ញុំនឹងសួរសំណួរទៅលោក ខ្ញុំនឹងដាក់បង្ហាញលោកនូវឈ្មោះសៀវភៅមួយចំនួន។ សុំឲ្យលោកចង្អុលបង្ហាញថាតើលោកបានអានសៀវភៅទាំងនោះដែរឬទេ? លោកគ្រាន់តែឆ្លើយថាបាទ ឬក៏ទេ។ សំណួរទីមួយ តើអានសៀវភៅជាសៀវភៅសំឡេងពីស-២១ របស់ ដេវីដ ឆេនឌ័ល័រ ដែរឬទេ?

[១៣:៥៤:៣៨]

**ឌះ** បានអាន។

**ស៖** តើៗលោកបានអានសៀវភៅដែលមានចំណងជើងថា ពេជ្ឈឃាដបាត់ខ្លួន សរសេរដោយ នីក ដងឡុប ដែរឬទេ?

**ឆ៖** បានអាន។

**ស៖** តើលោកបានអានសៀវភៅឈ្មោះថា "ក្លោងទ្វារធំ" សរសេរដោយ ហ្វ្រង់ស្វ័រ ប៊ីហ្សូ ដែរឬទេ?

**ឆ៖** ខ្ញុំអានដែរ តែមិនជក់ចិត្ត។ គាត់និយាយបារាំងបែបពិបាកស្តាប់ណាស់។ ខ្ញុំតែងចំអន់លេង ជាមួយ ហ្វ្រង់ស្វ័រ រូ ថា *ប៉ូរ៉េអិត* ហ្វ្រង់ស្វ័រ ប៊ីហ្សូ ជាកវី បានន័យថា បណ្តែតអារម្មណ៍រវើរវាយ។

**ស៖** តើលោកបានអានសៀវភៅថា "កម្ពុជាឆ្នាំ*ហេ្សូ*" របស់ ប៉ុងសួដ៏។ បាទលោកឪពុក ប៉ុងសួដ៏ ដែរទេ?

**ឆ៖** ខ្ញុំបានអានខ្លះដែរ តិចទេ មិនច្រើនគ្រប់ទំព័រទេ។

[១៣:៥៦:០៣]

**ស៖** លោកបានឃើញខ្សែភាពយន្តរបស់ រិទ្ធី ប៉ាន់ ទេថា ស-២១ គ្រឿងម៉ាស៊ីនសម្លាប់មនុស្ស របស់របបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ខ្ញុំបានទស្សនាខ្សែភាពយន្តពីរកូនខ្សែរបស់ រិទ្ធី ប៉ាន់ តែចំណងជើងស្អី ខ្ញុំមិនដឹង ភ្លេចបាត់ ហើយ។

**ស៖** ឥឡូវនេះ ខ្ញុំចូល ចេញពីសៀវភៅ និងខ្សែភាពយន្ត សួរថាតើត្រូវដែរឬទេនៅក្នុងការជំនុំជម្រះរឿងក្តីរបស់លោក គឺថាមនុស្សមួយចំនួនមកផ្តល់សក្ខីកម្ម មាន ក្រេក អេតធេសាន់, ដេវីដ ឆេនដ័ល័រ, វ៉ាអ៊ួល ម៉ាកចេនណា ហើយនិង ណាយ៉ាន់ ចាន់ដា។ តើលោកបានជួបអ្នកទាំងអស់នោះ ពេលផ្តល់សក្ខីកម្មទេ?

**ឆ៖** ខ្ញុំជួប។

**ស៖** បាទ តើលោកជួបពួកគាត់ នៅពេលដែលឃើញគាត់ ឃើញគាត់នៅពេលដែលគាត់មក ផ្តល់សក្ខីកម្មហ្នឹងដែរឬទេ?

**ឆ៖** ឃើញ ជួប ខ្ញុំអង្គុយនោះ។

**ស៖** លោកអាចដឹងថា រឿងក្តីរបស់គាត់នៅ អ.វ.ត.ក ហ្នឹង គឺហៅថា រឿងក្តី០០១ គឺខុសពី រឿងក្តី០០២ ដែលកូនក្តីរបស់ខ្ញុំជាជនជាប់ចោទ ហើយលោកក៏ជាជនជាប់ចោទនៅក្នុងរឿងក្តី០០២ តើ

លោកបានមានលទ្ធភាពបើកមើលរឿងក្តីនៅក្នុង០០២ នេះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំដូចមិនដែលឃើញ តុលាការចោទខ្ញុំពីកូនក្តីនៅក្នុងសំណុំរឿងលេខ០០២ ដឹងតែតុលាការចោទខ្ញុំពីសំណុំរឿងលេខ០០១។ ឥឡូវសូមលោកមេធាវីជម្រាបតុលាការឲ្យច្បាស់ទៅ ជាតិប្រជាជនកម្ពុជាឲ្យច្បាស់ទៅ។

[១៣:៥៨:២៣]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី តាំងសំណួរសាជាថ្មី ដូចមានការភ័ន្តច្រឡំជាភាសាខ្មែរ ដែលមានន័យថាសាក្សីរូបនេះ ក៏ជាជនជាប់ចោទនៅក្នុងសំណុំរឿង០០២ដែរ ក្រែងលោមានការភ័ន្តច្រឡំ ពីព្រោះនៅក្នុងសំណុំរឿង០០២ យើងបានប្រកាសបើកហើយ និងកំណត់ជនជាប់ចោទដែលយកមកសវនាការ ហើយនិងជនជាប់ចោទដែលបង្គង់នីតិវិធី ដោយមូលហេតុបញ្ហា អ្ហឹ!សម្បទាដូចជាជាក់ច្បាស់ហើយ។

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** សូមអរគុណលោកប្រធាន។ ហើយខ្ញុំសូមបំភ្លឺ។ ឌុច គឺជាជនសង្ស័យនៅក្នុងរឿងក្តី០០២ ហើយត្រូវបានសួរនៅក្នុងករណី០០២នេះ ក្នុងនាមជាជនសង្ស័យ ថាតើ ឌុច គាត់បានមានលទ្ធភាពមើលឯកសារនៅក្នុងរឿងក្តី០០២ដែរឬទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ចំពោះបញ្ហារឿងក្តី០០២ ខ្ញុំជាអ្នកផ្តល់ព័ត៌មានមួយផ្នែកណាជូនការិយាល័យចៅក្រមស៊ើបអង្កេត ឯកសារមាន ពេញបរិបូរ។

**ស៖** ខ្ញុំនឹងទុកសំណួរនេះមួយរយៈសិន។ ខ្ញុំឃើញថា សាក្សីមិនឆ្លើយទេ ហើយខ្ញុំនឹងចូលទៅដល់ចំណុចបន្ទាប់ទៅទៀត គឺ សំណួរសួរថា តើឌុច បានប្រើសៀវភៅរបស់ ដេវីដ ឆេនដ៍ល័រ សំឡេងពីស-២១ នេះ នៅពេលដែលលោកព្យាយាមឆ្លើយនូវសំណួរទាំងឡាយដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងរឿងក្តីរបស់លោកនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំឆ្លើយតាមសំណួររបស់សហចៅក្រមស៊ើបអង្កេតដោយគាត់ដកស្រង់ចេញពីសៀវភៅរបស់ ដេវីដ ឆេនដ៍ល័រ។ ខ្ញុំមិនបានដកស្រង់ខ្លឹមសារហ្នឹង យកទៅធ្វើជាបង្អែក សម្រាប់ការពារខ្លួនទេ គឺខ្ញុំពន្យល់ការិយាល័យស៊ើបអង្កេតអំពីរឿងដែល ដេវីដ ឆេនដ៍ល័រ សរសេរនៅក្នុងសៀវភៅរបស់គេ។

**ស៖** សូមអរគុណ ឌុច។ ខ្ញុំសូមបន្តទៅដល់ផ្នែក និងប្រធានបទនៃការតាំងសំណួររបស់ខ្ញុំផ្សេងទៀត ដែលជាប់ពាក់ព័ន្ធទៅនឹងចម្លើយ លោកបានឆ្លើយជូននៅពេលដែលចៅក្រមស៊ើបអង្កេតស្តាប់ចម្លើយលោក។

[១៤:០១:៥៦]

**លោក ហ្សាស្តើ ប៉ោ៖**

ខ្ញុំសូមអនុញ្ញាតលោកប្រធាន បង្ហាញឯកសារ D90 គឺកំណត់ហេតុស្តាប់ចម្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ថ្ងៃ២៥ មីនា ឆ្នាំ២០០៨។ ខ្មែរ គឺ00187-- ខ្មែរ គឺ 00198873 អង់គ្លេស 00198882 បារាំង 00198890។ ខ្ញុំសូមអនុញ្ញាតបញ្ចាំងឯកសារនេះ នៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវីយកជូនសាក្សីពិនិត្យ!

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** ខ្ញុំសូមឲ្យសាក្សីអាននៅក្នុងកំណត់ហេតុ-- ចម្លើយដែលក្នុងប្រអប់ក្រហមឲ្យលោកអានមើលពិនិត្យតាមទៅ ខ្ញុំនឹងអានជាភាសាអង់គ្លេស។ “ឆ្លើយដោយ ឌុច គឺ--។ ជាដំបូង ខ្ញុំត្រូវបញ្ជាក់ថា នៅនាពេលនេះ ខ្ញុំមានការយល់ដឹងច្រើនជាងនៅខែសីហា ឬធ្នូ កន្លងទៅ។ តាមពិតទៅ នៅពេលដែលខ្ញុំបានដឹងបន្តិចៗដងពីសំណុំរឿង ខ្ញុំយល់កាន់តែច្បាស់ពីរចនាសម្ព័ន្ធនៃរបបនោះ។ ខ្ញុំអាចដឹងពីអ្វីដែលខ្ញុំហៅថា គណៈកម្មាធិការការងារជុំវិញមន្ទីរ៨៧០។ នាពេលដែលការសួរចម្លើយលើកមុន ដែលការពិតគឺជាមន្ទីរស-៧១”។

[១៤:០៣:៥២]

ឌុច ខ្ញុំមិនខ្វល់អំពីខ្លឹមសារនៃចម្លើយនេះទេ ក៏ប៉ុន្តែខ្ញុំសូមសួរដូចតទៅ៖ តើលោកឯកភាពជាមួយនឹងខ្ញុំដែរឬទេ ថាការពិនិត្យសិក្សារបស់លោកទៅលើសំណុំរឿង គឺអាចឲ្យលោកយល់អំពីរចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ មែនដែរឬទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ត្រឹមត្រូវហើយ ក្នុងនេះ ខ្ញុំបានលម្អិតជូនសហចៅក្រមស៊ើបអង្កេតអំពីរចនាសម្ព័ន្ធរបស់ ស-៧១។ ដូច្នេះ ក្នុងនេះវាមានលក្ខណៈ-- និយាយអំពីការយល់ដឹងរបស់ខ្ញុំកាន់តែច្បាស់ អំពីអ្វីដែលហៅ

ថា ស-៧១។

**ស៖** ឯកសារដែលខ្ញុំចង់បង្ហាញ គឺឯកសារ D86/25 អង់គ្លេស ERN គឺ 00185474 ខ្មែរគឺ 00115---

**អ្នកបកប្រែ៖**

លោកប្រធាន សូមអនុញ្ញាតឲ្យលោកមេធាវីអាចបញ្ជាក់លេខ ERN ឡើងវិញ ឲ្យបានយឺតៗ។

**លោក ហ្សាស្ដើ ប៉ោ៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

លោកមេធាវីបញ្ជាក់ពីលេខ ERN ឯកសារឡើងវិញទាំងបីភាសា អ្នកបកប្រែអត់បានបកទេ ដោយសារស្ដាប់មិនទាន់លោកនិយាយលឿនពេក។ សូមលោកនិយាយឲ្យបានយឺតជាងនេះបន្តិចដើម្បីឲ្យអ្នកបកប្រែបកទាន់ ហើយអាចអង្គជំនុំជម្រះអនុញ្ញាតឲ្យដាក់បញ្ចាំងឯកសារនៅលើអេក្រង់ទូរទស្សន៍ ហើយនិងបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីមេធាវីយកទៅដាក់-- យកទៅជូនសាក្សីពិនិត្យ។ សូមលោកមេធាវីបញ្ជាក់លេខ ERN សាជាថ្មីម្ដងទៀត ដើម្បីឲ្យមានការបកប្រែ ហើយប្រតិចារឹកផង។

[១៤:០៦:៣១]

**លោក ហ្សាស្ដើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអធ្យាស្រ័យ ខ្ញុំរំភើបពេកនៅពេលដែលខ្ញុំអាន ERN ខ្ញុំនឹងព្យាយាមអានឲ្យបានយឺតៗ។

**សួរដោយលោក ហ្សាស្ដើ ប៉ោ៖**

អង់គ្លេស ERN គឺ 00185474 ខ្មែរគឺ 00185466 បារាំងគឺ 00185481។ ដូចដែលសាក្សីបានទទួលឯកសារមួយច្បាប់រួចមកហើយ។ ដូច្នេះនៅពេលនេះ ខ្ញុំសូមអានសំណួរសួរដោយចៅក្រមស៊ើបអង្កេត។ ចៅក្រមស៊ើបអង្កេតសួរថា "ឌុច លោកប្រកាសប្រាប់យើងអំពីសេចក្ដីសង្កេតជាលាយលក្ខណ៍អក្សររបស់លោកលើបទសម្ភាសន៍របស់លោកនៅឆ្នាំ១៩៩៩ និងសៀវភៅរបស់លោកដេវីដ ឆេនដ័ល័រ ដែលមានចំណងជើងថា "សំឡេងពីស-២១" រហូតមកដល់ពេលនេះ ខ្ញុំមិនទាន់បានទទួលកត់សម្គាល់ទាំងនោះនៅឡើយទេ"។

[១៤:០៧:៣០]

ចម្លើយរបស់លោកនៅពេលនោះឆ្លើយថា "ទាក់ទងទៅនឹងសៀវភៅរបស់លោក ឆេនដ័ល័រ មានចំណុចសំខាន់ៗជាច្រើន ជាពិសេសចំណុចទាក់ទងទៅនឹងសេចក្ដីសម្រេចថ្ងៃ៣០ មីនា ឆ្នាំ១៩៧៦ ទាក់ទងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានបញ្ជូន ដែលត្រូវបានបញ្ជានៅស-២១"។ ខ្ញុំសូមបញ្ចប់សម្ដីដកស្រង់។

**ស៖** ឌុច តើលោកចាំដែរឬទេថា សៀវភៅរបស់លោក ដេវីដ ឆេនដ័ល័រ បានលើកឡើងអំពីសេចក្ដីសម្រេចថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំពិតជាចាំ។

**ស៖** តើលោកចាំទេ សៀវភៅរបស់លោក ដេវីដ ឆេនដ័ល័រ នោះបាននិយាយយ៉ាងម៉េចខ្លះទៅលើសេចក្ដីសម្រេចនេះ?

[១៤:០៨:៣២]

**ឆ៖** ខ្ញុំចាំបានមួយឃ្លា ដែលថា-- អ៎ន៎ែ! ឯកសារនេះ វាជាកំណត់ ជាលាយៗ-- ជាកំណត់ជាលាយលក្ខណ៍អក្សរដំបូងដែលនៅសល់បញ្ជាក់អំពីការ អ្នកដែលមានសិទ្ធិសម្រេចកម្ទេច។ នេះខ្ញុំឃើញខ្លី ហើយចាំអាហ្នឹង។

**ស៖** សូមអរគុណ។ ខ្ញុំសូមចូលទៅដល់ឯកសារបន្ទាប់ទៀត គឺឯកសារ D238 កិច្ចស្ដាប់ចម្លើយរបស់ចៅក្រមស៊ើបអង្កេតថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩ អង់គ្លេស ERN គឺ 00403888 ខ្មែរគឺ 00403877 បារាំងគឺ 00403897។ ដូច្នេះខ្ញុំសូមអនុញ្ញាតលោកប្រធាន បញ្ចាំងឯកសារនេះនៅលើអេក្រង់។ សូមកែលេខ-- ជាអង់គ្លេស គឺ 00403877។

[១៤:១០:០២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ប៉ុន្តែលេខខ្មែរជាភាសាខ្មែរម៉េចទៅ? អង្គជំនុំជម្រះអនុញ្ញាត ហើយមន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីមេធាវីយកមកជូន-- យកទៅជូនសាក្សី។ លេខERN ជាភាសាខ្មែរ?

**លោក ហ្សាស្ទើ ប៉ោ៖**

ជាការពិតលោកប្រធាន ខ្ញុំ-- ឯកសារខ្មែរគឺ 00403877។ ហើយសាក្សី-- លោកប្រធានសូមឲ្យសាក្សីអានតាមជាភាសាខ្មែរ ហើយខ្ញុំនឹងអានជាភាសាអង់គ្លេស គឺការស្ដាប់ចម្លើយ ខែក ប៊ុន ហៅស៊ូ ខ្ញុំសូមដកស្រង់សម្ដីត្រង់ផ្នែកដែល ឌុច បាននិយាយថា "ខ្ញុំនិយាយអំពី-- ខ្ញុំបានបញ្ជូនឯកសារនេះទៅ

សុន សេន តាមរយៈនីរសារ។ សុន សេន ប្រហែលជាអ្នករៀបសេចក្ដីសម្រេចនេះ ហើយសូមសេចក្ដីសម្រេចពី ប៉ុល ពត។ ហើយខ្ញុំមិនដឹងថា កំណត់ចំណារ នួន ជា នេះសរសេរក្រោយពីសេចក្ដីសម្រេចរបស់ ប៉ុល ពត ឬក៏យ៉ាងណានោះទេ? ខ្ញុំគិតថាមិនច្បាស់នោះទេ ក៏ប៉ុន្តែ នួន ជា ជាអ្នកទទួលខុសត្រូវថាសេចក្ដីសម្រេចរបស់ ប៉ុល ពត ត្រូវបានអនុវត្តឲ្យបានត្រឹមត្រូវ។ ហើយត្រូវបញ្ជូនសេចក្ដីសម្រេចនេះទៅតាមភូមិភាគនានា”។

[១៤:១១:៤៥]

ដូច្នេះ នៅពេលនេះខ្ញុំសូមសួរទៅកាន់លោក ឌុច ខ្ញុំទាញសេចក្ដីសន្និដ្ឋានផ្អែកទៅលើសេចក្ដីសម្រេច៣០ មីនា ឆ្នាំ១៩៧៦។ ជារៀងរាល់សប្ដាហ៍ សុន សេន ត្រូវតែរៀបចំឯកសារទាក់ទងទៅនឹងរឿងសន្តិសុខ ដើម្បីដាក់សូមការសម្រេចពីប៉ុល ពត។ ក្រោយមកទៀត លោកនិយាយថា ខ្ញុំធ្វើសន្និដ្ឋាននេះតាមរយៈការសង្កេតរបស់ខ្ញុំពីចម្ងាយ។ ខ្ញុំគិតថា-- បាទ សូមបញ្ចប់ការដកស្រង់។

**សួរដោយលោក ហ្សាស្តេ ប៉ៅ៖**

**ស៖** លោកនៅពេលដែលលោកមើលឯកសារនេះ លោកបានលើកឡើងថាលោកបានធ្វើសេចក្ដីសន្និដ្ឋានថា មានអ្វីកើតឡើងចំពោះចម្លើយ ខែក ប៊ុន នេះ? តាមរយៈសេចក្ដីសម្រេចថ្ងៃ៩ ខែតុលា ឆ្នាំ១៩៧៥ និងសេចក្ដីសម្រេចថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦។ លោក ឌុច ថាតើលោកពិតជាធ្វើការសន្និដ្ឋានថាមានករណីមួយចំនួនបានកើតឡើងក្រោយពីពិនិត្យមើលចម្លើយសារភាពនេះ ដោយសារលោកសន្មតទៅលើ តើដំណើរការប្រព័ន្ធនៅសម័យនោះ គឺដំណើរការទៅរបៀបណា? តើពិតជាដូច្នោះដែរឬទេ?

[១៤:១៣:១០]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ដូចវែងអន្លាយ។ ឥឡូវមេធាវីចោះៗអាត្រង់ណាដែលសំខាន់ ចង់សួរខ្ញុំ។ វែងអន្លាយណាស់។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីជាតិ មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន។ សូមឲ្យលោកមេធាវី ហ្សាស្តេ ប៉ៅ យឺតបន្តិច។ ហើយមុននឹងអានសូមឲ្យដាក់ឯកសារឲ្យចំនៅលើអេក្រង់តែម្ដង ដើម្បីឲ្យភាគីអាចមើលឃើញនូវឯកសារនៅលើអេក្រង់

មុននឹងអាន បើមិនដូច្នេះទេនឹងវង្វេង។

[១៤:១៣:៥៣]

**ប្រធានអង្គជំនុំ៖**

បាទ អំមិញកត់សម្គាល់ឃើញអ៊ីចឹងដែរ ក៏ប៉ុន្តែខាងជំនួយការបានប្រឹងប្រែងដើម្បីរៀបចំហ្នឹងឲ្យ *ស៊ីរ៉េ*ឲ្យត្រូវមកវិញហើយ កែតម្រូវហើយ។ បានន័យថា គាត់ក៏បានដឹងដោយខ្លួនឯង ហើយបានរៀបចំកែសម្រួលដោយខ្លួនឯងរួចហើយ។ អានេះវាជារឿងមួយបញ្ហាបច្ចេកទេស។ អង្គជំនុំជម្រះក៏បានកត់សម្គាល់ ប៉ុន្តែភ្លាមៗគឺខាងជំនួយការគេបានកែសម្រួលរួចហើយ។ បញ្ហាមួយលោក ឌុច អំមិញឃើញលោកមានបញ្ហាវ៉ែនតា តើវ៉ែនតារបស់លោកហ្នឹងយ៉ាងម៉េចទៅ?

**អ្នកបកប្រែ៖**

សូមបើកមីក្រូហ្វូន អ្នកបកប្រែស្តាប់អត់ឮ។

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន វ៉ែនតានេះខ្ញុំរបូតអំមិញទៅទៀតទៅហើយ។ ពីលើកមុនរបូតមួយសា ដល់គេយកទៅជួសជុលឲ្យ យកមកវិញរបូតទៀត។

**ប្រធានអង្គជំនុំ៖**

អរគុណ ហើយមន្ត្រីរដ្ឋបាលតុលាការអាចជួយសម្របសម្រួល ដើម្បីដោះស្រាយបញ្ហាហ្នឹងបណ្តោះអាសន្នសិនបានទេ? ហើយយកមក រកចាត់ចែងអ្នកណាជួយរៀបចំដាក់ប្រើប្រាស់បណ្តោះអាសន្នសិន ព្រោះឃើញគាត់ ភ្នែកគាត់ប្រឹងបើក។

សូមមេធាវីអញ្ជើញបន្តទៀត ហើយសូមសួរសំណួរឲ្យបានជាក់ច្បាស់ ហើយអាចខ្លីៗដើម្បីងាយយល់ស្តាប់យល់នូវសំណួរ ហើយនិងបំណាងនៃការសួរ ដើម្បីឆ្លើយតបនឹងឲ្យបានជាក់ច្បាស់បាទ។

[១៤:១៥:៤៩]

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** ឌុច ខ្ញុំនឹងសួរសំណួរដោយសាមញ្ញៗបំផុត។ នៅក្នុងចម្លើយនេះលោកនិយាយថា នៅពេលដែលលោកនិយាយអំពីចម្លើយសារភាពនេះ សម្តីរបស់លោកខ្ញុំសូមដកស្រង់ "ខ្ញុំធ្វើសេចក្តីសន្និដ្ឋាននេះតាមរយៈសេចក្តីសម្រេចថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ និងសេចក្តីសម្រេចថ្ងៃទី៣០ មីនា ឆ្នាំ១៩៧៦"។ តើលោកបានន័យយ៉ាងម៉េច នៅពេលដែលលោកនិយាយថា ខ្ញុំសំអាង សន្និដ្ឋានទៅលើសេចក្តីសម្រេច

ទាំងអស់នោះ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន រឿងនេះ វាមួយកំណាត់ខាងចុងទៅហើយទេ ខាងដើមមិនដឹងជារឿងស្អីទេ។ ក៏ប៉ុន្តែខ្ញុំបានឃើញសេចក្តីសម្រេច ថ្ងៃ០៩ តុលា ១៩៧៥ ហើយនិងសេចក្តីសម្រេចថ្ងៃ៣០ មីនា ឆ្នាំ១៩៧៦ ទាក់ទងនឹងភារកិច្ចរបស់ សុន សេន ថ្ងៃ០៩ តុលា ១៩៧៥ នេះ គឺ ប៉ុល ពត គាត់ចាត់តាំងឲ្យ សុន សេន ទទួលសេនាធិការ ហើយនិងទទួលខាងសន្តិសុខ។ ឯចំណែកសេចក្តីសម្រេចថ្ងៃ៣០ មីនា នេះ ប៉ុល ពត គាត់សម្រេច អ្នកដែលមានសិទ្ធិសម្រេចកម្ទេច ទាំងក្នុងជួរ និងក្រៅជួរមានបួនក្រុម។ ក្រុមទីមួយ គឺអចិន្ត្រៃយ៍មជ្ឈិម, ក្រុមទីពីរ គឺអចិន្ត្រៃយ៍ភាគ, ក្រុមទីបី គឺប្រធានគណៈកម្មាធិការមន្ទីរមជ្ឈិម, ហើយនិងក្រុមទីបួន គឺសេនាធិការនេះឯង។ នេះខ្ញុំសូមសរុបតាមតែខ្លឹមសារដែលឆ្លងពីក្រោមហ្នឹង ពីខាងដើមមក ខ្ញុំមអត់បានដឹងទេ ប៉ុន្តែខ្ញុំសរុបនេះ សរុបវាទាក់ទងនឹងខាងដើមដែរ ហើយវាមានក្រឹត្យក្រមជាទូទៅផង។

[១៤:១៧:៥៥]

**ស៖** សូមអធ្យាស្រ័យចំណុចចុងក្រោយដែលលោកបាននិយាយ ដែលថា វាជាក្រឹត្យក្រមចុងក្រោយទូទៅ។ តើលោកមានន័យយ៉ាងម៉េច ក្រឹត្យក្រមទូទៅនេះ?

**ឆ៖** ក្រឹត្យក្រមទៅទូទៅ ៗអាសេចក្តីសម្រេចថ្ងៃ៣០ មីនា នេះ វាជាក្រឹត្យក្រមទូទៅ។ នៅទីណាក៏គេអនុវត្តបែបនេះ ជាពិសេសនៅកម្ពុជា កន្លែងណាក៏ដោយ ក៏គេអនុវត្តបែបនេះ។ ហើយអាសេចក្តីសម្រេចថ្ងៃ០៩ តុលា នេះ ក៏ជាការអនុវត្តទូទៅដែរ គឺ សុន សេន គាត់មានភារកិច្ចអ៊ីចឹង កាន់កាប់ខាងសេនាធិការកងទ័ពមជ្ឈិម ហើយនិងទទួលភារកិច្ចខាងសន្តិសុខទូទាំងប្រទេស។

[១៤:១៨:៥៥]

**ស៖** ត្រង់ចំណុចដដែលនេះ ខ្ញុំសូមបង្ហាញសាជាថ្មី ឯកសារ D228។ ERN ជាភាសាអង់គ្លេស គឺ 00398231 ដល់លេខ 00398233។ ខ្មែរ ERN គឺ 00398224 ដល់លេខ 00398225 បារាំងគឺ 00398239 និងទំព័របន្ទាប់។ លោកមានឯកសារនេះ នៅចំពោះមុខលោករួចមកហើយ សំណួររបស់ខ្ញុំនេះ ចង់សួរថា ប្រសិនបើលោកមានឯកសារក្រដាសនៅចំពោះមុខលោក។ ខ្ញុំសូមដកស្រង់សម្តីប្រអប់ដែលចាប់ផ្តើមដោយសំណួររបស់ចៅក្រមស៊ើបអង្កេត“ចម្លើយសារភាព ពៅ-- ចម្លើយសារភាពរបស់ ពក ដែលវាពាក់ព័ន្ធទៅនឹងខែកក្កដា ឆ្នាំ១៩៧៧”។ ពាក់ព័ន្ធទៅនឹងចម្លើយសារភាព លោកលើក

ឡើងថា ការវិភាគរបស់ខ្ញុំនេះ គឺថាបញ្ជូនទៅ នួន ជា ដោយ សុន សេន ដែលគាត់ទុកមួយច្បាប់។ ប្រហែល នួន ជា ដែលធ្វើសេចក្ដីសម្រេចចាប់មន្ទីរ៧០៣។ ខ្ញុំធ្វើសេចក្ដីសង្ខេបជូន ប៉ុល ពត តែប៉ុណ្ណោះ។ ចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា មិនឃើញមានសេចក្ដីសង្ខេបដែលរកឃើញនៅក្នុងសំណុំរឿននោះទេ។ លោកបានឆ្លើយថា យើងមិនបានឃើញសេចក្ដីសង្ខេបដែលធ្វើជូន ប៉ុល ពត នោះទេ។ បញ្ហាទាំងឡាយត្រូវតែរាយការណ៍ជូន ប៉ុល ពត។ សេចក្ដីសម្រេចថ្ងៃ៩ ខែតុលា ឆ្នាំ១៩៧៥ ចែងថាបុគ្គលទាំងឡាយត្រូវតែឲ្យសម្ពហភាពដឹង។ សេចក្ដីសម្រេចថ្ងៃទី៣០ ខែមីនា ១៩៧៦ ចែងថាឲ្យ នួន ជា ដែលត្រូវធ្វើរបាយការណ៍នេះជូន ប៉ុល ពត។ ខ្ញុំសូមដកស្រង់ បញ្ចប់សម្ដីនេះ។

[១៤:២១:៣៩]

ឌុច ខ្ញុំអានចម្លើយរបស់លោក លោកបានប្រើពាក្យថា "ការវិភាគរបស់ខ្ញុំ ឬក៏ នួន ជា ជាអ្នកវិភាគ"។ តើលោកមានធ្លាប់ឃើញឯកសារសង្ខេបវិភាគនោះដែលរកមិនឃើញដែរឬទេ? ហើយឯកសារវិភាគនុ៎ងមានធ្លាប់ធ្វើឡើងដែរឬទេ? ឯកសារសង្ខេបនុ៎ង? ហើយថាតើលោក នួន ជា ជាអ្នកធ្វើការរាយការណ៍ទៅ ប៉ុល ពត ដែរឬទេ? ខ្ញុំសូមសួរលោក ឌុច។ តើត្រឹមត្រូវដែរឬទេ នៅពេលដែលយើងនិយាយថាលោកផ្អែកសំអាងការវិភាគរបស់លោក លើការសន្និដ្ឋានអំពីហេតុការណ៍ដែលបានកើតឡើងក្នុងកម្ពុជាប្រជាធិបតេយ្យ? ជាពិសេសលោកសន្និដ្ឋានទៅលើជួរដឹកនាំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោក តើខ្ញុំបញ្ជាក់ចំណុចនេះត្រឹមត្រូវដែរឬទេ?

[១៤:២២:៤១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីជាតិ មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

លោកប្រធាន ខាងខ្ញុំហ្នឹងតាមលែងទាន់ហើយ មិនដឹងថាសាក្សីតាមទាន់អត់ បើសំណួរច្រើនយ៉ាងនេះ ហើយអ្វីដែលបានអានលើកឡើងមកក៏ច្រើនទៀត។ អ៊ីចឹងគួរតែស្នើសុំឲ្យលោកមេធាវីធ្វើសំណួរឲ្យសាមញ្ញ ខ្លី ស្រួលយល់ ហើយនិងអាចឆ្លើយបាន។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទសំណើសុំនេះត្រឹមត្រូវពិតប្រាកដហើយ ទំនងជាសាក្សីក៏ដូចជាមិនក្ដាប់បានដែរលើការបង្ហាញហើយនិងការអានឡើងដោយមេ-- ក្រុម-- ដោយមេធាវីរូបនេះ។ ចំពោះបញ្ហានេះសូមមេធាវីបញ្ជាក់

ឲ្យបានច្បាស់លាស់ ហើយបើសិនចាំបាច់ឲ្យសាក្សីអាន គឺឲ្យសាក្សីអាននូវខ្លឹមសារឲ្យបានច្បាស់លាស់ មុននឹងតាំងសំណួរ ហើយគួរតែត្រូវបានកំណត់ឲ្យបានក្របខ័ណ្ឌសមល្មមដែលអាចនឹងយល់បាន។ អង្គជំនុំជម្រះបានជម្រាបលោកមេធាវីរួចហើយកាលពីព្រឹកមិញ គប្បីយល់អំពីស្ថានការណ៍នៃសង្គមកម្ពុជា។ ពិតមែនតែមានការរីកចម្រើននាពេលបច្ចុប្បន្ន ប៉ុន្តែកាលពីអតីតកាល ប្រជាជនកម្ពុជាយើងខ្ញុំនេះ មានការយល់ដឹងក្នុងការរៀនសូត្រហ្នឹងគឺមានកម្រិតដែរ មិនមែនទូលំទូលាយដូចពួកសហានៅអឺរ៉ុប ឬក៏នៅសហរដ្ឋអាមេរិកទេ លើការរៀនសូត្រនោះ។ ហើយប្រយោជន៍ដើម្បីការពិតទាល់តែសំណួរ តាំងសំណួរឲ្យបានជាក់ច្បាស់ ហើយខ្លីៗសមល្មមនឹងគោលដៅនៃការដែលសួរហ្នឹងគាត់យល់បាន ហើយគាត់ឆ្លើយតបបានផង នោះជាដើម្បីប្រយោជន៍ក្នុងការស្វែងរកការពិត។

[១៤:២៤:៣៣]

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វីល្លៀម ស្មីត៖**

សូម-- ខ្ញុំសូមបញ្ជាក់សាក្សី គឺចង្អុលបញ្ជាក់ត្រង់តែចំណុចដែលថាការវិភាគរបស់ខ្ញុំ។ ដូច្នេះហើយ ឲ្យសាក្សីនោះមើលទៅលើចំណុចខ្លឹមសារហ្នឹងឲ្យបានជាក់លាក់។ នៅចំណុចនោះ គឺក៏បានលើកឡើងថានៅខាងស្តាំ នៅខាងលើ ខាងស្តាំ គាត់បានសរសេរ ៧០៣ និងខាងក្រោមប្រអប់បួនជ្រុងនៅកណ្តាល គាត់បានសរសេរជូន បងនួន មួយច្បាប់ ១១-១១-៧៧។ ចំណុចទាំងអស់នេះ មិនបានសាក្សីឲ្យមើលទេ អម្បាញ់មិញ។ ដូច្នេះហើយ សូមឲ្យសាក្សីមើលឡើងវិញ ក្រោយពីយើងបានស្តាប់ចម្លើយ គឺចាប់ពីនៅខាងលើ ខាងស្តាំ ចុះមករហូត។

**លោក ហ្វាស្តេ ប៉ោ៖**

លោកប្រធាន ខ្ញុំយល់ការជំទាស់របស់សហព្រះរាជអាជ្ញា ហើយខ្ញុំក៏យល់អំពីការព្រួយបារម្ភដែលថាសាក្សី យល់ ឬក៏មិនយល់នោះដែរ។ ដូច្នេះខ្ញុំនឹងព្យាយាមប្រុងប្រយ័ត្ន។ ចំណុចមួយដែលខ្ញុំសុំកត់សម្គាល់នោះ គឺថាខ្ញុំមានការភ្ញាក់ផ្អើល ដែលភាគីជំទាស់ទៅនឹងសំណួរដែលខ្ញុំសួរទៅកាន់សាក្សី មុនពេលដែលសាក្សីឆ្លើយ យើងមិនដឹងថាតើសាក្សីនេះ យល់ ឬក៏មិនយល់សំណួរ ឬក៏អាច ឬក៏មិនអាចឆ្លើយផង។ សាក្សីរូបនេះ គឺជាសាក្សីដែលមានសុភវិនិច្ឆ័យ ហើយមានការយល់ដឹងខ្ពង់ខ្ពស់ ជាពិសេសនៅក្នុងវិស័យនៃការសួរចម្លើយ។ ហេតុដូច្នេះ ខ្ញុំគិតថាគាត់មិនចាំបាច់ឲ្យខាងសហព្រះរាជអាជ្ញា ឬភាគីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជួយពន្យល់គាត់នោះទេ។ ខ្ញុំដឹងហើយថា ពេលវេលារបស់ខ្ញុំកំពុងតែដើរ

ទៅមុខហើយ ខ្ញុំទម្លាក់សំណួរនេះចោល ហើយខ្ញុំសូមទុកឲ្យពេលវេលានេះឲ្យមេធាវីខាងជាតិលោក សុន អរុណ សួរ។ ខ្ញុំសូមបញ្ចប់ដោយសួរចំណួរចុងក្រោយ និងចំណុចចុងក្រោយនេះទៅកាន់ ឌុច ដូចតទៅ។

[១៤:២៦:៥៧]

**សួរដោយលោក ហ្សាស្តេ ប៉ោះ**

**ស៖** ឌុច លោកបានលើកឡើងជាច្រើនលើក ជាច្រើនសានៅចំពោះមុខចៅក្រមស៊ើបអង្កេត រួមទាំងនៅចំពោះមុខអង្គជំនុំជម្រះ ថាលោកមិនចាំរឿងរ៉ាវមួយចំនួន ដោយសារតែវាយូរមកហើយ។ ខ្ញុំយល់អំពីចំណុចហ្នឹង។ យើងដឹងថាហេតុការណ៍ វាកើតឡើងយូរមកហើយ ខ្ញុំសូមលើកឡើងថា សក្ខីកម្មរបស់លោកបានបញ្ជាក់ចំណុចមួយចំនួនបានច្បាស់ ហើយខ្ញុំសូមលើកឡើងជូនលោកថា លោកមិនបានដឹងមានអ្វីកើតឡើងនៅក្នុងគណៈអចិន្ត្រៃយ៍ដោយផ្ទាល់នោះទេ ហើយលោកក៏មិនបានដឹងដោយផ្ទាល់អំពីអ្វីដែលកើតឡើងនៅក្នុងគណៈមជ្ឈិមផងដែរ ហើយលោកក៏មិនដឹងថាតើមានអ្វីកើតឡើងដោយផ្ទាល់នៅពេលដែលបញ្ជូនសំណើនេះទៅខាងលើ ហើយលោកក៏មិនដឹងតួនាទីរបស់ នួន ជា នៅក្នុងគណៈអចិន្ត្រៃយ៍ផងដែរ។ អ្វីដែលលោកបានធ្វើ រៀបរាប់នេះ ដោយបានផ្អែកទៅលើសេចក្តីសន្និដ្ឋាន និងអ្វីដែលលោកបានអានតែប៉ុណ្ណោះ។

[១៤:២៧:៥៦]

លោកមិនដឹងអំពីគណៈអចិន្ត្រៃយ៍ គណៈមជ្ឈិម លោកបានដឹងក្រោយពីច្រើនឆ្នាំមកហើយនោះតែប៉ុណ្ណោះ។ សេចក្តីសម្រេចទាំងនោះ ក៏លោកមិនបានដឹងដោយផ្ទាល់នោះផងដែរ។ លោកបានសិក្សាសៀវភៅដោយអ្នកសិក្សាស្រាវជ្រាវ ហើយលោកបានច្របាច់បញ្ចូលព័ត៌មានទាំងអស់នេះយកមកធ្វើជាព័ត៌មានខ្លួនឯង។ ដូច្នេះ ខ្ញុំសូមសួរលោក តើវាត្រឹមត្រូវដែរឬទេ តាមការសង្ខេប ការដឹងរបស់លោកនៅលើព័ត៌មាននៅកម្ពុជាប្រជាធិបតេយ្យ គឺសេចក្តីសម្រេច លោកបានលើកឡើងថា "ប្រសិនបើ លោកចង់ឲ្យខ្ញុំរៀបរាប់អ្វីដែលខ្ញុំបានដឹងដោយផ្ទាល់នោះ ខ្ញុំមិនអាចដឹងទេ"។

[១៤:២៨:៥២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វីណ្ឌៀម ស្មីត៖**

ហេតុផលនៃការជំទាស់របស់យើងខ្ញុំ គឺថាមានសំណើលើកឡើងច្រើនណាស់នៅក្នុងនេះ មានដល់តែ១០ឯណោះ ចំណុចដែលបានលើកឡើង ដែលបានយកមកច្របាច់ប្រចូលគ្នា បង្កើតទៅជាសំណួរមួយសាមញ្ញ។ សំណួរសាមញ្ញគឺគេទារធ្វើការសន្និដ្ឋានថា លោកសាក្សីមិនដឹងអ្វីទាំងអស់នៅក្នុងឆ្នាំ១៩៧៥។ ដូច្នេះសំណួរចុងក្រោយសង្ខេបអម្បាញ់មិញនេះ មិនក្តោបចំណុចសំណើទាំង១០ដែលបានធ្វើឡើងដោយខាងមេធាវីការពារក្តីនោះទេ។ ដូចមេធាវី នួន ជា បានលើកឡើង គឺយើងគួរតែឲ្យមេធាវីបំបែកសំណួរនោះឲ្យបានងាយៗនៅចុងក្រោយនោះ គឺយើងគួរតែ-- យើងឮហើយពីខាងមេធាវី ជាការសន្និដ្ឋាន មិនមែនជាសំណួរនោះទេ។

**លោក ហ្សាស្តេ ប៉ោ៖**

ខ្ញុំកត់សម្គាល់ទៅលើការជំទាស់របស់លោកសហព្រះរាជអាជ្ញា។

[១៤:២៩:៥៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

សូមអរគុណលោកចៅក្រមប្រធាន។ សូមគោរពលោកចៅក្រមប្រធាន លោក លោកស្រីចៅក្រមសាជាថ្មី។ អ្វីដែលលោកមេធាវីការពារក្តីលោក នួន ជា បានលើកឡើងនេះ គឺដូចជាការមិនស្តាប់ទៅលើការណែនាំរបស់លោកចៅក្រមប្រធាន។ ហើយលោកបានថា-- អ៎ បានលើកឡើងថា លោក ឌុច មានសមត្ថភាពគ្រប់គ្រាន់នៅក្នុងការយល់អ្វីដែលលោកមេធាវីបានសួរ។ ហើយហាក់ដូចជារឿងក្តីនេះ គឺសម្រាប់តែករណីលោកមេធាវី ហើយនិងលោក ឌុច តែប៉ុណ្ណោះ។ ហើយមេធាវី ហើយនិងភាគីដទៃទៀតក៏ដូចជាសាធារណជន មិនសំខាន់នៅក្នុងការយល់អ្វីដែលលោកបានមេធាវីបានលើកនោះទេ។ ដូច្នេះសំណូមពរថាសាជាថ្មី ថាសុំឲ្យសំណួរក្តីដែលបានលើកឡើង ក៏ចំណុចដែលបានលើកក្តី គួរតែធ្វើឲ្យសាមញ្ញមែនទែន ហើយមិនមែន-- នេះមិនមែនជារឿងក្តីសម្រាប់តែមនុស្សម្នាក់ ឬពីរនាក់ទេ ជារឿងក្តីសម្រាប់ទូទៅ សម្រាប់ជាតិទាំងមូល។ ហើយដូច្នេះ គួរតែលើកសំណួរ ឬក៏ចំណុចយ៉ាងណា ឲ្យគេអ្នកដទៃទៀត អាចយល់ផងដែរ។ សូមអរគុណច្រើនលោកប្រធាន។

[១៤:៣១:១៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា! បញ្ចាតបទៅនឹងការជំទាស់របស់មេធាវីទាំងពីរ ប្រសិនបើមាន?

**លោក ហ្សាស្តេ ប៉ោ៖**

លោកប្រធាន ខ្ញុំអាចសម្រួលសំណួររបស់ខ្ញុំតាមរបៀបផ្សេង ប្រសិនជាលោកសាក្សីពិបាកយល់បាទ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** ឌុច ប្រសិនបើយើងចង់សង្ខេបអំពីចំណេះដឹងរបស់លោក ដែលលោកបានមាននៅពេលរបបកម្ពុជាប្រជាធិបតេយ្យអំពីអ្វីដែលបានកើតឡើងនៅក្នុងប្រទេស តើអ្វីជាសង្ខេបល្អបំផុតនោះ គឺចម្លើយរបស់លោកនៅអង្គជំនុំជម្រះសាលាដំបូង លោកនិយាយថា អ្វីដែលខ្ញុំចង់និយាយពេលនោះ ខ្ញុំបារម្ភថា ខ្ញុំមិនមានអ្វីប្រាប់ដល់ពិភពលោកឲ្យដឹងទេ។ បាទ តើនេះជាការសង្ខេបត្រឹមត្រូវអំពីការយល់ដឹងរបស់លោកនៅសម័យនោះទេ?

[១៤:៣២:៤៨]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ចម្លើយរបស់មនុស្សម្នាក់ ទៅមនុស្សម្នាក់ទៀត ឆ្លើយក្នុងលក្ខខណ្ឌមួយជាកំណត់ តើគេសួរយើងពីអី? កាលដែលខ្ញុំឆ្លើយជូនសហចៅក្រមស៊ើបអង្កេតនោះ តើសហចៅក្រមស៊ើងអង្កេតកំពុងនិយាយអី ហើយដល់ពេលសួរ គាត់សួរពីអី? បានៗវាច្បាស់។ ដូច្នេះ ខ្ញុំពិតជាបានឆ្លើយអ៊ីចឹងមែន។ បើសិនមាននៅក្នុងកំណាត់ហេតុ។ ហើយច្បិចយកតែម៉ាត់មកសរុបរួមមិនមែនជាការល្អសម្រាប់សួរ ហើយនិងដេញដោល ស្វែងរកការពិត។ ខ្ញុំសុំ ថាខ្ញុំអត់មានសមត្ថភាពនឹងឆ្លើយសំណួរបែបនេះទេ។

**លោក ហ្សាស្តេ ប៉ោ៖**

លោកប្រធាន ខ្ញុំមិនមានសំណួរអ្វីបន្ថែមទៀតទេ ខ្ញុំជូនពេលវេលាទៅសហមេធាវី សុន អរុណដើម្បីបន្ត។ ដូច្នេះ អាស្រ័យអង្គជំនុំជម្រះថាតើសម្រាក ឬក៏ឲ្យគាត់សួរបន្ត? បាទ សូមអរគុណ។

[១៤:៣៣:៥២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ មុននឹងសម្រាក ខ្ញុំមិនចង់លើកបញ្ហាហ្នឹងដដែលទេ ខ្ញុំដឹងថាសហព្រះរាជអាជ្ញាលោក ស្មីត ក្រោកឈរឡើង ហើយស្នើថានៅក្នុងគោលការណ៍ដែលថាឲ្យបានទាំងស្រុងនោះ ជាពិសេសផ្នែកខ្លះនៃឯកសារត្រូវតែអានចំពោះមុខសាក្សី។ យើងរំឭកហើយថា ពីរបីថ្ងៃកន្លងនេះខ្ញុំធ្វើដូចគ្នានេះ។ ខ្ញុំ-- លោក ស្មីត គាត់ជំទាស់ខ្ញុំ ហើយនោះគឺជាពាក្យដែលខ្ញុំប្រើអ្វីដែលគាត់ប្រើផ្នែកមួយគប្បីតែអានផងដែរ ផ្នែកនោះនៅចំណុចនោះ ហើយយើងដឹងថា យើងគួរតែរក្សាទុកនៅពេលសួរតទល់គ្នា។ ដូច្នេះ ខ្ញុំសូមលើកចំណុចនេះឡើងជូនតុលាការ តើសមស្របសម្រាប់មេធាវីការពារក្តី? គួរតែសមស្របសម្រាប់សហព្រះរាជអាជ្ញា? ខ្ញុំឯកភាពជាមួយសាក្សីហើយ លោក ស្មីត គឺថាប្រសិនដែលគាត់សួរដេញដោលយើងនឹងមានសិទ្ធិធ្វើដូច្នោះ។

[១៤:៣៤:៥៥]

យើងត្រូវតែមានវិធានដកស្រង់ផ្នែកណាមួយដាក់ក្នុងបរិបទ ឬក៏សួរត្រូវបានសំណួរ និងចម្លើយទាំងស្រុង ដើម្បីឲ្យលោក លោកស្រីចៅក្រម អាចៗហ្នឹងថ្លឹងថ្លែងនូវសក្ខីកម្ម ថាតើអ្វីដែលបានប្រើនៅ--ជំរុញឲ្យសាក្សី ឬក៏ជួយឲ្យសាក្សីឆ្លើយនោះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

ជាបឋម មេធាវីអន្តរជាតិហ្នឹង លោកបានដឹងហើយ។ ខ្ញុំមិនដកស្រង់សម្តីទេ ហើយខ្ញុំក៏មិនបានសំណួរនាំមុខនោះដែរ។ តាមពិតចំណុចមួយចំនួន ការសួរអំពីបរិបទ គឺវាអាស្រ័យទៅលើចម្លើយពិសេសណាមួយ ថាតើផ្នែកណាមួយគប្បីយកមកបង្ហាញសាក្សី។ នៅក្នុងករណីនេះ ផ្នែកដែលយើងបានដាក់ជូនសាក្សីពិនិត្យនោះ គឺបានរក្សាទុក ឬក៏បញ្ចេញនូវអង្គ-- កត្តាផ្សេងៗ ដោយសាក្សីឆ្លើយ។ ហើយផ្នែកដែលខ្ញុំដាក់ជូនសាក្សីនោះ គឺជាផ្នែកទាំងស្រុង។ ហេតុការណ៍ដែលថាវាមានអត្ថបទខាងដើមនៅខាងក្រោយផ្នែកនោះ គឺមិនមែនថាក្រៅពីបរិបទនោះទេ។ ខ្ញុំមិនយល់ស្របជាមួយលោក កាណាវាស

អំពីបញ្ហានេះទេ។ ពីព្រោះយើងចង់ឈានទៅដល់ចំណុចមួយលម្អិតនោះ គឺថាពេលនោះ យើងនឹងតម្រូវឲ្យអានចម្លើយទាំងស្រុងជូនសាក្សី។

[១៣:៣៦:២២]

នេះពេលជាមូលហេតុមួយដែលថាផ្អែកទៅលើសន្ទានុភាព ឬក៏ថាមូលហេតុសមហេតុសមផលដែលត្រឹមណា ដែលថាពេញលេញ ឬក៏មិនពេញលេញក្នុងបរិបទនីមួយៗ។ បាទ នេះជាការឆ្លើយតបទៅនឹងមេធាវីការពារក្ដី ម៉ៃខល កាណាវាស។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ អង្គជំនុំជម្រះកត់សម្គាល់លើបញ្ហាមតិយោបល់នេះ។ ឥឡូវនេះ ដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ អនុរក្សមន្ទីរឃុំឃាំងអញ្ជើញសាក្សីទៅកាន់បន្ទប់សម្រាករបស់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងបី។ សម្រាកចុះ!

[១៤:៣៧:១៤]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៧ នាទី ដល់ម៉ោង ១៥:០០ នាទី)*

[១៥:០០:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាបន្ត អង្គជំនុំជម្រះសូមផ្ដល់វេទិកាទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសក្នុងការបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ ប្រសិនបើមាន។

សូមអញ្ជើញ!

**លោក សុន អរុណ៖**

សូមគោរពក្រុមប្រឹក្សាអង្គជំនុំជម្រះ។ សូមលោគោរពលោកប្រធាន។ បន្ទាប់ពីសហភាតាខ្ញុំពីរនាក់បានឡើងសាកសួរលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច ជាសាក្សី ខ្ញុំជាមេធាវីជាតិ សូមសាកសួរបន្តទៅទៀត។

[១៥:០១:២៦]

**សួរដោយលោក សុន អរុណ៖**

**ស៖** យោងតាមឯកសារសេចក្ដីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ១៩៧៦ ត្រង់ទំព័រ៦ ស្ដីអំពីរចនាសម្ព័ន្ធរបស់សភា រដ្ឋាភិបាល និងគណៈប្រធានរដ្ឋ ដូចលោកប្រធានសវនាការបានធ្វើការសាកសួរកាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១២ រួចហើយ។ ថ្ងៃនេះខ្ញុំសួរក្នុងឯកសារខាងលើនេះដដែល តែគ្រាន់តែសួរលម្អិតចុះមកដល់រចនាសម្ព័ន្ធរបស់ក្រសួងសន្តិសុខ។ ខ្ញុំចង់សួរ ឌុច ថា បើលោកនៅចាំសូមលោកធ្វើអត្ថាធិប្បាយអំពីរចនាសម្ព័ន្ធក្រសួងសន្តិសុខ ចាប់ពីរដ្ឋមន្ត្រីចុះមក។

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន នៅក្នុងឯកសារថ្ងៃ៣០ មីនានេះ ពិតជាគ្មានលម្អិត ឬក៏និយាយអីទាក់ទងនឹងក្រសួងសន្តិសុខទេ។ ដោយឡែក មានតែកថាខណ្ឌទី១ និយាយអំពីអ្នកដែលមានសិទ្ធិកម្ទេចទាំងបួនក្រុម។

[១៥:០៣:០៩]

**ស៖** ខ្ញុំចង់សួរត្រង់ទំព័រទី៦ ត្រង់កថាខណ្ឌ "ដំណើរការចាត់តាំងជាក់ស្ដែង។ ក្នុងនោះមានសភាមានប្រធាន-- មានគណៈប្រធានរដ្ឋ មានរដ្ឋាភិបាល"។ ក្នុងៗជំពូក១នេះគឺថាសភា និយាយអំពីសភា របៀបរបបធ្វើការមានដូចតទៅ៖ "១) តំណាងទាំងអស់ស្ថិតនៅជាមួយប្រជាជនរបស់ខ្លួនតទៅទៀត។ ២) គណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនកម្ពុជា ប្រធានមានសមមិត្ត នួន គឺលោក នួន ជា។ អនុប្រធានទីមួយ សមមិត្ត ភឹម។ អនុប្រធានទីពីរ សមមិត្ត ម៉ុក។ សមាសភាពផ្សេងទៀត នៃគណៈអចិន្ត្រៃយ៍ទុកឲ្យអចិន្ត្រៃយ៍បក្សរៀបចំពេលក្រោយទាំងអស់ប្រហែលដប់នាក់"។ ចំណុចត្រង់នេះដែលខ្ញុំចង់សួរលោក។

[១៥:០៤:២០]

ក្នុងនេះវាមាននិយាយអំពីលោក នួន ជា ជាប្រធានរដ្ឋសភា ដល់មកៗមករដ្ឋាភិបាលនៅវគ្គទីបីនេះ មានសមមត្តិ ប៉ុល រដ្ឋមន្ត្រីទីមួយ សមមិត្ត វ៉ាន់ ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុក ទទួលខាងការបរទេស។ សមមិត្ត វន ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកខាងការពារប្រទេស។ អ៎! សូមទោស សមមិត្តវន ឧបនាយកទទួលខាងសេដ្ឋកិច្ចហិរញ្ញវត្ថុ, សមមិត្ត ខៀវ ឧបនាយកទទួលខាងការបរទេស។ ហើយបើតាមច្បាប់ក្រោយមកទៀតដូចជា ការសម្រេចរបស់ៗអចិន្ត្រៃយ៍អី របស់អចិន្ត្រៃយ៍គឺទទួលបន្ទុកក្រសួងការពារជាតិ និងសន្តិសុខផង។

[១៥:០៥:៣៧]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអាចធ្វើដូចនីតិវិធីដែលយើងបានដេញដោលមុនទេ? អាចដាក់លេខឯកសារឲ្យបានច្បាស់លាស់ ហើយអត្តសញ្ញាណ ហើយលេខ ERN ផង ដែលយោងទៅ ហើយនិងផ្តល់ឯកសារជាក្រដាសជូនទៅសាក្សី ដើម្បីសាក្សីពិនិត្យ ហើយនិងឆ្លើយតបនឹងសំណួររបស់លោក។ បើធ្វើដូច្នេះ គឺច្បាស់លាស់ និងជឿនលឿនទៅមុខ ពីព្រោះយើងបានកំណត់ដូច្នេះទៅហើយ ដោយសារឯកសារនៅក្នុងការដេញដោលនេះវាច្រើនសន្ធឹកសន្ធាប់ ទំនងជាមិនអាចចងចាំច្បាស់ទេ ហើយការប្រើពាក្យពេចន៍ទៀតសោតក៏មានការច្រឡំបន្តិចបន្តួចហ្នឹងក៏អាចមានបញ្ហាដែរ។

[១៥:០៦:១៩]

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបានរៀបចំឯកសារសម្រាប់ជូនទៅខាងសាក្សីរួចហើយ ក្នុងនេះមានលេខ ERN ខ្មែរលេខ 003141 ជាភាសាអង់គ្លេស 0018281314 ជាភាសាបារាំង 00224366។ ក្នុងនេះ ខ្ញុំនឹងជូនឯកសារទៅខាងសាក្សី។

**ប្រធានអង្គជំនុំ៖**

ឯកសារលេខ D ឬក៏ E? E ប៉ុន្មានទៅ? ប្រាប់តែលេខ ERN។ លេខឯកសារ ក្បាលចំណងជើងលេខ D ឬក៏ E? D ប៉ុន្មាន? E ប៉ុន្មានទៅ?

ចុចក្បាលមីក្រូ លោកមេធាវី!

**លោក សុន អរុណ៖**

លេខ E3/12។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយមន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីមេធាវីដាក់ជូនទៅសាក្សីពិនិត្យ។ ហើយសូមឲ្យបុគ្គលិកជំនួយការមេធាវី អាចដាក់បញ្ចាំងឯកសារនេះលើអេក្រង់កុំព្យូទ័រផងបានទេ?

[១៥:០៨:០១]

**លោក សុន អរុណ៖**

បានបញ្ចាំងលើអេក្រង់កុំព្យូទ័រហើយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី តើលោកចោទត្រង់ចំណុចណាមួយចំពោះសាក្សីរូបនេះ?

សូមអញ្ជើញ!

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំចង់សួរលោកសាក្សីថា នៅក្នុងឯកសារមួយនេះមិនបានបញ្ជាក់ថា លោក នួន ជា ហ្នឹង គាត់ជាអ្នកដឹកនាំកាន់នៅក្រសួងសន្តិសុខ ឬក៏កិច្ចការសន្តិសុខ ដែលលោកបាននិយាយប៉ុន្មានថ្ងៃមក ហើយហ្នឹង និយាយពីរឿង នួន ជា ទទួលបន្ទុកសន្តិសុខនោះ។ សូមឲ្យបញ្ជាក់កន្លែងហ្នឹង។

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ដំបូងខ្ញុំសូមចាប់អារម្មណ៍ថា លោកមេធាវីអានអំពីសមមិត្តខៀវ នេះមិនច្បាស់ទេ អំមិញច្រឡំ។ ក្នុងឯកសារនេះ មែន បើលោកមេធាវីអានទៅខាងលើ "រដ្ឋាភិបាលត្រូវតែជាអង្គការរបស់បក្សសុទ្ធសាធ ជារដ្ឋរបស់យើងផ្ទាល់"។ នេះធាតុពិតមួយ។ ធាតុពិតមួយទៀត សូមលោក អរុណ មើលលក្ខន្តិកៈបក្ស។ "បក្សកុម្មុយនីស្តកម្ពុជាជាបក្សរបស់វណ្ណៈកម្មករ។ បក្សដឹកនាំដាច់ខាត គ្រប់មុខ និងគ្រប់ផ្នែក ទាំងស្រុង និងគ្រប់ផ្នែក"។ ហ្នឹងជាចំណុចមួយសំខាន់ ដែលយើងត្រូវតែយល់។ ហើយបងនួន នេះគាត់អនុលេខាបក្សតាំងពីឆ្នាំ១៩៦០។ ដូច្នេះគ្រប់កិច្ចការទាំងអស់របស់បក្ស ត្រូវតែ បងនួន ហើយនិងបងប៉ុល ជ្រាប។ បងប៉ុល ជាអ្នកសម្រេច បងនួន ជាអ្នកធ្វើ-- អំជាអ្នកតាមដានការអនុវត្ត។ នេះយើងមើលលក្ខន្តិកៈបក្ស ហើយនិងយើងមើលឯកសារថ្ងៃ-- សូមទោស ប្រហែលជាឯកសារថ្ងៃ០៩ ហ្នឹងដែរ និយាយបញ្ហាហ្នឹង សរុបឯកសារទាំងអស់ទៅ ច្បិចតែប៉ុននេះមកអត់បានទេ។

[១៥:១០:៥៧]

**ស៖** ខ្ញុំ-- សូមទោសលោកប្រធាន។ ខ្ញុំមានឯកសារមួយទៀត ក៏បញ្ជាក់ប្រហាក់ប្រហែលគ្នា

ហ្នឹងដែរ។ អានេះជាការប្រជុំអចិន្ត្រៃយ៍ថ្ងៃ០៩ ខែតុលា ឆ្នាំ១៩៧៥ និយាយពីរឿងសមមិត្តអនុប្រធានការងាររបស់គាត់ គឺការងារបក្សសង្គមកិច្ច ទទួលបន្ទុកការងារបក្ស សង្គមកិច្ច វប្បធម៌ ឃោសនា និងសិក្សាធិការ។ អានេះការប្រជុំអចិន្ត្រៃយ៍ថ្ងៃ០៩ តុលា ឆ្នាំ១៩៧៥ ដែលមាន ERN បើចង់បាន ខ្ញុំជូន ERN ទៀត តែអាហ្នឹងខ្ញុំជឿថា លោកសាក្សីប្រហែលជាបានស្គាត់រត់មាត់ក្នុងឯកសារនេះហើយ។

**ប្រធានអង្គជំនុំ៖**

មិនៗអ៊ីចឹងទេលោកមេធាវី សូមលោកប្រាប់លេខ D ឬក៏លេខ E ឲ្យច្បាស់ ហើយបន្ទាប់មកលោកចង់សួរនៅទំព័រមួយណាគឺហៅលេខ ERN ទៀតទាំងបីភាសា ដើម្បីជាប្រតិចារឹក មិនមែនសំដៅថា សាក្សីនេះយល់ចាំ ឬក៏មិនចាំនោះទេ។ ហើយបាទបញ្ចាំង ហើយនិងសូមយកឯកសារជាក្រដាសជូនគាត់ផង។

មន្ត្រីរដ្ឋបាលតុលាការ ទទួលឯកសារជាក្រដាសពីមេធាវីជូនសាក្សីពិនិត្យ ហើយសូមមេធាវីបញ្ជាក់ឡើងវិញអំពីអត្តសញ្ញាណឯកសារដែលត្រូវដាក់ដេញដោល នៅចំពោះមុខអង្គជំនុំជម្រះនេះ ហើយអង្គជំនុំជម្រះអនុញ្ញាតឲ្យបញ្ចាំងឯកសារនេះ នៅលើអេក្រង់កុំព្យូទ័រ។

[១៥:១២:៣៣]

**លោក សុន អរុណ៖**

លេខ IS13.2។ ERN ជាខ្មែរ 0019108 លេខ ERN អង់គ្លេស 00183393 លេខ ERN--

**អ្នកបកប្រែ៖**

លោកប្រធានសូមឲ្យលោក សុន អរុណ យឺតបន្តិចទាន ERN ហ្នឹងលឿនពេក។

**លោក សុន អរុណ៖**

ERN ជាភាសាខ្មែរ 0019108 ERN ជាភាសាអង់គ្លេស 00183393 ERN ជាភាសាបារាំង 00292868។

**សួរដោយលោក សុន អរុណ៖**

**ស៖** ក្នុងឯកសារនេះ គឺការប្រជុំអចិន្ត្រៃយ៍ផង មានបញ្ជាក់អំពីសមាសភាពលោក នួន ជា ជាអនុប្រធានលេខា-- ជាអនុលេខា គឺការងាររបស់គាត់ ការងារបក្សនៅក្នុងការងារបក្ស គាត់កាន់កាប់ខាងសង្គមកិច្ចវប្បធម៌ ឃោសនាការ និងសិក្សាធិការ។ អាហ្នឹង ខ្ញុំចង់សួរថា បើបញ្ជាក់អ៊ីចឹង សូមលោកសាក្សីមេត្តា បំភ្លឺថាតើ នួន ជា ហ្នឹងគាត់មានមុខងារសន្តិសុខយ៉ាងម៉េច?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ដំបូងសូមអធិប្បាយជូនអង្គប្រជុំពីរឿងការងារបក្ស។ បងនួន កាន់កាប់ការងារបក្ស តើការងារបក្សស្អី មិនមែនបើវគ្គរៀនសូត្រទេ "ភរ"។ ឯចំណែកការងារបក្សគឺបញ្ចូលបក្ខជនថ្មី ដំឡើងឋានៈបក្ស ដាក់វិន័យទៅលើបក្ខជនផ្សេងៗទៀតទៅតាម ១០(ខ) កម្មាភិបាល ជ្រើសរើសកម្មាភិបាល និងតាមលក្ខណៈសម្បត្តិបញ្ចូលបក្ស។ ដូច្នេះ យើងមើលឯកសារផ្សេងទៀតបានដឹង ថាអ្នកកាន់កាប់កិច្ចការងារបក្សត្រូវបក្សក្តាប់ប្រវត្តិរូប ត្រូវក្តាប់ប្រវត្តិរូប ហើយនិងជីវទស្សនៈបដិវត្តន៍ ហើយនិងប្រវត្តិសកម្មភាពរបស់បក្ខជនគ្រប់រូបឲ្យច្បាស់លាស់។ ដូច្នេះគឺអនុលេខាហ្នឹងហើយ ដែលក្តាប់ប្រវត្តិរូប ដែលក្តាប់ពីការគុណសម្បត្តិ គុណវិបត្តិរបស់បក្ខជនខាងក្រោមមួយៗហ្នឹង។ ដូច្នេះការអនុវត្តវិន័យក៏បក្ស-- នែនេះដែរ ក៏បក្សជាអ្នកសម្រេចដែរ។ មិនមែនអ្នកណាសម្រេចទេ គឺបក្សសម្រេច។ តើអ្នកណាសម្រេច? ជាគោលការណ៍គឺបង ប៉ុល។

[១៥:១៥:៥៦]

ក៏ប៉ុន្តែនេះឯកសារដដែលនេះ ដែលលោក អរុណ បង្ហាញយើងទាំងអស់គ្នានេះ គឺសូមលោក អរុណ អ៎!សូមទោស សូមលោកមេធាវីមើលត្រង់ទំព័រ-- នេះមើលត្រង់ទំព័រ៥ បន្ទាត់ទីបី។ "ទន្ទឹមនេះបើសមមិត្តណាម្នាក់មិននៅ សមមិត្តឯទៀតជំនួស"។ នេះឃ្លានេះ គោលការណ៍នេះប្រើវាអស់កេរ អស់កាលយូរមកហើយ បើលេខាមិននៅអនុលេខាជំនួស។ ដូច្នេះក្នុងឯកសារនេះវាគ្រាន់តែជាការរម្លឹកទេ។ នេះបូកជាមួយនឹងលក្ខន្តិកៈបក្សដែលថាបក្សដឹកនាំគ្រប់ផ្នែកការងារ ដឹកនាំទាំងស្រុង និងដឹកនាំដាច់ខាត។ ដូច្នេះការងារយោធារបស់បក្ស ការងារសេដ្ឋកិច្ចរបស់បក្ស ការងារនគរបាលក៏របស់បក្ស។ ដូច្នេះ អនុលេខាជាអ្នកតាមការអនុវត្ត លេខាជាអ្នកសម្រេច។ នេះគោលការណ៍ដែលមានចែងទាំងអស់បូកសរុបគ្នា។

[១៥:១៧:៣២]

**ស៖** សូមអរគុណ។ ខ្ញុំសូមលោកសាក្សីមេត្តាជម្រាបជូនមកអង្គសវនាការ អំពីរចនាសម្ព័ន្ធរបស់ក្រសួងសន្តិសុខ១ និងការពារជាតិ។

**ឆ៖** អរគុណ។ នេះតាមការដឹងឮ ហើយនិងតាមការអនុវត្តទេ។ ក្រសួងការពារជាតិ សុន សេន គាត់ជាសេនាធិការ ហើយទទួលបន្ទុកក្រសួងការពារប្រទេសផង។ កាលណោះ ជំនាន់នោះយើងហៅការពារប្រទេស អត់មានហៅការពារជាតិទេ។ ការពារប្រទេសហ្នឹងគ្រាន់តែលើកស្លាកមួយចោល

ទៅ។ តាមពិតគាត់ដើរតួជានាយអគ្គសេនាធិការកងទ័ពបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យ ក្នុងនុ៎ងវាមានគណៈកម្មាធិការសេនាធិការរបស់គេមួយ។ គណៈកម្មាធិការសេនាធិការនេះ វាមានសិទ្ធិសម្រេចកម្មេចរបស់វាដែរ។ បក្សយោងតាមកថាខណ្ឌទី១ នៃសេចក្តីសម្រេចចិត្តថ្ងៃ៣០ មីនា ១៩៧៦។ ក៏ប៉ុន្តែក្នុងកិច្ចដំណើរការខាងការងារយោធា វាមានគណៈកម្មាធិការសេនាធិការរបស់គេច្បាស់លាស់។

[១៥:១៨:៥៦]

ដំបូងចាត់តាំងគណៈអចិន្ត្រៃយ៍សេនាធិការមានបី-- មានបីរូប គឺបង សុន សេន សមាជិកមជ្ឈិមត្រៀម ប្រធានគណៈកម្មាធិការសេនាធិការ។ ម៉ែន សាន ហៅ យ៉ា អនុប្រធានគណៈកម្មាធិការសេនាធិការមជ្ឈិមពេញសិទ្ធិ។ សៀត ឆែ ហៅ ទុំ សមាជិកមជ្ឈិមត្រៀម សមាជិកគណៈកម្មាធិការសេនាធិការ។ ហើយក្រៅពីនោះមានជំនួយការគេផ្សេងទៀតដូចជា មាស មុត, ស៊ូ ម៉េត, អ៊ិន ណាត, ពេជ ឆន ហៅ សោម, ទាញ ខាងភស្តុភារជាដើម។ នេះវាមានកិច្ចដំណើរការរបស់គេអ៊ីចឹង។

[១៥:១៩:៣៧]

ដោយឡែក ដោយ សុន សេន គាត់កាន់កាប់ខាងសន្តិសុខ អាស-២១ នេះវាក្រោម សុន សេន ផ្ទាល់ ខាងការងារសន្តិសុខ។ ខាងខ្សែសន្តិសុខទេ អ្ហឺ! ក៏ប៉ុន្តែការងារសន្តិសុខនេះវាជារបស់បក្ស វាស្ថិតនៅក្រោមការគ្រប់គ្រងរបស់លេខា និងអចិ-- អនុលេខាមជ្ឈិមបក្ស។ នេះខ្ញុំសូមពន្យល់ នែ៎ និយាយបញ្ហានេះតាមការជាក់ស្តែង ហើយនិងការដែលបានធ្វើ។

**ស៖** សូមអរគុណ។ លោកសាក្សីបាននិយាយហើយពីរឿងរចនាសម្ព័ន្ធ ប៉ុន្តែរចនាសម្ព័ន្ធហ្នឹងមានចែងជាឯកសារអីត្រឹមត្រូវទេ? ដែលរហូតមកដល់ថ្ងៃនេះតុលាការមានឯកសារហ្នឹងទេ រចនាសម្ព័ន្ធរបស់ក្រសួងសន្តិសុខ? ហើយលោកគ្រាន់តែនិយាយទេ តាមការដែលលោកបានប្រព្រឹត្តមកហើយ បានអនុវត្តមកហើយអ៊ីចឹង ឬក៏ថាមានឯកសារជាផ្លូវការត្រឹមត្រូវ? តែងតាំងតាមខ្សែបណ្តោយ ខ្សែទទឹងរបស់បក្សអ៊ីចឹងទៅ។

[១៥:២០:៥៦]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បើនិយាយពីការងារសន្តិសុខ ការងារសន្តិសុខទូទាំងប្រទេសវាមានយ៉ាងតិច១៩៦ មន្ទីរនគរបាល។ កាលនោះខ្ញុំមិនដឹងជាមានប៉ុន្មានទេ។ ហើយអា ស-៧១ នេះវាគ្រប់គ្រងស្អីខ្លះ? ខ្ញុំបានសរុបនៅក្នុងនេះហើយ។ ក៏ប៉ុន្តែឯកសារចាត់តាំងមិនទាន់បានបង្ហាញជូនដោយការិយាល័យសហព្រះរាជអាជ្ញាទេ។ ខ្ញុំមិនជឿថាអត់ឯកសារ ឬក៏អត់មែនក៏មិនដឹង ក៏ប៉ុន្តែកិច្ច

ដំណើរការគឺអ៊ីចឹង។ ពីខ្ញុំទៅ មុនដំបូងទៅ សុន សេន ហើយ សុន សេន គាត់តែងនិយាយពី បងនួន អ៊ីចេះ បងនួន អ៊ីចុះ។ ខ្ញុំបាននិយាយហូរហែមកហើយ។ ដូច្នេះ លក្ខន្តិកៈបក្សវាច្បាស់ណាស់ នៅក្នុងផ្នែកទីមួយ និយាយអំពីលាក់ការណ៍និងគោលជំហរជាយុទ្ធសាស្ត្រមួយចំនួន និងគោលជំហរនយោបាយជាយុទ្ធសាស្ត្រមួយចំនួនរបស់បក្ស។ បក្សកុម្មុយនីស្តកម្ពុជា អាហ្នឹងក្នុងនេះ កថាខណ្ឌទី១ "បក្សកុម្មុយនីស្តកម្ពុជាជាបក្សរបស់វណ្ណៈកម្មករ"។ កថាខណ្ឌទី២ "បក្សដឹកនាំផ្តាច់មុខ ដាច់ខាត និងទាំងស្រុងគ្រប់ផ្នែក"។ ដូច្នេះបក្សហ្នឹងសំដៅអ្នកណា គឺសំដៅ ប៉ុល ពត និង នួន ជា នេះឯង។

[១៥:២២:៣២]

**ស៖** អរគុណ។ ធម្មតារដ្ឋាភិបាលរបស់ប្រទេសណាក៏ដូចប្រទេសណាដែរ។ ខ្សែបណ្តោយរបស់បក្ស គឺធ្វើតាំងពីនាយករដ្ឋមន្ត្រីចុះមករដ្ឋមន្ត្រីចុះមករហូត។ បន្ទាប់ពីរដ្ឋមន្ត្រីមកមានអនុរដ្ឋមន្ត្រីអ៊ីចឹង។ លោកអំមិញបានបញ្ជាក់ប្រាប់តុលាការហើយ ថាបន្ទាប់ពី សុន សេន គឺ ម៉ែន សាន...។ល។ ការងាររបស់ សុន សេន ទោះបីគាត់នៅ ឬមិននៅ វាត្រូវទៅផ្តាប់មកនូវអ្នកបន្ទាប់។ លោកសាក្សីកាលពីសម័យស-២១ ក្តី ថាស-២១ ចុះ លោកមានឋានៈស្មើនឹងវរសេនាធំ។ លោកនិយាយទាំងប៉ុន្មានរហូតមកដល់ថ្ងៃនេះ លោកថាអ្វី សុន សេន គឺផ្ទាល់ជាមួយលោក លោកផ្ទាល់ជាមួយ សុន សេន លោកផ្ទាល់ជាមួយនឹង នួន ជា។ អានេះធ្វើឲ្យខ្ញុំសង្ស័យថា ការងារនេះដូចជាមិនអ៊ីចឹងទេ។ គេមានឋានានុក្រមរបស់គេ។ សូមលោកបញ្ជាក់ត្រង់ហ្នឹង ថាតើឋានានុក្រមរបស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹងអ៊ីចឹងដែរ ឬក៏ថា ធ្វើដូចបាយឡុកបាយឡ?

[១៥:២៣:៥៨]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមអនុញ្ញាតឆ្លើយនឹងសំណួរលោកមេធាវីដូចតទៅ។ លោកមេធាវីមានប្រសាសន៍ថា រចនាសម្ព័ន្ធប្រទេសណាក៏គេធ្វើអ៊ីចឹង តែលោកមេធាវីក្រឡេកមើលទៅចិនប្រជាមានិត សម័យប្រធានាធិបតី ហ្វា គុយហ្វឹង លោកប្រធាន ហ្វា គុយហ្វឹង ប្រធានបក្ស។ ប្រធានបក្សកាន់កាប់តួនាទីជានាយរដ្ឋមន្ត្រី អនុប្រធាន យី ជៀនយីង ប្រធានសភា លីសៀននៀន ប្រធានាធិបតី។ តើ លីសៀននៀន មានអំណាចទេ អត់ទេ? យី ជៀនយីង មានអំណាចទេ? អត់ទេ។ គេយកបុគ្គលចាស់ទុំម្នាក់ហ្នឹងមកតាំងទៅ សម្រាប់ជានិមិត្តរូប ថាអ្នក គោរពចាស់ទុំប៉ុន្នុំង។ នេះ យី ជៀនយីង។ នេះការចាត់តាំងនេះវាដូចគ្នា។

[១៥:២៥:០២]

ខ្ញុំសូមបញ្ជាក់ថា កម្ពុជាប្រជាធិបតេយ្យ វាចម្លងតាមពុម្ពគំរូនៃមហាបដិវត្តន៍វប្បធម៌ ដែលមានពីឆ្នាំ១៩៦៦ ដល់ឆ្នាំ១៩៧៦។ នេះរចនាសម្ព័ន្ធវាអ៊ីចឹង។ នេះខ្ញុំសូមនិយាយអំពីរចនាសម្ព័ន្ធប៉ុណ្ណឹងចុះ។ ដូច្នេះ វាអត់ប្លែកទេ វាអត់បាយឡុកបាយឡអីទេ លក្ខន្តិកៈបក្សវាច្បាស់ហើយ។ រចនាសម្ព័ន្ធខាងសេនាធិការវាច្បាស់ហើយ ខាងការងារសេនាធិការ គឺវាមានគណៈកម្មាធិការរបស់គេមួយ។ ឯចំណែកការងារសន្តិសុខ វាមិនទាន់មានគណៈកម្មាធិការទេ គ្រាន់តែ សុន សេន, ប៉ុល ពត គាត់ចាត់ឲ្យរៀបជួយការងាររបស់គាត់។ សរុបឯកសារស្អី សុំយោបល់សម្រេចរបស់គាត់។ សន្តិសុខទាំង១៩៦ យ៉ាងតិចទូទាំងប្រទេសនេះ វារាយការណ៍មកអចិន្ត្រៃយ៍ អចិន្ត្រៃយ៍ហុចទៅឲ្យ សុន សេន។ សរុបរៀបចំឯកសារ។ នេះភស្តុតាងដែលនៅសល់ គឺវាឃើញអ៊ីចឹង។ នេះសូមវាបញ្ជាក់ប៉ុណ្ណឹង។

[១៥:២៦:០៥]

**ស៖** សូមអរគុណ។ ខ្ញុំចាប់អារម្មណ៍ត្រង់លោក អ្ហ៎!សាក្សីបានបញ្ជាក់ប្រាប់តុលាការថា នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ ក្រោយពេលដែលសុន សេន ទៅបំពេញបេសកកម្មនៅបូព៌ា គឺនៅអ្នកលឿងនោះលោកបានបញ្ជាក់ថា ឯកសារសារភាព ឯកសារសំខាន់ៗផ្សេងៗ លោកយកទៅឲ្យលោក នួន ជា។ តើរឿងនេះយ៉ាងនេះយ៉ាងម៉េច បានជាលោកនិយាយដូច្នេះ? ពីព្រោះថានាទុក្រមរបស់រដ្ឋាភិបាលនីមួយៗលោកបានបញ្ជាក់អម្បាញ់មិញហើយថា ស្រុកចិនគេធ្វើអ៊ីចឹង ប៉ុន្តែដល់ស្រុកខ្មែរយើង ខ្ញុំមិនបាននៅជាមួយ ប៉ុន្តែខ្ញុំគ្រាន់តែមានការឆ្ងល់ ហើយសួរលោកថា តើរចនាសម្ព័ន្ធរបស់សន្តិសុខ វាធ្វើអ៊ីចឹង ឬក៏ថាពីធំធ្លាក់-- កាលណាអ្នកធំមិននៅ ធ្លាក់មកដល់អ្នកបន្ទាប់។ អានេះការចង់បញ្ជាក់របស់ខ្ញុំគឺអ៊ីចឹង ហើយតើលោកអាចពន្យល់តទៅទៀតបាន។

[១៥:២៧:០៩]

**ឆ៖** អរគុណ។

**ស៖** ម៉េចក៏ឡើងទៅលើទៅវិញ ម៉េចក៏ឡើង នួន ជា ទៅវិញ? ម៉េចក៏មិនចុះមកក្រោម?

**ឆ៖** អរគុណៗ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមបញ្ជាក់ថា អត់ពី សុន សេន ត្រូវឡើងទៅ នួន ជា ពីព្រោះ នួន ជា ជាអនុលេខាបក្ស ហើយនៅក្រោម សុន សេន មិនមានអ្នកណាទេចាត់តាំងនោះ។ គ្មានៗទេ គ្មានអ្នកណាទេ។ បើនៅពីក្រោម សុន សេន គឺមានតែ ខៀវ សំផន។ បើនិយាយពីក្នុងលំដាប់មជ្ឈិមបក្ស ហើយខៀវ សំផន ណាទៅអំពល់រវល់នឹងអារឿងហ្នឹង។ គេមិនចាត់តាំងខៀវ សំផន ឲ្យខាងនុ៎ងទេ។ នេះវាច្បាស់ដែរ។ ដូច្នេះ ឌុច វាត្រូវឡើងទៅដល់កំពូលពីលើ សុន

សេន ហ្នឹងបន្តិចទៅទៀត។ បានន័យថា នួន ជា គាត់បន្ទាបខ្លួនមកស្តាប់សេចក្តីរាយការណ៍របស់ ឌុច។ មកទទួលឯកសារពី ឌុច។ មកចាត់ចែងគ្រប់កិច្ចការងាររបស់ ស-២១ តាមរយៈ ឌុច។

[១៥:២៨:២០]

**ស៖** ចុះអំមិញលោកបានជម្រាបតុលាការថា ក្នុងរចនាសម្ព័ន្ធរបស់ក្រសួងសន្តិសុខមាន សុន សេន បន្ទាប់មក ម៉ែន សាន, មាន ស៊ុន ឆៃ អីទាំងអស់ហ្នឹង។ ជាមនុស្សយ៉ាងម៉េច?

**ឆ៖** អរគុណៗ។ ជម្រាបប្រសាសន៍លោក អរុណ អ៊ំ! ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមឆ្លើយជាមួយលោក អរុណៗ បន្តំហើយ បន្តខ្ញុំហើយ។ ខ្ញុំនិយាយតែសេនាធិការ មិនមែនខាងសន្តិសុខទេ។ សន្តិសុខ វាអត់ទាន់មានចាត់តាំងជាគណៈកម្មាធិការសន្តិសុខទូទាំងប្រទេស វាមាន សុន សេន មួយជាកំពូល។ ដើម្បីសរុបឯកសាររាយការណ៍ទៅ បងប៉ុល ហើយ បងប៉ុល គាត់សម្រេចយ៉ាងម៉េច? បងនួន ជាអ្នកទទួលខុសត្រូវក្នុងការតាមដានការអនុវត្ត។ ដូច្នេះ សន្តិសុខ-- មន្ទីរសន្តិសុខទាំង១៩៦ យ៉ាងតិច ទូទាំងប្រទេសនេះ វាត្រូវរាយការណ៍មកអចិន្ត្រៃយ៍មជ្ឈិម។ ដូច្នេះ ឯចំណែក សុន សេន បងយ៉ា ហើយនិង បងទុំ គណៈកម្មាធិការសេនាធិការទេ ចាត់ចែងខាងកិច្ចការប្រយុទ្ធ ខាងកាំភ្លើង ខាងជម្លោះអាវុធ អីៗនុ៎ង។

**ស៖** តាមការណែនាំ-- តាមការពន្យល់របស់លោកសាក្សី មានន័យថាលោក សុន សេន ហើយក្រៅពីសុន សេន គឺមិនមានអ្នកបន្តបន្ទាប់ទេ។ អ៊ីចឹងហើយបានជា សុន សេន ធ្វើរបាយការណ៍-- អ្ហឺ! ដូចជាលោកប្រធានមន្ទីរទាំងអស់ហ្នឹង ធ្វើរាយការណ៍ទៅលោក នួន ជា អ៊ីចឹងខុស ឬត្រូវ?

[១៥:៣០:១៣]

**ឆ៖** អរគុណ។ បញ្ហានេះ លោកសួរហ្នឹង ត្រឹមត្រូវហើយ ខ្ញុំសូមបញ្ជាក់បញ្ហានេះ។ សន្តិសុខទូទៅទាំងប្រទេសរាយការណ៍មកអចិន្ត្រៃយ៍មជ្ឈិម មិនមែនរាយការណ៍មក សុន សេន ទេ។ បានឯកសារហើយ ប៉ុល ពត រុញឯកសារហ្នឹង មកឲ្យ សុន សេន គាត់ក្តាប់សរុបដើម្បីរៀបចំឯកសារឲ្យគាត់ស្រួលក្តាប់ ស្រួលសម្រេច។ ដូច្នេះ អត់ពី សុន សេន ទៅ អ្នកដែលទទួលខុសត្រូវគឺ បងនួនផ្ទាល់តែម្តង។ ឯកសារមកពីភូមិភាគទាំងប៉ុន្មាន បងនួន ដឹងឮ បងនួន សម្រេច។ នេះជារឿងពិត។

**ស៖** សូមអរគុណ។ បើតាមលោកដឹង ហើយលោកធ្លាប់ទទួលឯកសារផ្សេងៗពី សុន សេន ក្តី ពី នួន ជា ក្តី តើមានត្រា ឬហត្ថលេខាអីពីអស់លោកធំៗហ្នឹងទេ?

[១៥:៣១:២០]

**ឆ៖** អរគុណ។ ត្រា ខ្ញុំឃើញបោះតែម្តងគត់ គឺនៅលើត្រាក់ ដែលបាចដើម្បីជម្រាបប្រជាជនថា សោ ភឹម ក្បត់ បាចតាមកប៉ាល់ហោះ។ ក្រៅពីនោះ មានតែត្រាកម្ពុជាប្រជាធិបតេយ្យពីរបែប ត្រាស្លូត ហើយនិងត្រាសើម។ បោះនៅលើសំបុត្រដោយដើរផ្លូវពិសេស។ ក្រៅពីនោះគ្មានឃើញត្រា គ្មានឃើញហត្ថលេខាទេ។

[១៥:៣២:០៧]

**ស៖** ខ្ញុំឆ្លងទៅសំណួរមួយទៀត លោកបានឆ្លើយប្រាប់ទៅសហព្រះរាជអាជ្ញាកាលពីថ្ងៃ-- កាលពីអាទិត្យមុនថា បើនិយាយពីបក្សគឺប៉ុល ពត នួន ជា។ បើនិយាយពីបញ្ជាចាប់ ឬក៏កម្ទេចគឺ ប៉ុល ពត នួន ជា។ បើនិយាយពីបញ្ជាកម្ទេច ឬក៏បញ្ជាធំៗ គឺ ប៉ុល ពត នួន ជា ។ល។ ត្រង់ចំណុចនេះ ខ្ញុំសូមឱ្យលោកពន្យល់តុលាការផងមើល៍ ថាអ្វីទៅហៅថា “បក្ស”។ បក្ស នោះ ជាមនុស្ស។ បក្សនោះ ជាសត្វ ឬក៏បក្សនោះ ជាវត្ថុអរូប ឬវត្ថុមានរូប ឬគ្រាន់តែទ្រឹស្តីសម្រាប់ធ្វើការចោទប្រកាន់ ហើយឱ្យធ្វើមនុស្សយល់ច្រំដើម្បីសម្លាប់ ឬយកទៅដាក់ច្រវាក់ដាក់គុកតែប៉ុណ្ណោះ។

**ឆ៖** អរគុណ។ បក្សនេះ បើនិយាយក្នុងន័យជាទ្រឹស្តី គឺជាការប្រមូលផ្តុំនៃយុទ្ធជន និងកម្មាភិបាលមួយចំនួនដែលបានចូលបក្សហើយ។ ទន្ទឹមនេះ វាមានអង្គការស្នូលរបស់វា។ មានយុវកកជនបង្គោល សមាគមនារី សមាគមកសិករ សហជីពកម្មករ។ ទាំងអស់នេះសរុបមក ហៅ “បក្ស”។ ក៏ប៉ុន្តែយើងមើលក្នុងលក្ខន្តិកៈបក្ស វិន័យបក្ស ថ្នាក់ក្រោមគោរពថ្នាក់លើ។ ទូទាំងប្រទេស គោរពមជ្ឈិមបក្ស និងអំណាចប្រមូលផ្តុំនៅក្នុងកណ្តាប់ដៃអចិន្ត្រៃយ៍មជ្ឈិម អំណាចគ្រប់ផ្នែកប្រមូលផ្តុំក្នុងបណ្តាប់ដៃមជ្ឈិម គឺក្នុងកណ្តាប់ដៃលេខាបក្សហ្នឹងតែម្តង។

[១៥:៣៤:២៤]

**ស៖** សូមលោកសាក្សីបញ្ជាក់ម្តងទៀតថា នៅលើ ប៉ុល ពត ឬនៅលើមជ្ឈិមតែម្តង។ ពាក្យហ្នឹងយ៉ាងម៉េច? ខុសគ្នាយ៉ាងម៉េច?

**ឆ៖** អរគុណៗ។ ជម្រាបប្រសាសន៍លោកប្រធាន យើងខ្ញុំពីរនាក់វាធ្លាប់រាប់អានគ្នា។ ដូច្នេះវាចេះភ្លាត់។ សូមទោស អង្គជំនុំជម្រះហើយ សូមបញ្ជាក់ថា ខ្ញុំសូមឆ្លើយថា បក្សហ្នឹង ដូចជាខ្ញុំជម្រាបអំមិញអ៊ីចឹង។ ជាទ្រឹស្តី វាជាអង្គប្រជុំប្រមូលផ្តុំមនុស្សមួយចំនួនដែលបានចូលអង្គការស្នូលរបស់បក្ស ហើយនិងបក្ខជន។ ហើយបក្ខជននោះវាមានលំដាប់ថ្នាក់របស់វា។ លំដាប់ថ្នាក់ខ្ពស់បំផុតដែលទទួលខុសត្រូវទូទាំងប្រទេសពីមហាសន្និបាតមួយទៅមហាសន្និបាតមួយគឺអចិន្ត្រៃយ៍មជ្ឈិមបក្ស។ ក្នុងអចិន្ត្រៃយ៍

មជ្ឈិមបក្សនេះ អំណាចប្រមូលផ្តុំនៅហ្នឹងលេខានិងអនុលេខា។ យើងមើលក្នុងសេចក្តីសម្រេចចិត្តថ្ងៃ ០៩ តុលា ១៩៧៥។ លេខាទទួលរួម ការងារបក្ស ការងារយោធា អ៉ន៉េ! សូមទោស ទទួលរួមការងារសេដ្ឋកិច្ច និងការងារយោធា។ អនុលេខាទទួលការងារបក្ស។ ឯចំណែកក្រសួងប្អូនទៀត បងនួន គាត់ទៅគ្រប់គ្រងពីលើ ថែមពីលើទៅទៀត។ ដូច្នេះតួនាទីរបស់គាត់អនុលេខានេះ ទទួលការងារបក្សផងនេះ វាធ្វើឲ្យគាត់មានអំណាចទៅតាមឯកសារថ្ងៃ០៩ តុលា ដដែល ត្រង់ទំព័រ៥។ ដូចខ្ញុំបានរាយការណ៍រួចអំមិញហើយ។ ទំព័រ៥ បន្ទាត់ទីពីរ។ ម្នាក់មិននៅ ម្នាក់ទៀតសម្រេចជំនួស។

[១៥:៣៦:៣០]

ភស្តុតាងគឺពេលដែល បងប៉ុល សម្រាករៀបចំឯកសារសម្រាប់ប្រកាសបក្សជាចំហ បងនួនជំនួស។ ឯកសាររបស់ អ៊ីង វ៉េត អ៉! គង់ គៀន ហៅ អ៊ីង វ៉េត នេះបងៗខៀវ សរសេរទៅសូមជូនបងនួន ផ្ទាល់។ បងនួន អ្នកសម្រេច។ ដូច្នេះពេលនេះ សម្រេចពេលដែល បងប៉ុល គាត់ចូលសម្រាក។ សរុបមក អានេះជាភស្តុតាងមួយទេ។ ម្នាក់មិននៅ ម្នាក់ទៀតទទួលជំនួស។ បើលេខា អនុលេខាមិនដឹងរឿងអីទាំងអស់ ទទួលជំនួសម៉េចបាន? នេះក្នុងការអនុវត្តជាក់ស្តែង យើងមើលឃើញអ៊ីចឹង។ សរុបមកវិញ លោកមេធាវីសួរខ្ញុំថា បក្សហ្នឹងជាបុគ្គល ឬជាស្អី? តាមពិតបក្សហ្នឹងវាជាទ្រឹស្តី វាជាកម្លាំងនយោបាយមួយបែប ដែលប្រមូលផ្តុំមនុស្សតាំងពីអង្គការស្នូលរបស់បក្សទៅដល់អចិន្ត្រៃយ៍មជ្ឈិមបក្ស។

ក៏ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែងតាមគោលគំនិតប្រជាធិបតេយ្យប្រមូលផ្តុំ អំណាចទាំងអស់វាប្រមូលផ្តុំនៅក្នុងកណ្តាប់លេខា និងអនុលេខារបស់បក្ស។

[១៥:៣៧:៤៧]

**ស៖** អរគុណ។ សូមលោកបញ្ជាក់ឲ្យច្បាស់បន្តិចទៀតមើល៍ ថាតើអំណាចទាំងអស់ប្រមូលផ្តុំនៅលើលេខានិងអនុលេខា។ អាហ្នឹងមានស្អីចែងនៅក្នុងច្បាប់ទម្លាប់របស់បក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យទេ?

**ឆ៖** អរគុណ។ លោក អរុណ ពិនិត្យមើល សូមទោស! ជម្រាបប្រសាសន៍លោកប្រធាន សូមលោកមេធាវីពិនិត្យមើលលក្ខន្តិកៈបក្សអំពី ទីមួយវិន័យៗរបស់បក្ស ថ្នាក់ក្រោមគោរពថ្នាក់លើ។ យើងគោរពវិន័យតាមគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំដាច់ខាត ដោយភ្ជាក់រឭក។ ទាំងអស់នេះអ៊ីចឹង។

[១៥:៣៨:៤១]

សរុបមកវិញ ខ្ញុំសូមជូនឧទាហរណ៍មួយ។ ក្នុងឯកសារថ្ងៃ៣០ មីនា ១៩៨៦ សរសេរច្បាប់

បើនៅក្នុងមូលដ្ឋាន អ្នកសម្រេចកម្មេចគឺ លេខាភាគ ក៏ប៉ុន្តែ កង ចាប ហៅ សែ ដែលខាងលើចាប់អារម្មណ៍សង្ស័យ ដល់ កង ចាប សម្រេចអត្តនោម័តមិនសូមយោបល់របស់ បងប៉ុល ទៅចាប់បងប្អូនប្រពន្ធ បងហែម។ បងប្អូនប្រពន្ធ ខៀវ សំផន។ ដឹងដល់ បងប៉ុល បងប៉ុល បញ្ជាឲ្យគេចាប់បាន។

[១៥:៣៩:៣០]

ចាប់ កង ចាប ហៅ សែ មកចូលស-២១ យកកូនក្មួយរបស់ប្រពន្ធ បងហែម យកមកដាក់នៅតាខ្មៅ។ នេះលោក ខៀវ សំផន រាយការណ៍ជូនសហាចៅក្រមស៊ើបអង្កេត។ នេះជាឧទាហរណ៍មួយ។ អ្នកឯងមានសិទ្ធិកម្មេចមែន ក៏ប៉ុន្តែកម្មេចអត្តនោម័តប៉ះពាល់ដល់កម្លាំងបក្ស អ្នកឯងទទួលខុសត្រូវ។ ដូច្នេះក្នុងការអនុវត្តជាក់ស្តែងវាបញ្ជាក់អ៊ីចឹង។ ហើយលោកមើលឯកសារដែលនៅសល់ រឿងអីក៏ដោយ សុន សេន គាត់សរសេរទៅសុំយោបល់ស្រួលបួលណាស់ទៅ បងប៉ុល ហើយរឿងស្អីដែល បងប៉ុល សម្រេចជាគោលការណ៍ ហើយដាក់ជូនសមមិត្ត ណាត ពិនិត្យ ជូនសមមិត្តតាល់ ពិនិត្យឯកសារនៅមានដូច្នេះ កិច្ចដំណើរការនេះយើងឃើញមានភស្តុតាង។ នេះខ្ញុំសូមសរុបប៉ុណ្ណឹង។

**ស៖** សូមអរគុណចម្លើយនេះ។ ខ្ញុំសូមសួរសំណួរមួយ ស្របនឹងដែលលោកសាក្សីបាននិយាយថា កាលណាហៅ “បក្ស” គឺ លេខា និងអនុលេខា។ ចុះនៅក្នុងៗស-២១ នោះលោកជាប្រធានមន្ទីរ ស-២១ ហើយនិងអនុប្រធានម្នាក់ទៀតហ្នឹង កាលណាគេនិយាយពីរឿង ស-២១ និយាយទាំងពីរឈ្មោះអ៊ីចឹងទេ?

[១៥:៤០:៤៩]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន គេនិយាយទាំងពីរឈ្មោះអ៊ីចឹងមែន ពិត។ ក៏ប៉ុន្តែអ្នកដែលមានអំណាចទៅលើគេឯងដទៃទៀត គឺខ្ញុំ មានអំណាចលើ មិត្តហ៊ ទៅតាមគោលការណ៍របស់បក្ស ទៅតាមបែបបទបញ្ជារបស់បក្សគ្រប់ករណីយកិច្ច។ អ៊ីចឹងហើយបានជាមហាជននៅ ស-២១ គេហៅ ខ្ញុំ បងអ៊ីកើត គេហៅ មិត្តហ៊ បងអ៊ីលិច។ នេះមហាជននៅចាំ រឿងរ៉ាវអស់នេះ វាចេញផ្កាយចេញ។

**ស៖** ប៉ុន្តែការសម្រេចចិត្តធ្វើអ្វីមួយៗ ធ្វើទាំងពីរនាក់ ដូច ពត ហើយនិង នួន ជា អ៊ីចឹងទេ? ហើយគ្រប់កន្លែងទាំងអស់ធ្វើដូចគ្នាអ៊ីចឹងទេ? អាហ្នឹងបក្សកុម្មុយនីស្តប្រមូលផ្តុំហើយ។

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមអនុញ្ញាតឆ្លើយនឹងសំណួរលោកមេធាវីដូចតទៅ៖ កិច្ចការអីពីខាងលើមក ខ្ញុំទៅផ្សាយឲ្យគេ។ នែ៎ ខាងលើសម្រេចអ៊ីចេះៗ ចូនអីគេជំទាស់ ចូន

អីគេមិនជំទាស់ ចួនអីគេលើកហេតុផល អើ ធ្វើអ៊ីចេះមិនស្រួលទេបង អាហ្នឹងវាមាន។ ក៏ប៉ុន្តែកាលណាខ្ញុំមិននៅគេសម្រេចកិច្ចការផ្សេងៗជំនួសខ្ញុំ។ ហើយជាពិសេសទៀត ក្នុងកិច្ចការប្រចាំថ្ងៃនៅលើគេទាំងអស់ទេ ការងារនៅស-២១ កិច្ចការប្រចាំថ្ងៃនៅលើគេទាំងអស់។ គ្រាន់តែខ្ញុំដឹងឮ មុននឹងធ្វើអីគេប្រាប់ខ្ញុំនេះខ្ញុំដឹងឮ។ រួចអត់ពីខ្ញុំគេបញ្ជា ហ្អេ! ការពិតកិច្ចការប្រចាំថ្ងៃ គឺគេបញ្ជាសុទ្ធសាធ គ្រប់រឿង។

[១៥:៤២:៤២]

**ស៖** សូមអរគុណ។ ខ្ញុំធ្វើការវិភាគ ហើយសូមឲ្យលោកវិភាគជាមួយខ្ញុំត្រង់អាខែង ឯកសារការប្រជុំអចិន្ត្រៃយ៍ ដែលខ្ញុំជូនទៅលោកដែរនុ៎ង។ ត្រង់ថា ការបែងចែងការងារ ហើយនិងកិច្ចដំណើរការ។ ១) សមមិត្តលេខា ទទួលរួមយោធា និងសេដ្ឋកិច្ច សមមិត្តអនុលេខា ហ្នឹង-- គេមិនសរសេរថាទទួលទេ ការងារ ហ្នឹងប្រហែលជាអ្នកវាយខុស អាហ្នឹងខ្ញុំមិនដឹងទេ ប៉ុន្តែក្រែងសរសេរអ៊ីចឹង។ ការងារបក្ស បើតាមខ្ញុំយល់ការងារបក្សទទួលបន្ទុកសង្គមកិច្ច វប្បធម៌ ឃោសនាការ និងសិក្សាធិការ។ ខ្ញុំនិយាយហ្នឹងត្រូវ ឬក៏ ហីលោកយល់ខុសពីខ្ញុំ?

[១៥:៤៣:៣៩]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមឆ្លើយនឹងសំណួរលោកមេធាវីដូចតទៅ៖ ពាក្យ “ទទួល” នេះចួនអី បងប៉ុល គាត់និយាយទៅ ចួនអីគាត់មិនបាននិយាយ។ អាហ្នឹងមិនមែនជាវាយខុសទេ។ អ្នកកំណត់ហេតុគ្នានិយាយតាមតែខាងលើមានប្រសាសន៍។ ឯចំណែករឿងដែលបញ្ជាក់នៅក្នុងទីនេះ “ការងារបក្ស”។ តើ “ការងារបក្ស” ហ្នឹងស្អីខ្លះ? “ការងារបក្ស” ខ្ញុំសរុបខ្លីមក បញ្ចូលបក្ខជនដំឡើងថ្នាក់កម្មាភិបាល ហើយនិងដាក់វិន័យកម្មាភិបាល។ អាដាក់វិន័យហ្នឹងហើយ វាជាការងារសន្តិសុខហើយ សម្រេចកម្ទេចផ្ទៃក្នុងបក្សនោះ។ ហើយឯកសារមួយទៀត លោកមេធាវីគង់ឃើញហើយ។ ដូចជាឯកសារហ្នឹងដែរ ក៏មិនដឹង។ រឿងអីៗជឿទុកចិត្តតាមខ្សែយើង តាមខ្សែខ្មាំងមិនបានទេ ខ្សែយើងគឺនរណា? គឺនួន ជា ដែលគាត់ក្ដាប់ប្រវត្តិរូប ក្ដាប់ជីវទស្សនៈបដិវត្តន៍ និងប្រវត្តិសកម្មភាពរបស់បក្ខជនគ្រប់រូបបាន។ ភស្តុតាងជាក់ស្តែងនៅទីនេះ។ ខ្ញុំជឿថា បងនួន ក្ដាប់ប្រវត្តិរូបរបស់ ឡុង នរិន្ទ បានច្បាស់ជាង អៀង សារី ទៅទៀត។ នេះភស្តុតាងវាបង្ហាញអ៊ីចឹង។

**ស៖** អរគុណ។ លោកសាក្សីកាលពីលោកនៅកាន់ស-២១ ឋានៈលោកក្នុងបក្សហ្នឹងត្រឹមណា? បក្ខជនអ៊ីចឹងទេ? ឬក៏មានឋានៈអី?

**ឆ៖** អរគុណ។ ឋានៈរបស់ខ្ញុំជាលេខាគណៈកម្មាធិការមន្ទីរស-២១ នេះក្នុងបក្ស។ តើស្មើនឹងអី? ស្មើនឹងថ្នាក់ស្រុក។ ស្មើនឹងអ៎! ស្មើនឹងថ្នាក់ស្រុកប៉ុនន៎ុងឯង។

**ស៖** អរគុណហើយ។ សូមបន្តសំណួរដដែលហ្នឹង ខ្ញុំសូមបន្តថា បើលោកមានឋានៈស្មើនឹងថ្នាក់ស្រុក ហើយមុនបានឮនិយាយថាវរសេនាធំ។ លោកថ្នាក់ត្រឹមហ្នឹង ហេតុអីបានជាលោកដឹងដល់ទៅរឿងធំៗរបស់អចិន្ត្រៃយ៍ របស់មជ្ឈិម រឿងធំៗប្រទេសជាតិតច្រើនតទៅទៀត? លោកដឹងៗដោយរបៀបណា? ហើយដឹងពីអ្នកណា? ហើយសូមៗលោកឆ្លើយ។

[១៥:៤៦:២៣]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមឆ្លើយនឹងសំណួររបស់លោកមេធាវីដូចតទៅ។ មជ្ឈិមបក្សអាចចាត់តាំងមន្ទីរជំនួយការ ឬក៏មន្ទីរបច្ចេកទេសរបស់ខ្លួន។ បើតាមខ្ញុំចាំក្នុងមាត្រា ៨ នៃលក្ខន្តិកៈបក្ស។ ខ្ញុំស្ថិតនៅក្នុងមន្ទីរហ្នឹង ដែលគ្រប់គ្រងផ្ទាល់ដោយអចិន្ត្រៃយ៍ នេះខាងការងារសន្តិសុខគ្រប់គ្រងផ្ទាល់ដោយអចិន្ត្រៃយ៍។ បើខាងភស្តុភារ ខាងរៀនសូត្រ ខាងអី គ្រប់គ្រងដោយសេនាធិការ។ ដូច្នេះខ្ញុំអចិន្ត្រៃយ៍ចុះមកដឹកនាំ ឬតាមរយៈ ប៉ង់ ឬតាមរយៈ ន៎ែ សុន សេន ឬ បងនួន គាត់អញ្ជើញមកផ្ទាល់ អាហ្នឹងវាទៅស្របទៅតាមមាត្រា៨ បើខ្ញុំចាំដូចមាត្រា៨ នៃលក្ខន្តិកៈបក្ស។ និយាយអំពីមន្ទីរឯកទេសមួយចំនួន។

**ស៖** អរគុណ។ លោកតាំងពីលោកធ្វើការសន្តិសុខមក លោកដែលធ្វើការក្រោមបង្គាប់ វន វ៉េត ទេ?

**ឆ៖** អរគុណ។ ខ្ញុំជាមនុស្សដែល វន វ៉េត អប់រំកសាងពី៦៧ ហើយដល់ឆ្នាំ១៩៧១ ខ្ញុំជួប វន វ៉េត ឡើងវិញ។ ដល់ក្រោយមក វន វ៉េត អញ្ជើញទៅភូមិភាគពិសេសខាងត្បូងភ្នំពេញទៅ ខ្ញុំនៅក្រោមការគ្រប់គ្រងរបស់គ្រូខ្ញុំចាស់ គឺ សុន សេន។ ដូច្នេះ ប្រវត្តិខ្ញុំជាប់ទាក់ទងនឹង វន វ៉េត រហូតដល់ឆ្នាំ ១៩៧៣-៧៤នេះ។

[១៥:៤៨:១៣]

**ស៖** វន វ៉េត ក្រោយពេលរំដោះមានដែលបានកាន់កាប់សន្តិសុខតទៅទៀតទេ? ក្រោយពីរំដោះភ្នំពេញហើយ? មានន័យថា ក្រោយ១៧ មេសា ឆ្នាំ១៩៧៥?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន បងវន អត់កាន់កាប់កិច្ចការសន្តិសុខទេ។ គាត់នៅខាងសេដ្ឋកិច្ច ហើយនិងហិរញ្ញវត្ថុ។

**ស៖** ពេលដែល សុន សេន ទៅបំពេញបេសកកម្មនៅបូព៌ា នៅថ្ងៃ១៥ សីហា ឆ្នាំ១៩៧៧ រួច នួន ជា ទទួលភារកិច្ចនោះ។ អាហ្នឹងបើតាមសម្ដីលោកសាក្សី។ ខ្ញុំសួរថា តើលោក ឌុច សំអាងលើអ្វីបានជាថា នួន ជា ជាអ្នកទទួលជំនួស សុន សេន? មានលិខិតបញ្ជី-- បញ្ជាបេសកកម្ម ឬក៏លិខិតជាផ្លូវការអ្វីទេពេលដែល សុន សេន ទៅ? ហើយដែលលោកទទួលការងារដើម្បីទាក់ទងលោក នួន ជា ផ្ទាល់។

[១៥:៥០:០៥]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ដែលមេខ្ញុំអញ្ជើញទៅអ្នកលឿង ខ្ញុំមិនទាំងដឹងផងទេ។ ថ្ងៃមួយហ្នឹង មិត្តលីន មកហៅខ្ញុំថាបង ហៅន៎ែ ឲ្យបងទៅធ្វើការ។ ខ្ញុំក៏ទៅ។ ដល់ទៅៗជួបបងនួន នៅនឹងពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត នៅជាន់លើអង្គាល់ទុំង តែខ្ញុំពីរនាក់ បងនួន ទេ។ គាត់ថា មិត្តខៀវ ទៅសមរភូមិមុខហើយ មិត្តមកធ្វើជាមួយនឹងខ្ញុំ។ ប៉ុន្តែមិត្តស្គាល់ មិត្តប៉ង់ ហើយនិង មិត្តលីនស្រាប់ហើយ មិត្តប៉ង់ ចុះឡើងទៅទុំង មិត្តលីន ហើយនិងមិត្តប៉ង់ ចុះឡើងទៅទុំង។ នេះជារឿងពិត។

ឯចំណែកលិខិតតែងតាំងគ្មានទេ បង សុន សេន ក៏គ្មានលិខិតតែងតាំងពី បងប៉ុល មានតែក្នុងឯកសារសេចក្ដីសម្រេចនេះឯង ជាគោល ហើយនាំគ្នាធ្វើការស្ដាប់គ្នាទៅ។ នៅពេលដែល ណាត ចេញ ឲ្យខ្ញុំឡើងធ្វើជាលេខាស-២១ ក៏អត់មានលិខិតតែងតាំង ហើយអត់មានលិខិតដក ណាត ដែរ គឺខាងលើហៅទៅតែម្ដង។ នេះទម្លាប់ធ្វើការនៅក្នុងបក្សកុម្មុយនីស្ដកម្ពុជាវាអ៊ីចឹង។

[១៥:៥១:២៥]

**ស៖** អរគុណ។ សំណួរមួយទៀត ពេលណាដែលសាក្សីបានអានទង់បដិវត្ត? អានពីពេលណា? តើលោកសាក្សីបានអានទង់បដិវត្តពេលណា?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមអនុញ្ញាតនិយាយបញ្ហានេះឲ្យបានច្បាស់លាស់ ក្បោះក្បាយ។ ទស្សនាវដ្ដីផ្ទៃក្នុងបក្សកុម្មុយនីស្ដកម្ពុជា យកឈ្មោះតាមទស្សនាវដ្ដីបក្សកុម្មុយនីស្ដចិន។ ចិនគេដាក់ថា "ទង់ក្រហម" ភាសាចិនកុកងឺ គេហៅថា "ឆុងឈី"។ ខ្ញុំបានមើលអត្ថបទនេះម្ដងនៅក្នុងខែធ្នូ ១៩៦៧ នៅមន្ទីរស្រុកចម្ការលើ មន្ទីរសម្ងាត់។ ពេលនោះខ្ញុំធ្វើជាសមាជិកគណៈស្រុកបណ្ដុះបណ្ដាល។ ក្រោយមក ខ្ញុំមកជាប់គុកបាត់ទៅ ខ្ញុំចេញមកវិញ ខ្ញុំមកទទួលភារកិច្ចនៅមន្ទីរម-១៣ ថ្ងៃ២១ កក្កដា ១៩៧១ ដល់ទៅ ៧២ បានៗខ្ញុំអាន-- ទទួលទស្សនាវដ្ដីផ្ទៃក្នុងបដិវត្តន៍នេះឡើងវិញ អ៎ផ្ទៃក្នុងបក្សនេះឡើងវិញ។ សូមបញ្ជាក់ម្ដងទៀត ទស្សនាវដ្ដីផ្ទៃក្នុងបក្សនេះឡើងវិញ។ ម្ដងនេះប្រែឈ្មោះពី "ទង់ក្រហម" មកជា "ទងបដិវត្ត"។ តាំងពីពេលនេះមកខ្ញុំបានទទួលទស្សនាវដ្ដីទង់បដិវត្តរៀងរាល់

លេខជាទៀងទាត់មិនដែលខាន។

[១៥:៥៣:០៤]

**ស៖** មានន័យថា លោកបានទទួលទង់បដិវត្តតាំងពីថ្ងៃ២២ ខែ៧--

**ឆ៖** សូមទោស ខ្ញុំអាចនិយាយលឿនពេក លោកមេធាវីចាប់មិនបាន។ ខ្ញុំចូលធ្វើប្រធានស-២១ នៅថ្ងៃ២១ ខែ៧ ឆ្នាំ១៩៧១ ឯចំណែកដល់ចុងឆ្នាំនោះ បានខ្ញុំទទួលទស្សនាវដ្ដីទង់បដិវត្តជាទៀងទាត់ គឺចុងឆ្នាំ១៩៧១ នេះ។

**ស៖** មានចាំខែណាទេ បានទទួល?

**ឆ៖** វង្វេងហើយ។

**ស៖** វង្វេងហើយ? ៧១?

**ឆ៖** អឺ។

**ស៖** ទង់បដិវត្តលោកដឹងទេថា មានប៉ុន្មានក្បាលទេដែលបានទទួល? ឥឡូវបើលោកដឹងថាមានទាំងអស់ប៉ុន្មាក្បាល? ហើយបើថាមិនដឹង តើលោកបានទទួលប៉ុន្មានក្បាល?

[១៥:៥៣:៥៤]

**ឆ៖** ខ្ញុំជម្រាបប្រសាសន៍លោកប្រធាន ដល់ៗលោកមេធាវីសួរអ៊ីចឹង ខ្ញុំពិបាកយល់ណាស់ អំពិបាកគិតលេខណាស់។ ខ្ញុំគ្រាន់តែជម្រាបថា ខ្ញុំទទួលទស្សនាវដ្ដីបដិវត្តជាទៀងទាត់ រាល់ខែ។ ក៏ប៉ុន្តែសូមជម្រាបថា ទង់បដិវត្តពេលខ្លះគាត់បញ្ចូលពីរខែធ្វើជាលេខពិសេស។ ជាពិសេស ក្រោយថ្ងៃ១៧មេសា គាត់ឧស្សាហ៍បញ្ចូលណាស់ ពីរខែបីខែ ជាពិសេសពីរខែ ភាគច្រើនៗពីរខែទៅធ្វើមួយលេខ ហៅថា "លេខពិសេស"។ ដូច្នេះ យើងមិនអាចគិតទង់បដិវត្តទៅតាមចំនួនខែបានទេ ព្រោះវាមានករណីពិសេសអ៊ីចឹង។ នេះខ្ញុំសូមជម្រាបប្រធានដោយជ្រាប។

**ស៖** សូមអរគុណ។ ពេលដែលលោកឃើញ ហើយបានអានទង់បដិវត្តនោះ មានន័យថា លោកច្បាស់លាស់ណាស់ជាមួយទង់បដិវត្ត។ បើសិនជាលោកច្បាស់លាស់មែន ខ្ញុំសួរថាតើលក្ខណៈ និងចរិតរបស់សៀវភៅនោះ របស់ទង់បដិវត្តនោះរបៀបណា?

[១៥:៥៥:០៣]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ទង់បដិវត្តនេះ ពីឆ្នាំ៧១-- ចុងឆ្នាំ៧១នេះ ឬក៏ដើមឆ្នាំ៧២នេះ ពីចុងឆ្នាំ៧១មក។ មជ្ឈិមបក្សអចិន្ត្រៃយ៍ មជ្ឈិម បញ្ជូនទង់បដិវត្តទៅភូមិភាគនីមួយៗ

ដូចជាប្រាំក្បាលអីមិនដឹង មួយភូមិភាគ។ ភូមិភាគនីមួយៗតម្រូវចាត់តាំងអ្នកជំនាញសរសេរចម្លង ដល់ចម្លងហើយអូស អូសស្តិនស៊ីល ឬក៏រ៉ៃ ដើម្បីឲ្យមួយភូមិភាគៗចែងគ្នាបានគ្រប់ ១០០អីទៅ។ នេះជំនាន់នុំង។ ដោយឡែក ពេលនុំង!នៅតាមភូមិភាគនីមួយៗ យើងមានផ្លូវចេញចូលទាក់ទងពាណិជ្ជកម្ម យើងរកទឹកខ្មៅ-ក្រហមបាន។ ខ្ទង់ដាក់ទឹកខ្មៅ-ក្រហម។ រូបនៅខាងក្របខ្នង ក្របខាងលើចាប់ផ្តើមដំបូងទង់ប្រាំ។ ទង់ប្រាំនេះ មិនមែនបក់រវិកនោះទេ គឺរាងសន្លឹងត្រង់ភ្លឹង។

[១៥:៥៦:២១]

ដល់ក្រោយ១៧ មេសា មិនដឹងជាទង់បដិវត្តដាច់ប៉ុន្មានខែទេ បានចេញមកប្រើពុម្ព ព្រោះយើងមានរោងពុម្ព។ ដល់ប្រើពុម្ពនោះ ដំបូងក៏នៅតែទង់ប្រាំដែរ។ ដល់ចុងក្រោយនេះ បានជាទង់បក់ហ្នឹង។ នេះលក្ខណៈរបស់ទង់បដិវត្ត គឺអ៊ីចឹង។

**ស៖** អ្ហឺ! ខ្ញុំដូចជានៅស្មាក់ស្មើរ ប៉ុនសួរបញ្ជាក់បន្ថែមម្តងទៀតថា សៀវភៅទង់បដិវត្តចេញជារបៀបសៀវភៅ ហើយលោកបាននិយាយហើយថា ទង់បដិវត្តមុនដំបូងពីឆ្នាំ៧១រហូត អ៎! ពីមុនមករហូត មកដល់ឆ្នាំ៧៥ សរសេរជាដៃ ហើយទាញនឹងដៃទៀត។ អ៊ីចឹងត្រឹមត្រូវហើយណាស់?

**ឆ៖** បាទ ត្រូវហើយ។

**ស៖** ហើយក្រោយពីហ្នឹងមក បានធ្វើពណ៌ខាងក្រៅ ក្រោយ៧៥?

**ឆ៖** អ្ហឺ!

[១៥:៥៧:១៨]

**ស៖** ហើយខាងក្នុងនៅសរសេរដៃអ៊ីចឹងដដែល ឬក៏រ៉ៃដាក់ទីឡូ ឬក៏មានកុំព្យូទ័រអីហើយ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន មុនឆ្នាំ១៩៧៥ ទង់បដិវត្តសរសេរនៅលើស្តិនស៊ីល រ៉ូណេអូ ឬក្រអូបអ៊ីចឹង។ ខាងក្រៅពណ៌ក្រហម ខាងក្នុងពណ៌ខ្មៅ និងអក្សរ ក៏ប៉ុន្តែជាអក្សរដៃ។ ក្រោយឆ្នាំ១៩៧៥ ទើបមានពុម្ព អក្សរពុម្ពខាងក្នុង ហើយខាងក្រៅគេឆ្លាក់ហើយឈ្មោះទស្សនាវដ្តីទង់បដិវត្តហ្នឹងគេឆ្លាក់ គេក្បាច់ក្បូរទៅតាមនុំង! ហើយលេខខែណា អីខែណា ក៏គេឆ្លាក់ស្អាតដែរ។ ក៏ប៉ុន្តែនៅតែពណ៌ក្រហមពីខាងក្រៅដដែល។ គ្រាន់តែទង់ ដំបូងប្រែរូបពីទង់ប្រាំ ដែលសន្លឹងស្មើរតែត្រង់ភ្លឹងនោះ មកជាទង់ប្រាំដែលមានរាងបក់បន្តិច។ ដល់ក្រោយមក ចោលទង់ប្រាំទៅ នៅទង់មួយ ហើយរាងបោយបក់ផ្ចត់ជាអក្សរ "អេស" នេះច្បាស់លាស់។

[១៥:៥៨:៣២]

សរុបមក ក្រោយ១៩៧៥ សុទ្ធតែជាអក្សរពុម្ព។ គំរូដែលបង្ហាញមកខ្ញុំ ប៉ុន្មាននេះ គឺពិតជាទស្សនាវដ្ដីដែលថតចម្លងចេញពីទង់បដិវត្តពិតប្រាកដហើយ។

**ស៖** សូមអរគុណ។ ខ្ញុំប្ដូរអត្ថបទទៅជា-- ខ្ញុំនិយាយអំពីរឿងជនៗជម្លៀសចេញពីទីក្រុង។ លោកសាក្សី សូមលោក-- កាលពីថ្ងៃ កាលពីអាទិត្យមុន លោកបានបញ្ជាក់ប្រាប់ទៅសហព្រះរាជអាជ្ញាអំពីគោលការណ៍សម្រេច ដែលសាក្សីមិន សឹងតែមិនជឿថា អ្នកខាងក្រោមអាចដឹងនោះទេ។ គឺលេខា អនុលេខាបក្សជាអ្នកសម្រេច ដើម្បីជម្លៀស។ និយាយដូច្នេះ ថាលេខា និងអនុលេខាអ្នកសម្រេចនោះ តើអ្នកពីណាមានអ្វី-- សូមទោស! សម្រេចនោះ ថាតើលោកសាក្សីដឹងនេះ ឮគេថា ឬក៏គេបានបញ្ជាជាឯកសារមកពីថ្នាក់លើ?

[១៦:០០:០៥]

**ឆ៖** អរគុណ។ ខ្ញុំសូមនិយាយថា ព្រឹត្តិការណ៍ដែលកើតមានឡើងនៅក្នុងសង្គមកម្ពុជា ដំបូងបក្សកុម្មុយនីស្តកម្ពុជាណែនាំនៅក្នុងទង់បដិវត្តអំពីការជម្លៀសប្រជាជនពីបាវាយណ៍។ នៅពេលដែលព្រឹត្តិការណ៍របស់ លន់ នល់ ដូចជាអាចេនឡាទីពីរអ៊ីចេះមិនដឹង។ គាត់ថា ដល់ពេលជម្លៀសប្រជាជនអ៊ីចឹងទៅ ខ្មាំងវាចូល វាហេលហាល។ មិនដឹងជាធ្វើស្អី។ ម្ល៉ោះហើយ យើងមានឱកាសវ៉ៃខ្មាំង ហើយយើងជម្លៀសប្រជាជនទៅ យើងទុកដូចជាបងប្អូនរបស់យើងអ៊ីចឹង ឧបត្ថម្ភគ្នា។ នេះ ខ្ញុំឃើញក្នុងទស្សនាវដ្ដីទង់បដិវត្តទេ។

[១៦:០០:៤៣]

ដល់ឆ្នាំ១៩៧៤ បក្សកុម្មុនីស្តកម្ពុជាវ៉ៃបែកឧដុង្គ ពេលនុ៎ង សម្រេសជម្លៀស ក៏ខ្ញុំមិនដឹង។ ក៏ប៉ុន្តែនៅពេលនុ៎ងឯង មេ អង្កាល់ណោះ សុន សេន គាត់បញ្ជាខ្ញុំ ថាមិត្តរៀបចំទៅ អ្នកនេះៗៗត្រូវបញ្ជូនទៅពោធិ៍សាត់ ចាំឡានគេដឹកជនជម្លៀសចេញពីឧដុង្គ គេហៅចូលហៅ។ មិត្តឱ្យឡើងឡានទៅពោធិ៍សាត់ទៅហ្នឹងគេទៅ។ ដូច្នេះហើយ បានៗពេលនុ៎ង នៅសល់មនុស្សម្នាក់ដែលតុលាការយើងស្គាល់ គឺ KW-30 ហៅ អ៊ុច ស៊ន នោះ។ គាត់មក ធ្វើសក្ខីកម្មនេះ។ ហើយអ្នកដែលជម្លៀសទៅប៉ុន្មាន ចេញពី ម-១៣ ហ្នឹង មាននៅរស់មួយចំនួនធំដែរ ដូចស្លាប់តែម្នាក់អីទេ។ នេះ ចម្លើយវាមានហួរហែអ៊ីចឹង។

[១៦:០១:៣៥]

ដល់ក្រោយ១៧មេសា ពេលនោះ ខ្ញុំនៅអមលាំងទេ។ មុនដំបូង ពីរបីថ្ងៃក្រោយមក ខ្ញុំឃើញមនុស្សរ៉ែកកញ្ជើទៅវពុយ ខ្ញុំថា អ្ហែ! បែបគេភ្ជាក់រឮកទៅស្រុកកំណើត។ ដល់ក្រោយមក បានដឹងល្បី

ថានៅកន្ទ្បែងសម វត្តកន្ទ្បែងសម ឃុំអមលាំង ដំបូងខេត្តកំពង់ស្ពឺនេះ មានការិយាល័យមួយដែល បងស៊ីគាត់ចាត់តាំង ឲ្យបំបែកមនុស្សទៅតាមវណ្ណភាព ទៅតាមប្រវត្តិរូប។ មួយចំនួនត្រូវយកទៅកម្ទេចផ្ទះនៅក្បែរវត្តកន្ទ្បែងសម ជាភស្តុតាងមួយហើយ។ ខ្ញុំដឹងប៉ុននុ៎ង។

[១៦:០២:១៥]

ដល់ចូលមកដល់ភ្នំពេញបាត់។ ដល់ថ្ងៃ២៦ មិថុនា អ៊ីចេះមិនដឹង ២៥ ឬ២៦? មាននៅក្នុងឯកសារ ក.ណ.ហ លេខ១៦៦។ មានការរៀនសូត្រវគ្គ ឯកសារដំបូងគឺ កត្តាជ័យជម្នះរបស់យើង។ បក្សណែនាំថាដែលយើងឈ្នះនេះ គឺឈ្នះមហាលោតផ្លោះ មូលហេតុគឺយើងបានត្រៀមលក្ខណៈសម្បត្តិយើងបានកសាងលក្ខណៈសម្បត្តិត្រៀមឈ្នះបានល្អ។ ជម្លៀសប្រជាជន ហើយនិងបណ្តាញពួកបរទេសជាពួកបស្ចិមប្រទេសចេញទៅប្រទេសតាមរយៈអរញ្ញ។ នេះវាមាននៅក្នុងឯកសារជាភស្តុតាង។ ហើយខ្ញុំនិយាយហួសមួយម៉ាត់ទៅទៀត នៅពេលដែលខ្ញុំទៅដឹកនាំធ្វើប្រវត្តិរូប-- អ៎ ផ្លូវជីវទស្សន៍របស់ពួកកងពល៧០៣ មានគេរាយការណ៍ប្រាប់ខ្ញុំ ពីរឿងពេលជម្លៀសហ្នឹង ពួកកងហ្នឹង វាប្រើហិង្សាដាក់ប្រជាជន បាញ់រះពីក្បាលអ៊ីចឹង។ នេះ កិច្ចដំណើរការប៉ុណ្ណេះ។ ដែលខ្ញុំយល់ការជម្លៀសប្រជាជនវាជាផែនការត្រៀមឈ្នះរបស់បក្ស។ ខ្ញុំសូមបញ្ចប់។

[១៦:០៣:៤៥]

**ស៖** សូមអរគុណ។ សំណួរមួយទៀតថា តើលោកសាក្សីសំអាងទៅលើអ្វីហៅថា លោក នួន ជា ថាបងទីពីរ តើជា១ក្បួន ជាតម្រារបស់បក្សឲ្យហៅអ៊ីចឹង បងទីមួយ ទីពីរ អ៊ីចឹង ឬក៏លោកហៅដើម្បីស្និទ្ធស្នាល ឬក៏ឮពេលក្រោយមកទេ ពាក្យហ្នឹង?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន គ្មានក្បួនតម្រាឯណាទៅបញ្ជាយុទ្ធជនស-២១ ឲ្យខ្ញុំបងឯកើត មិត្តហ៊ី បងឯលិចទេ។ បាទនេះគេហៅ។ ឯចំណែក បងទីមួយ បងទីពីរ នេះ អ្នកនាំអាតឲ្យដឹងគឺ កុយ ធួន។ បងទីមួយ បងទីពីរ គឺ កុយ ធួយ ហ្នឹងតែម្តង ដែលនាំឲ្យខ្ញុំដឹង។ ដល់ក្រោយមក ប៉ង់ វាចុះឡើងផ្ទះខ្ញុំ គាត់ចុះឡើងផ្ទះខ្ញុំ ស្រាប់តែហៅ បងម៉ុក បងទីបួន។ នេះវាមានជាតម្រាយអ៊ីចឹង បាន១វាលេចចេញអាពាក្យហ្នឹង។

[១៦:០៤:៥៧]

**ប្រធានអង្គជំនុំ៖**

លោក១មេធាវីតើនៅប៉ុន្មានសំណួរទៀត? ទំនងជាត្រូវប្រើប្រាប់ពេលវេលាប៉ុន្មានទៅ?

**លោក សុន អរុណ៖**

ខ្ញុំនៅប្រហែលជា-- សំណួរនៅប្រហែលជាមួយម៉ោងទៀត បើសិនលោកអនុញ្ញាត ឬក៏ថាអនុញ្ញាតឲ្យខ្ញុំធ្វើនៅពេលព្រឹកស្អែក ខ្ញុំសូមមួយម៉ោង។ អ៎! ស្អែកថ្ងៃសុក្រហើយ ស្អែកថ្ងៃសុក្រ សូមទោសថ្ងៃចន្ទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមសួរទៅក្រុមមេធាវីការពារក្ដីលោក អៀង សារី ហើយនិងលោក ខៀវ សំផន តើក្រុមមេធាវីពីរក្រុមហ្នឹងត្រូវប្រើប្រាស់ពេលវេលាប៉ុន្មាន ទៅក្នុងការតាំងសំណួរដេញដោលសាក្សីរូបនេះ? ទំនងជាការប្រមើលមើលនូវពេលវេលា។ លោកមេធាវី ម៉ៃខល កាណាវាស?

[១៦:០៦:៤០]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជម្រាបថា ខ្ញុំត្រូវការមួយថ្ងៃ ប្រហែលជាមួយថ្ងៃជាងបន្តិច ខ្ញុំមិនដឹងច្បាស់ទេ។ ខ្ញុំមានពេលបីថ្ងៃ ដើម្បីមើលអ្វីៗទាំងអស់ ហើយបូកបង្រួមដើម្បីខ្ញុំអាចគ្រប់គ្រងពេលវេលាបាន ដើម្បីសួរពិនិត្យដោយមិនចាំបាច់សួរសំណួរដដែលៗឡើងវិញ។ ខ្ញុំជម្រាបថា មានករណីមួយចំនួនខ្ញុំអាចត្រឡប់ទៅក្រោយ ហើយនិយាយបញ្ហាមួយចំនួនដែលមិនពេញចិត្តតាមយើងខ្ញុំដែលលម្អិតដែលយើងចង់បាន។

ហើយខ្ញុំសូមរក្សាមួយថ្ងៃ ហើយមេធាវី ខៀវ សំផន មួយថ្ងៃ។ ប៉ុន្តែវាអាស្រ័យលើពួកគាត់ បើសិនជាក្នុងករណីនោះ ប្រហែលជាតិចជាងមួយថ្ងៃ។ ប៉ុន្តែខ្ញុំត្រូវការពេលបីថ្ងៃ ដើម្បីពិនិត្យមើលអ្វីៗទាំងអស់ ដើម្បីផ្ដោតអារម្មណ៍ជាសំខាន់ទៅលើការពិនិត្យទាក់ទងទៅនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ។ បាទ ដូច្នេះហើយយើងខ្ញុំនឹងគោរពទៅតាមបញ្ញានីតិវិធីដែលសម្រេចរួចហើយនេះបាទ។

[១៦:០៧:៥១]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រី--អ៎! លោកមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន?

**លោក អាកទួរ វែកគែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំស្ថិតនៅក្នុងស្ថានភាពដូចលោក កាណាវាស ដែរ។ ពិតណាស់ថាយើងមានសិទ្ធិអាទិភាព ដោយសារតែយើងនៅក្រោយគេ។ ដូច្នេះ វាធ្វើឲ្យមានស្ថានភាពស្មុគស្មាញដែរ

ដើម្បីធ្វើម៉េចឲ្យយើងចៀសវាងនៅការនិយាយច្រំដែល សួរសំណួរដដែលៗនោះ។ ខ្ញុំត្រូវការពេលវេលាដែរ សម្រាប់ពេលវេលាបីថ្ងៃនេះ សម្រាប់ពិនិត្យមើលទៅលើសំណួរដែលបានសួរឡើងវិញ ដើម្បីចៀសវាងសំណួរដដែលៗ។ ដូច្នេះ ឥឡូវនេះវាពិបាកណាស់ចំពោះខ្ញុំ ក្នុងការឆ្លើយទៅឲ្យបានជាក់លាក់ជូនអង្គជំនុំជម្រះនោះ។ ដូច្នេះ ខ្ញុំគិតថា ប្រហែលជាត្រូវការមួយថ្ងៃសម្រាប់ការសួរ រួមជាមួយនិងសហភាតាកម្ពុជារបស់ខ្ញុំ។ នេះជាការពិត។ អង្គជំនុំជម្រះបានគិតថា មិនប្រើប្រាស់ពេលវេលាថ្ងៃពុធ ឬទៅថ្ងៃព្រហស្បតិ៍ សម្រាប់សប្ដាហ៍ក្រោយ សម្រាប់សវនាការនោះទេ។

[១៦:០៩:០៨]

ដូច្នេះវាមានការលំបាកសម្រាប់ខាងយើងខ្ញុំ។ ដូច្នេះជាថ្មីម្ដងទៀត យើងខ្ញុំឥឡូវនេះពិបាកក្នុងការសន្មត ក្នុងសន្និដ្ឋានប្រាប់ឲ្យបានច្បាស់ជូនអង្គជំនុំជម្រះថា តើយើងត្រូវការប៉ុន្មាន ប៉ុន្តែគឺយ៉ាងហោចណាស់គឺមួយថ្ងៃពេញតែម្ដង។

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:១០:១៦]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ពេលក៏សមល្មមនឹងសម្រាកហើយ ហើយនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។ ដោយមានសំណើសុំពីក្រុមមេធាវីការពារក្ដីរបស់ នួន ជា ហើយម៉្យាងទៀតដោយសារបញ្ហាពេលវេលាដែលយើងបានកំណត់ធ្វើសវនាការ នៅសប្ដាហ៍ក្រោយពីរថ្ងៃ សម្រាប់គ្រោងជូនទៅមេធាវីការពារក្ដីពីរក្រុមផ្សេងទៀត ដែលគាត់បានលើកឡើងបញ្ហានេះតាំងពីដើមទីមក។ ដោយឡែកបញ្ហាមេធាវីការពារក្ដីលោក នួន ជា គឺបានកំណត់យកស្នើសុំពីរថ្ងៃ។ ហើយដោយសារមានបញ្ហាខ្លះនៅក្នុងកិច្ចដំណើរការសវនាការ ដូច្នេះអង្គជំនុំជម្រះសម្រេចដូច្នេះថា ពីរថ្ងៃគឺថ្ងៃចន្ទ និងអង្គារ គឺហ្នឹងប្រគល់ទៅឲ្យមេធាវីការពារក្ដីពីរក្រុមថ្មីផ្សេងទៀត ដើម្បីដំណើរការសួរដេញដោលសាក្សីរូបនេះ។ ហើយប្រសិនបើមានពេលវេលានោះ គឺអង្គជំនុំជម្រះនឹងនៅសល់ពេលវេលា អង្គជំនុំជម្រះនឹងផ្ដល់ជូនទៅមេធាវីការពារក្ដីនួន ជា ដើម្បីសួរបញ្ចប់នូវគោលបំណងនៃការសួររបស់ខ្លួន។ ហើយប្រសិនបើពេលវេលានោះមិនមានទេ អង្គជំនុំជម្រះនឹងសម្រេចបញ្ចប់ទៅតាមស្ថានភាពជាក់ស្ដែងនៃកិច្ចដំណើរការសវនាការ ថ្ងៃចុងក្រោយ គឺថ្ងៃអង្គារទី១០ ខែមេសា ឆ្នាំ២០១២។

[១៦:១១:៣៨]

បាទ ឥឡូវនេះពេលវេលាសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ និងថ្ងៃអង្គារ ទី០៩ និងទី១០ ខែមេសា ឆ្នាំ២០១២ គឺពីរថ្ងៃដើមសប្តាហ៍ក្រោយ។ អាស្រ័យហេតុនេះសូមភាគី និងសាធារណជនជ្រាប។

អនុរក្សមន្ទីរឃុំឃាំងឲ្យអញ្ជើញសាក្សី កាំង ហ្កេកអ៊ាវ ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះនៅថ្ងៃចន្ទ ទី០៩ ខែមេសា ឆ្នាំ២០១២ វេលាម៉ោងប្រាំបួនព្រឹកឲ្យដល់កន្លែងផ្តល់សក្ខីកម្ម។

[១៦:១២:២៣]

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំពួកគាត់មកកាន់បន្ទប់សវនាការនេះនៅព្រឹកថ្ងៃចន្ទ ទី០៩ ខែមេសា ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:១២ នាទី)*